ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី១៧)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍
*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង
លោក ម៉ាតូ គ្រីស្ពារ
*(Mr. Matteo Crippa)*
លោកស្រី សែ កុលវុឌ្ឍី
កញ្ញា ណាថាក់ វិចស៊ែល
*(Ms. Natacha Wexels-Riser)*
លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ ប៊េត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទួអាត ហ្វដ *(Mr. Stuart FORD)*

**មេធាវីការពារជនជាប់ចោទ កាំង ហ្កេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោក គង់ ពិសី

លោក យ៉ុង ផានិត

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វែនណឺ

*(Mr. Alain Werner)*

លោកស្រីអេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សីជំនាញ ៖** លោក ក្រេក អេតឆេសាន់

សួរដោយ ចៅក្រម ស៊ីលយ៉ា ខាត់វ៉ាយថ៍ ផ្តើមពី .......................................................ទំព័រ ១
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ ផ្តើមពី ............................................................ទំព័រ ៤១

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡិចសាន់ឌឺ ប៊ែត | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |
| លោក គង់ ពិសី | ខ្មែរ |
| លោកស្រី ស៊ីលឃិ ស្ទូតហ្សីនស្គី | អង់គ្លេស |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក គ្រេក អេតឆេសាន់ | អង់គ្លេស |
| លោកស្រី អេលីហ្សាប៉ែត វ៉ាបេសាន់ដ្រាតាណា | បារាំង |

# កិច្ចដំណើរការនីតិវិធី

[០៩:១៤:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តដំណើរការនីតិវិធីសវនាការ ។ ជាដំបូងនេះក្រឡាបញ្ជីឡើងរាយការណ៍អំពីវត្តមាន អវត្តមានអ្នកដែលត្រូវចូលរួមនៅក្នុងនីតិវិធីសវនាការនាព្រឹកនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ។ ភាគីដែលបានចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួនហើយ ។

**ប្រធានអង្គជំនុំ៖**

នៅព្រឹកនេះ ដោយសារយើងធ្វើសវនាការពីម្សិលមិញស្តាប់សក្ខីកម្មរបស់អ្នកជំនាញបណ្ឌិត ក្រេក អេតធេសាន់ ហើយដំណើរការម្សិលមិញយើងមិនទាន់ចប់ទេ ។ អ៊ីចឹងព្រឹកនេះយើងនឹងដំណើរការនៃការស្តាប់នូវសក្ខីកម្មរបស់អ្នកជំនាញរូបនេះតទៅទៀត ។ ហើយជាកិច្ចបន្តគឺសូមជូនវេទិកានេះទៅចៅក្រមលោកស្រី ខាតវាយថ៍ ដើម្បីដំណើរការតាំងសំណួរសួរដល់អ្នកជំនាញជាបន្ត ។

សូមអញ្ជើញ លោកស្រី ។

**សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អរគុណលោកប្រធាន ។

**ស៖** បណ្ឌិត អេតធេសាន់ គឺលោកនៅតែរក្សាការស្បថដែលលោកបានធ្វើឡើងកាលពីម្សិលមិញ តើលោកនៅយល់ដែរ ឬទេចំពោះករណីនេះ?

**លោក ក្រេក អេតធេសាន់៖**

**ឆ៖** បាទ, ខ្ញុំនៅតែរក្សាការសម្បថរបស់ខ្ញុំដដែល ។

**ស៖** កាលពីម្សិលមិញខ្ញុំសួរលោកអំពីឯកសារជាច្រើនដែលលោកបានដកស្រង់ដែលសុន សេនបានចេញបញ្ជាទាក់ទងទៅនឹងបញ្ហាសន្តិសុខផ្ទៃក្នុងដល់មេបញ្ជាការផ្នែកសន្តិសុខ ។ បន្តទៅលើចំណុចនេះសំណួររបស់ខ្ញុំ ថាតើយោធាបានធ្វើការកម្ទេចសមាជិករបស់ខ្លួនដែរឬទេ? ហើយសូមឲ្យលោកលើកឧទាហរណ៍ចំពោះករណីនេះ ។

[០៩:១៧:៤០]

**ឆ៖** អរគុណលោកស្រីចៅក្រម ។ ប្រសិនបើតុលាការអនុញ្ញាតមុននឹងខ្ញុំឆ្លើយតបទៅនឹងសំណួរ ខ្ញុំចង់រំឭកក្នុងសក្ខីកម្មរបស់ខ្ញុំកាលពីម្សិលមិញពេលរសៀល ហើយខាងមេធាវីការពារក្តីចង់ឲ្យខ្ញុំផ្តល់ឯកសារយោងទាំងស្រុងទៅលើ ចំណុចយោងទៅលើឯកសារទាំងស្រុងដែលខ្ញុំបានលើកឡើងម្សិលមិញ។ ព្រឹកមិញខ្ញុំបានរៀបចំឯកសារមួយដែលវាបង្ហាញអំពីឯកសារយោងដែលខ្ញុំចង់លើកឡើងនៅក្នុងសក្ខីកម្ម ។ នៅក្នុងនោះគឺមានលេខសំណុំរឿង ហើយនិងលេខយោងទៅលើ លេខយោងអេឡិចត្រូនិច ហើយលេខយោងភាសាអង់គ្លេស បារាំង និងខ្មែរ ។ ហើយរួមទាំងចំណងជើងនៅក្នុងនោះផងដែរ ។ ហើយខ្ញុំរៀបចំក្នុងរយៈពេលខ្លីមួយ ដូច្នេះហើយវាមិនមែនជាព័ត៌មានទាំងស្រុងនោះទេ ។ ប៉ុន្តែ ខ្ញុំនឹងផ្តល់ឯកសារនេះជូនតុលាការ ហើយសង្ឃឹមថាវាជាផលប្រយោជន៍សម្រាប់ភាគីគ្រប់ទាំងអស់ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អរគុណលោកបណ្ឌិត អេតឆេសាន់ ។ ហើយប្រហែលជាផលប្រយោជន៍ជាបឋមចំពោះខាងការពារក្តី ហើយវាជាប្រយោជន៍ខាងសម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ។ ដូច្នេះ ឯកសារថតចម្លងមួយច្បាប់ គឺយើងនឹងផ្តល់ជូនមេធាវី ការ សាវុត្ថ និង លោក រូ ហើយយ៉ាងហោចណាស់យើងផ្តល់មួយច្បាប់ទៅដល់ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

សូមអរគុណលោកបណ្ឌិត អេតឆេសាន់ ។

**ស៖** ឥឡូវនេះ ត្រឡប់ទៅសំណួររបស់ខ្ញុំវិញ តើលោកអាចនិយាយបានទេថា ការបោសសម្អាតរបស់យោធាទុំង អាចដែលបានកើតឡើង តើលោកអាចផ្តល់ឧទាហរណ៍ខ្លះបានទេ ទាក់ទងទៅនឹងការស្រាវជ្រាវរបស់លោក?

**លោក ក្រេក អេតឆេសាន់៖**

**ឆ៖** បាទ, លោកស្រីចៅក្រម! គឺមានការបោសសម្អាតទ្រង់ទ្រាយធំនៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យទាក់ទងទៅនឹងកម្លាំងយោធា ។ បើសិនជាលោកស្រីចៅក្រមអនុញ្ញាត គឺខ្ញុំចង់ធ្វើការបង្ហាញនូវអង្គហេតុមួយចំនួនទាក់ទងទៅនឹងតារាង ។ អង្គសវនាការបានដឹងហើយថា ខាងការិយាល័យសហព្រះរាជអាជ្ញាបានដាក់នៅក្នុងសំណុំរឿងនូវឯកសារផ្គុំគ្នារបស់ស-២១ គឺបញ្ជីឈ្មោះអ្នកទោសដែលជាឯកសារនៅក្នុងសំណុំរឿងគឺឯកសារ D25 ដែលមាន ERN លេខ00172353 រហូតទៅដល់លេខ00172255 នៅក្នុងភាសាជាភាសាអង់គ្លេស ។ ហើយតារាងដែលខ្ញុំចង់បង្ហាញហ្នឹងគឺអាស្រ័យ

ពឹងទៅលើតារាងដែលយើងបានប្រមូលផ្តុំចូលគ្នាទៅក្នុងបញ្ជីឈ្មោះអ្នកទោស ហើយក៏មានតារាងនៅក្នុងសំណុំរឿងផងដែរ ដែលជាវិធីមួយផ្សេងទៀតក្នុងការពិនិត្យមើលព័ត៌មានដែលមាននៅក្នុងសំណុំរឿងរួចហើយ ។ ហើយខ្ញុំក៏បានដឹងដែរថា ប្រហែលជានៅក្នុងព្រឹកនេះផងដែរ ខាងការិយាល័យសហព្រះរាជអាជ្ញានឹងដាក់តារាងនេះនៅក្នុងសំណុំរឿង ជាមួយនឹងតារាងផ្សេងៗមួយចំនួនធំទៀតក្នុងការបង្ហាញព័ត៌មាន ដែលជាការបញ្ចូលគ្នានូវបញ្ជីឈ្មោះអ្នកទោសនៅស-២១ ។

[០៩:២៣:២៨]

**ចៅក្រម ស៊ីលវីយ៉ា ខាតវ៉ាយថ៍៖**

តើមានភាគីណាផ្សេងធ្វើការជំទាស់ទៅនឹងការបង្ហាញអំពីតារាងនេះ ក្នុងការប្រើបង្ហាញនៅក្នុងដំណាក់កាលនេះ?

**លោក អាឡិចសាន់ឌឺ ប៊េត៖**

លោកស្រីចៅក្រម,ខ្ញុំចង់ធ្វើការបង្ហាញថា អ្វីដែលលោក អេតឆេសាន់ បាននិយាយគឺជាការត្រឹមត្រូវហើយគឺ ខាងការិយាល័យសហព្រះរាជអាជ្ញាចង់ធ្វើការដាក់បញ្ចូលនូវឯកសារតារាងមួយចំនួនដែលបានដកស្រង់យកមកពីបញ្ជីរួមរបស់បញ្ជីឈ្មោះអ្នកទោស ហើយយើងគិតថា ឯកសារទាំងហ្នឹងដែលលោក អេតឆេសាន់ គាត់នឹងពឹងលើនៅក្នុងការបង្ហាញនេះឯង នឹងត្រូវការដាក់បញ្ចូលនៅក្នុងព្រឹកនេះ ។

**ចៅក្រម ស៊ីលវីយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ តើមានចំណុចជំទាស់អ្វីពីភាគីដើមបណ្តឹងរដ្ឋប្បវេណីទេ?

**លោក អាឡាំង វែនណឺ៖**

មិនមានទេ ។

**ចៅក្រម ស៊ីលវីយ៉ា ខាតវ៉ាយថ៍៖**

ដូច្នេះ ដូចជាគ្មានជំទាស់ពីភាគីណាផ្សេងទៀតទេ ។ តើមានចំណុចជំទាស់អ្វីពីខាងមេធាវីការពារក្តីដែរឬទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកស្រីចៅក្រម, មេធាវីការពារក្តីសោកស្តាយណាស់ដែលថា ឯកសារនេះបានមកក្នុងរយៈពេលយឺតពេលទៅហើយ ។ ហើយមេធាវីខាងក្រុមការពារក្តីមិនបានដឹង ថាតើឯកសារហ្នឹងបង្ហាញអំពីអ្វីទេ ។ អ៊ីចឹងយើងនឹងពិនិត្យមើលថា តើយើងអាចទទួលយកបានឬទេនូវឯកសារនោះ ដើម្បីបញ្ចូលទៅ

ក្នុងសំណុំរឿង ប្រហែលជានៅពេលក្រោយបន្តិចទៀតនេះ ។ សូមអរគុណ។

[០៩:២៥:00]

**សួរដោយ ចៅក្រម ស៊ីលវ៉ា ខាតវ៉ាយថ៍៖**

**ស៖** អរគុណ ។ ខ្ញុំនឹងផ្តល់ឱកាសឲ្យលោកដើម្បីធ្វើអត្ថាធិប្បាយនៅពេលក្រោយទៀតនៅពេលដែលលោក អេតធេសាន់ បានបញ្ចប់ភស្តុតាងទាក់ទងទៅនឹងចំណុចនេះ ។ ហើយខ្ញុំនឹងបំពេញទៅតាមសំណើរបស់លោក ។

សូមអរគុណលោកអេតធេសាន់ លោកអាចធ្វើការបង្ហាញនូវតារាង ក្រាហ្វ ហ្នឹងបាន អាស្រ័យទៅនឹងសិទ្ធិរបស់មេធាវីការពារក្តី តើគេនឹងធ្វើការជំទាស់ដែរឬក៏អត់នោះ?

**ឆ៖** សូមអរគុណលោកស្រីចៅក្រម ។ បើសិនខាងផ្នែកសោតទស្សន៍អាចធ្វើការប្តូរមក *ឡេប ថប* របស់ខ្ញុំបានដែរឬទេ? នៅក្នុងកាលវិភាគនៃបញ្ជីឈ្មោះអ្នកទោសនៅស-២១ រួមគ្នា ដែលបានធ្វើឡើងដោយខាងការិយាល័យសហព្រះរាជអាជ្ញាយើងរកឃើញថា យ៉ាងហោចណាស់ក៏មានប្រជាជនចំនួន៨៥៥ ត្រូវបានគេបោសសម្អាតពីកងពល៣១០ ពីកងពលរបស់កម្ពុជាប្រជាធិបតេយ្យ ។

តារាងនេះ គឺបង្ហាញអំពីការចាប់ខ្លួនដោយស-២១ ពីកងពល៣១០ នៅតាមអំឡុងពេលវេលាតាមរយៈខែនីមួយៗ ។ តារាងនេះក៏មានការបង្ហាញផងដែរថា ការបោសសម្អាតនៅក្នុងកងពល៣១០ នោះបានកើតមានឡើងយ៉ាងពេញលេញកាលពីខែធ្នូ ឆ្នាំ៧៦ ហើយបានបន្តរហូតដោយអត្រាកម្រិតខ្ពស់រហូតដល់ពេញឆ្នាំ៧៧ នេះ ។

ឥឡូវហ្នឹងខ្ញុំចង់ធ្វើការបង្ហាញនូវតារាង*ក្រាហ្វ*ទីពីរ ដែលអាស្រ័យទៅលើការងាររបស់ខាងការិយាល័យសហព្រះរាជអាជ្ញាផងដែរ ទាក់ទងទៅនឹងបញ្ជីរួមនៃបញ្ជីអ្នកទោសរបស់ស-២១ ដែលជាតារាងក្នុងការប្រៀបធៀបការធ្វើការចាប់ខ្លួនរបស់ ស-២១ ពីកងពល៥០២ និងកងពល៧០៣ ។

**ស៖** ខ្ញុំចង់ឲ្យលោកពិនិត្យមើលតារាងទីមួយ តើដើម្បីឲ្យភាគីគ្រប់គ្នាដើម្បីធ្វើការពិនិត្យមើលថាតើអាចពិនិត្យមើលបានព័ត៌មានលម្អិតដែរឬទេ ពីព្រោះអីតារាងនេះ គឺជាតារាងជាភាសាអង់គ្លេស ។ ដូច្នេះ ខ្ញុំចង់ឲ្យភាគីពាក់ព័ន្ធនានាធ្វើការពិនិត្យមើលតារាងនេះឲ្យបានជាក់លាក់ច្បាស់លាស់ ។

សូមអរគុណ។ ឥឡូវនេះគឺថា យើងអាចពិនិត្យមើលតារាងទីពីរបាន ។

**ឆ៖** សូមអរគុណលោកស្រីចៅក្រម ។ តារាងទីពីរនេះ គឺជាការប្រៀបធៀបនៃការចាប់ខ្លួនរបស់ស-២១ ពីកងពល៥០២ និងពីកងពល៧០៣ ។ កាលវិភាគរបស់យើងបានស្នើឡើងថា យ៉ាងហោច

ណាស់ប្រជាជនចំនួន២៩៩នាក់ ត្រូវបានគេបោសសម្អាតពីកងពល៥០២ នៅក្នុងប្រតិបត្តិការដែលចាប់ផ្តើមឡើងក្នុងខែមិថុនា ឆ្នាំ៧៦ រហូតប្រហែលជាពេញរយៈពេលមួយឆ្នាំ ។ យ៉ាងហោចណាស់ប្រជាជនចំនួន៤០៦នាក់ ត្រូវបានធ្វើការបោសសម្អាតពីកងពល៧០៣ នៅក្នុងប្រតិបត្តិការដែលបានកើតឡើងចំនួនខ្ពស់នៅក្នុងខែសីហា ឆ្នាំ៧៧ ហើយបានកើតឡើងខ្ពស់ម្តងទៀត តួលេខនេះគឺនៅក្នុងខែ៤ ឆ្នាំ៧៨ ។ ទោះបីជាខ្ញុំមិនបានយកតារាងមួយទៀត តារាងពីកងពលផ្សេងៗទៀតដែលទាក់ទងទៅនឹងកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានគេបោសសម្អាតក្នុងលក្ខណៈទ្រង់ទ្រាយធំក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ ។

ជាឧទាហរណ៍ យ៉ាងហោចណាស់ក៏មានមនុស្សចំនួន៤៦៧នាក់ត្រូវបានបោសសម្អាតពីកងពល៤៥០ ដែរ ។ យ៉ាងហោចណាស់ គឺមនុស្សចំនួន២៤៩នាក់ ត្រូវបានបោសសម្អាតពីខាងអគ្គលេខាធិការ... ។ល ។ *(សុំកែគឺ ចំនួន៣៤៩នាក់)*

**ស៖** សូមអរគុណ ។ តើនេះគឺ ជាការបញ្ចប់អំពីតារាងដែលលោកធ្វើការបង្ហាញ ឬលោកអេតឆេសាន់?

**ឆ៖** បាទ សម្រាប់ពេលនេះ គឺចប់ហើយ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៌៖**

សូមអរគុណ ។ អ៊ីចឹងខាងផ្នែកសោតទស្សន៍ គឺអាចវិលមករកទិដ្ឋភាពរួមទូទៅនៃសាលសវនាការវិញ ។

**ស៖** ក្រោយពីមានការបោសសម្អាត ដូចដែលលោកបានរៀបរាប់នៅក្នុងតារាងរបស់លោក ហើយនិងនៅក្នុងភស្តុតាងរបស់លោកនោះ ថាតើចំនួនភាគច្រើននៃអ្នកដែលត្រូវបានគេចាប់ខ្លួននោះត្រូវបានគេបញ្ជូនទៅទីណា?

[០៩:៣០:៥៧]

**ឆ៖** ការបោសសំអាតរបស់បុគ្គលិកយោធាមួយចំនួន ត្រូវបានគេប្រហារជីវិតនៅក្នុងអង្គភាពផ្ទាល់របស់ខ្លួនតែម្តង ។ អ្នកខ្លះទៀតត្រូវបានគេបញ្ជូនទៅក្នុងកន្លែងធ្វើការងារទ្រង់ទ្រាយធំ ដូចជានៅការដ្ឋានធ្វើវាលយន្តហោះនៅកំពង់ឆ្នាំង ។ យ៉ាងណាមិញចំនួនភាគច្រើនត្រូវបានបញ្ជូនទៅស-២១ ។ ប្រសិនបើខ្ញុំអាចនោះ លោកស្រីចៅក្រម, ខ្ញុំចង់លើកឡើងនូវឧទាហរណ៍មួយ ដែលអាចបើរកឃើញនៅក្នុងកំណត់ហេតុរបស់អគ្គសេនាធិការចុះថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧ ។ ឯកសារនេះ នៅក្នុងភាសា

អង់គ្លេស គឺមានលេខ ERN00183949 រហូតទៅដល់លេខ 00183955 នៅក្នុងទំព័រទី១នៃឯកសារនេះ កងពល៥០២-- លេខាកងពល៥០២ គឺ ស៊ូ ម៉េត បានរាយការណ៍ទៅ សុន សេន ហើយក្នុងរបាយការណ៍របស់គាត់នុ៎ង គឺមាននៅមានអធិប្បាយដូចខាងក្រោមនេះ បាទខ្ញុំសូមស្រង់ឡើងវិញ៖ " ជាការពិតណាស់ដែលបុគ្គលិកមួយចំនួន ដែលត្រូវបានចាប់ពីមុនមកហើយនោះ គឺជាអ្នកដែលជាសត្រូវ គឺអ្នកដែលមានសមាសភាពមិនល្អ ជាង៥០នុ៎ង ត្រូវបានបញ្ជូនទៅស-២១" ។ សូមបញ្ចប់នូវការដកស្រង់ ។

ឯកសារនេះ គឺបង្ហាញអំពីការពិតដែលថា ប្រធានកងពល គឺមិនត្រឹមតែបានដឹងអំពីស-២១ ទេ ហើយនឹងមិនត្រឹមតែបានដឹងពីប្រតិបត្តិការទេ គឺថាបាន ថែមទាំងបញ្ជូនបុគ្គល ឬក៏អ្នកទោសទៅស-២១ ទៀត ។

**ស៖** សូមអរគុណ ។ សម្រាប់សមាជិកយោធាត្រូវបានបញ្ជូនទៅស-២១ តើមានព័ត៌មានអ្វីត្រូវបានបញ្ជូនទៅជាមួយពួកគេទៅ ដើម្បីបង្ហាញអំពីហេតុផលនៃការចាប់ខ្លួនរបស់ពួកគេនោះ?

**ឆ៖** ជាការពិតណាស់ លោកស្រីចៅក្រម ។ ឧទាហរណ៍នៅក្នុងឯកសារមួយ ដែលចុះថ្ងៃទី២ ខែមីថុនា ឆ្នាំ១៩៧៧ ដែលជាលិខិតពីលេខាកងពល៥០២ ស៊ូ ម៉េត ផ្ញើទៅឲ្យជនជាប់ចោទឯកសារនេះ គឺមាននៅក្នុងសំណុំរឿង ដែលមានលេខ ERN00002409 រហូតដល់លេខ 00002409 ឯកសារនេះ បានមានព័ត៌មានដូចខាងក្រោមនេះ "លោកសមមិត្ត ឌុច ជាទីស្រឡាញ់រាប់អាន ខ្ញុំសូមផ្ញើទៅលោក ខ្ញុំបានបញ្ជូនទៅលោក មនុស្សមួយចំនួនដូចខាងក្រោមនេះ៖

ឈ្មោះទីមួយ លោក ចាប លេខារបស់កងវរសេនាតូច ៥០២ ។ ទីពីរ អ៊ុច សមាជិករបស់កងវរសេនាតូច ៥០២ ។ ឈ្មោះទាំងនេះ បានដកចេញពីចម្លើយសារភាពរបស់ សោម ម៉ៅ ហើយនិង ហុក ដែលសុទ្ធតែជាអ្នកនៅក្នុងកងវរសេនាធំ៣១០ ។ សូមបញ្ចប់នៅការដកស្រង់ ។

[០៩:៣៦:១៨]

នៅពេលដែល ម៉េត បាននិយាយថាឈ្មោះអស់ទាំងហ្នឹងត្រូវបានដកស្រង់មកពីចម្លើយសារភាពរបស់ សោម ម៉ៅ ហើយនិងហុក គឺគាត់យោងទៅលើចម្លើយសារភាពពីមុន ដែលអ្នកទាំងនោះបានធ្វើ ដែលពីរនាក់ គាត់បានបញ្ជូននោះ គឺថាត្រូវបានមានឈ្មោះថា ជាអ្នកផ្សំគំនិត ហើយនេះក៏ជាការបង្ហាញផងដែរនៅវដ្តនៃអ្វី ដែលបានកើតឡើងនៅស-២១ ទាក់ទងទៅនឹងអ្នកទោស ដែលត្រូវបានគេសួរចម្លើយ ដើម្បីឲ្យឆ្លើយដាក់ឈ្មោះអ្នកដទៃទៀត ។ នោះគឺជាឈ្មោះដែលត្រូវបានគេចាប់ខ្លួន ហើយត្រូវបានគេសួរ

ចម្លើយ ដើម្បីឲ្យបញ្ចេញឈ្មោះអ្នកដទៃទៀត ដូច្នេះជាលំដាប់លំដោយ ។

**ស៖** ខ្ញុំគិតថា គឺថាមានឯកសារយោងនៅក្នុងឯកសាររបស់លោក នៅក្នុងហ្វូតណូតនុំង គឺ285 និង286 នៅក្នុងឯកសារ D1.15 ដែលមានលេខ ERN00146872 ជាភាសាអង់គ្លេស។

**ឆ៖** លោកស្រីចៅក្រមត្រឹមត្រូវហើយ ។

**ស៖** នៅក្នុងដំណើរការស៊ើបអង្កេតរបស់លោក តើលោកមានបានរកឃើញព័ត៌មានអ្វីទាក់ទងទៅនឹងការចាប់ខ្លួនពីក្រសួងរបស់រដ្ឋាភិបាលដែរឬទេ?

**ឆ៖** ជាការពិតណាស់ លោកស្រីចៅក្រម គឺមានការចាប់ខ្លួនទ្រង់ទ្រាយធំនៅក្នុងគ្រប់ក្រសួងរបស់រដ្ឋ ។ រដ្ឋមន្ត្រីមួយចំនួនបានធ្វើការរអ៊ូរទាំអំពីភាពលំបាកក្នុងការធ្វើភារកិច្ចរបស់ខ្លួន ពីព្រោះមនុស្សបុគ្គលិកជាច្រើនពីក្រសួងរបស់ខ្លួននោះ ត្រូវបានខាងផ្នែកសន្តិសុខចាប់ខ្លួន ។

**ស៖** តើលោកមានឧទាហរណ៍ជាក់លាក់ណាមួយទេ ទាក់ទងទៅនឹងក្រសួងជាក់លាក់ណាមួយដែលលោកអាចលើកមកបង្ហាញប្រាប់ពួកយើង អំពីព័ត៌មានទាំងនេះ?

**ឆ៖** ខ្ញុំមិនមានឯកសារ ដែលខ្ញុំមាននៅជាមួយខ្ញុំនោះទេ ពេលនេះខ្ញុំអត់មានឯកសារនៅក្នុងដៃដើម្បីបង្ហាញនោះទេ ប៉ុន្តែនៅក្នុងចម្លើយសារភាពរបស់ស-២១ របស់មេដឹកនាំតាមក្រសួងនានា ដូចជាក្រសួងពាណិជ្ជកម្មជាដើម គឺថា យើងអាចរកឃើញអំពីការបង្ហាញអំពីចំណុចដែលខ្ញុំទើបតែលើកបានឡើងអំម្បាញ់មិញនេះ ។

[០៩:៣៩:៤១]

យ៉ាងណាមិញ នៅក្នុងការវិភាគរបស់យើងអំពីបញ្ជីឈ្មោះអ្នកទោសរួមគ្នានៅស-២១នោះសំណុំរឿងឯកសារដែលមានលេខ D55 ដែលខ្ញុំបានលើកឡើងកាលពីពេលមុននេះ យើងបានរកឃើញថាឧទាហរណ៍ យ៉ាងហោចណាស់មនុស្ស៥៣២ នាក់ត្រូវបានចាប់ខ្លួន ពីក្រសួងកិច្ចការសាធារណ: ហើយត្រូវបានបញ្ជូនទៅស-២១ ។ នេះជាការបង្ហាញអំពីចំនួន ដែលជាចំនួន៥០ភាគរយនៃកងកម្លាំងទាំងអស់នៅក្នុងក្រសួង ។ យ៉ាងហោចណាស់ មនុស្សចំនួន៣៨៦នាក់ មកពីក្រសួងពាណិជ្ជកម្មត្រូវបានចាប់ខ្លួនហើយបញ្ជូនទៅស-២១ ។ យ៉ាងហោចណាស់ មនុស្ស២៦៨នាក់ត្រូវបានចាប់ខ្លួនពីក្រសួងថាមពលហើយបញ្ជូនទៅស-២១ ។ យ៉ាងហោចណាស់ មនុស្ស២៥១នាក់ ត្រូវបានចាប់ខ្លួនពីក្រសួង-- ស្ថានីយ៍រថភ្លើង ហើយបញ្ជូនទៅស-២១។ល។ ហើយការបោសសំអាតនុំង មានលក្ខណៈទូលំទូលាយសម្រាប់ក្រសួងទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងនៅពេលនេះអាចជាប្រយោជន៍ណាស់ ប្រសិនបើជាលោកអាចផ្តល់លេខយោងERN ទៅនឹងឯកសារ D55 ដែលជាបញ្ជីអ្នកទោសរួម ហើយខ្ញុំមានលេខERN ជាភាសាខ្មែរទេ តើលេខERN00172349 រហូតដល់លេខ00017237។

**ឆ៖** លោកស្រីចៅក្រម ខ្ញុំមានលេខERN ជាភាសាអង់គ្លេសទាក់ទងទៅនឹងឯកសារនេះ ។

**ស៖** អ៊ីចឹងលោកបានផ្តល់ហើយមែនទេ?

**ឆ៖** បាទ,មែនហើយ ។

**ស៖** មានន័យថាគឺលេខ00172353 និងលេខ រហូតដល់លេខ00172255 ។ តើលោកអាចប្រាប់យើងយើងខ្ញុំដែរឬទេ ថាតើពីប្រភពណាខ្លះដែលថា ថាតើស-២១ ទទួលអ្នកទោសពីផ្នែកណាខ្លះ គឺយើងផ្អែកទៅលើយោធា? ជាទូទៅ គឺទទួលពីយោធា ប៉ុន្តែតើមានការទទួលពីប្រភពណាផ្សេងក្រៅពីខាងយោធាដែរឬទេ?

**ឆ៖** លោកស្រីចៅក្រម, ស-២១ ទទួលអ្នកទោសមកពីអង្គភាពគ្រប់ទាំងអស់ និងអង្គការគ្រប់ទាំងអស់នៅក្នុងកម្ពុជាប្រជាធិបតេយ្យនៅទូទាំងប្រទេស ។ ឧទាហរណ៍ដែលគួរឲ្យចាប់អារម្មណ៍មួយ គឺ បានផ្តល់ជូនដោយជនជាប់ចោទខ្លួនឯង ដែលគាត់បានផ្តល់ជូនទៅដល់ចៅក្រមស៊ើបអង្កេត នៅពេលដែលគាត់ផ្តល់ចម្លើយជូនសហចៅក្រមស៊ើបអង្កេត ។

[០៩:៤៣:២១]

នៅក្នុងឧបសម្ព័ន្ធនៃឯកសារសំណុំរឿងលេខD73 ដែលមានលេខERN00209180 រហូតដល់00209182 ជនជាប់ចោទគាត់បានរៀបចំឯកសារមួយដែលមានចំណងជើងថា "បញ្ជីបុគ្គលិកអ្នកទោសដែលបានចាប់ខ្លួន និងបញ្ជូនទៅស-២១" ។ នៅក្នុងបញ្ជីនេះ គឺមានឈ្មោះកម្មាភិបាល៤២នាក់ពីមន្ទីរសន្តិសុខទូទាំងប្រទេស ដែលគាត់ក្រោយមកជាជនរងគ្រោះនៅស-២១ ។ ប្រសិនបើអនុញ្ញាតពីតុលាការ ខ្ញុំនឹងផ្តល់ឧទាហរណ៍បន្ថែមមួយទៀតស្របគ្នាទៅនឹងចំណុចនេះដើម្បីបង្ហាញទៅលើករណីនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ចាស សូមធ្វើការផ្តល់ជូនការលើកឧទាហរណ៍នេះ ។

**លោក ក្រេក អេតឆេសាន់៖**

នៅក្នុងសំណុំរឿង លោកស្រីចៅក្រម នឹងឃើញចម្លើយសារភាពនៅក្នុងស-២១ ដែលទាក់ទង

ទៅនឹង កែវ មាស ដែលហៅថា អាចារ្យ កង ។ កែវ មាស គឺជាអ្នកបដិវត្តន៍ជាន់ខ្ពស់ ហើយគាត់ជាសមាជិកដើមរបស់គណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជានៅក្នុងឆ្នាំ១៩៦០ ។ ចម្លើយសារភាពរបស់គាត់ដែលមានលេខ ERN00226729 ដល់លេខ 00226773 នេះគឺជាលេខ ERN ជាភាសាខ្មែរ ។ ហើយចម្លើយសារភាពលេខERN ជាភាសាអង់គ្លេស គឺមានលេខ ERN00284015 ដល់លេខ00284019 ។ ហើយលេខ ERN ជាភាសាបារាំងនៃឯកសារនេះ គឺលេខ ERN00294500 ដល់លេខ 00294504 ។ លេខសំណុំរឿងគឺ E5/2.21 នៅក្នុងចម្លើយសារភាពមួយនេះ យើងឃើញមានចំណារលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ ដែលនៅក្នុងនោះគឺមានការរៀបរាប់អំពីការទស្សនកិច្ចមន្ទីរ៩៩ ដែលមានឈរជើងនៅក្នុងខេត្តកំពង់ស្ពឺ ។ នៅក្នុងចំណារនោះ ជនជាប់ចោទបានលើកឡើងថា គាត់បានជួប កែង កែប ហៅ កន នៅមន្ទីរ៩៩ ហើយធ្វើការរិះគន់ចំពោះអំពើល្មើសមួយចំនួនរបស់បុគ្គលនោះ ។

នៅក្នុងចំណារនោះ ដែលជាចំណាររបស់ជនជាប់ចោទគឺ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៧៦ ។ ដប់ប្រាំមួយថ្ងៃក្រោយមក កាំង ហ្គិច ហៅ កង គឺត្រូវបានចាប់ខ្លួន ហើយសរសេរចម្លើយសារភាពរបស់គាត់នៅស-២១ ។ នៅក្នុងសំណុំរឿងនោះផងដែរ លោក លោកស្រីចៅក្រម នឹងឃើញរបាយ-ការណ៍ ដែលសរសេរដោយជនជាប់ចោទ គឺចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៧៧ ដែលមានចំណងជើងថា ឈ្មោះរបស់បុគ្គលដែលត្រូវបានចង្អុលដាក់ដោយ ចាប ណម ឯកសារនេះ គឺនៅក្នុងសំណុំរឿង ដែលមានលេខ ERN00170595 រហូតដល់ 00170601 ។ នេះគឺជាឯកសារលេខ ERN ជាភាសាខ្មែរ ។

[០៩:៥០:០៤]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោក លោកស្រីចៅក្រមជាទីគោរព!

ខ្ញុំមានបញ្ហាមួយចំនួន គឺយើងទទួលឮថា លោក ក្រេក អេតឆេសាន់ នឹងផ្តល់សក្ខីកម្ម ហើយប្រសិនបើខ្ញុំមើលទៅលើដីកាកំណត់ថ្ងៃសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងគឺលេខ E51 ។

ខ្ញុំសូមដកស្រង់នូវសម្តី “បន្ទាប់ពីព័ត៌មានដែលផ្តល់ជូនដោយសហព្រះរាជអាជ្ញា អង្គជំនុំជម្រះនឹងកោះអញ្ជើញលោក ក្រេក អេតឆេសាន់ មកផ្តល់សក្ខីកម្ម នៅក្នុងពេលសវនាការលើរចនាសម្ព័ន្ធយោធារបស់កម្ពុជាប្រជាធិបតេយ្យ និងលើបញ្ហានយោបាយ និងរចនាសម្ព័ន្ធនយោបាយរបស់ខ្មែរក្រហម បណ្តាញទំនាក់ទំនងគោលនយោបាយរបស់របបនេះ ហើយនិងគោលនយោបាយ និងមនោគមវិជ្ជារបស់ខ្មែរក្រហម” ។ ខ្ញុំសូមបិទសម្តីដកស្រង់ ។

បន្ទាប់ពីខាងសហព្រះរាជអាជ្ញាបានបញ្ជូនឯកសាររបស់យើង ទាក់ទងទៅនឹងរបាយការណ៍ដែលផ្តល់ជូនរៀបចំឡើងដោយ លោក ក្រេក អេតឆេសាន់ គឺមានការបកប្រែបារាំងនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ។ របាយការណ៍នោះ គឺទាក់ទងទៅនឹងបញ្ហាដែលបានផ្ទុះបញ្ចាំង និងបង្ហាញដូចនៅក្នុងរបាយការណ៍ ប៉ុន្តែខ្ញុំសង្កេតឃើញថា នៅពេលនេះ លោក ក្រេក អេតឆេសាន់ គឺគាត់ទុកចោលរបាយ-ការណ៍នេះ ហើយគាត់ធ្វើការវិភាគទៅលើសំណុំរឿងរបស់សហចៅក្រមស៊ើបអង្កេតទៅវិញ ដែលចំណុចនេះគឺវាមិនពាក់ព័ន្ធទៅក្នុងនីតិវិធីរបស់យើង ។ ហើយចំណុចដែលសំខាន់នោះ គឺគាត់ធ្វើការលើកឡើងអំពីស-២១ ហើយនៅក្នុងរបាយការណ៍ ដែលខ្ញុំលើកឡើងមុននេះ អម្បាញ់មិញនេះ គឺមិនមានការលើកឡើងច្រើនអំពីស-២១ នោះទេ ប៉ុន្តែមានការពិភាក្សាអំពីអង្គការចាត់តាំងទូទៅរបស់របបនោះ ។ ប៉ុន្តែ នៅពេលនេះគឺខ្ញុំខាងការពារក្តី ចង់បញ្ជាក់ថា ដើម្បីធ្វើការរៀបចំថាតើលោក អេតឆេសាន់ ហ្នឹងនឹងនិយាយអំពីអ្វី? ហើយមេធាវីការពារក្តីមិនត្រូវទទួលព័ត៌មានថា ប្រធានបទនេះគឺវាទាក់ទងទៅនឹងរបាយការណ៍ ប៉ុន្តែ បន្ទាប់មកគឺគាត់នឹងបានផ្តល់សក្ខីកម្មទៅលើចំណុចផ្សេងទៅវិញ ។

ហើយគឺមានការស្នើសុំឱ្យអ្នកជំនាញនេះ ធ្វើការផ្តល់យោបល់ទៅលើការងាររបស់សហចៅក្រមស៊ើបអង្កេតនៅពេលនេះ ។

លោក លោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតឱ្យលោក លោកស្រីចៅក្រមគួរតែត្រឡប់ទៅអង្គហេតុដែលដូចមានចែង និងនៅក្នុងដីការបស់លោក លោកស្រីចៅក្រមវិញ ។

[០៩:៥៣:៥០]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

តើខាងសហព្រះរាជអាជ្ញាមានការចង់លើកយោបល់អីផ្សេងដែរឬទេ?

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអរគុណ លោកស្រីចៅក្រម ។ ខ្ញុំសូមរំឭកមេធាវីការពារក្តី និងលោក លោកស្រីចៅក្រម បញ្ហាចោទ ដែលសួរឡើងដោយ ខាងលោក លោកស្រីចៅក្រម គឺជាសំណួរ ហើយការលើកឡើងរបស់មេធាវីការពារក្តី គឺមិនសមស្របក្នុងការនិយាយដូច្នេះទេ ដោយសារតែយើងឃើញទៅលើជំនាញរបស់គាត់ និងរបាយការណ៍ ហើយនិងពេលវេលាដែលសមស្របសម្រាប់សវនាការ ។ ហើយគឺវាអាស្រ័យទៅលើលោកស្រីចៅក្រម ដែលធ្វើការកំណត់សំណួរទាក់ទងទៅនឹងស-២១ ដោយជាក់លាក់ ។ ហើយនៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ខ្ញុំគិតថា វាជាការតាំងសំណួរដ៏សមស្របរបស់អង្គ

សវនាការចំពោះសាក្សី ចំពោះអ្នកជំនាញមួយនេះ ។ ហើយប្រសិនបើមេធាវីការពារក្តីលើកឡើងអំពីបញ្ហាទាក់ទងទៅនឹងស-២១ នេះ បញ្ហានេះគឺជាជំនាញរបស់គាត់ ដែលគាត់សិក្សាអំពីខ្មែរក្រហម ។ ហើយក្នុងរយៈពេលបីឆ្នាំក្រោយនេះ គឺទាក់ទងទៅនឹងស-២១ ។ ហើយវាមិនមែនជាភាពមិនត្រឹមត្រូវចំពោះអង្គសវនាការនោះទេ ហើយខ្ញុំសូមដាក់ជូនថា សំណួររបស់លោក លោកស្រីចៅក្រម គឺសមស្របទៅលើករណីនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ថាតើមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណីចង់លើកឡើងយោបល់ដែរឬទេ?

**លោក អាឡាំង វែនណឺ៖**

យើងមានការសន្និដ្ឋាន ដូចខាងសហព្រះរាជអាជ្ញា ហើយយើងមិនមានអ្វីឆ្លើយតបបន្ថែមទៅលើចំណុចនេះទេ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សឺនស្តី៖**

យើងគាំទ្រសេចក្តីសន្និដ្ឋានរបស់ខាងសហព្រះរាជអាជ្ញា ។

[០៩:៥៦:០៥]

**លោកស្រី វ៉ាបេសាន់ជ្រាតាណា៖**

យើងសូមគាំទ្រលើសេចក្តីសង្កេតរបស់សហព្រះរាជអាជ្ញា ។

ខ្ញុំសូមលើកយោបល់មួយចំពោះការជំទាស់របស់ខាងមេធាវីការពារក្តីលោក ហ្វ្រង់ស្វ័រ រូ ។ នៅក្នុងការសិក្សាទៅលើរចនាសម្ព័ន្ធរបស់របបមួយនេះ យើងបានធ្វើការពិភាក្សាទៅលើរចនាសម្ព័ន្ធយោធានិងប្រព័ន្ធយោធា ហើយនិងរចនាសម្ព័ន្ធរដ្ឋាភិបាល ហើយយើងហាក់ដូចជាយល់ឃើញថា នៅក្នុងរចនាសម្ព័ន្ធនីមួយៗនោះ គឺអត់មានអាទិភាពទាក់ទងទៅនឹងស-២១ ។ ហើយគឺថា វាជាបញ្ហាជាក់ស្តែងមួយគឺបញ្ហានេះ វាពាក់ព័ន្ធទៅនឹងស-២១ ដែលយើងបានពិភាក្សានៅក្នុងក្របខណ្ឌនៅពេលនេះ ហើយវាទាក់ទងទៅនឹងការពន្យល់របស់អ្នកជំនាញ ក្រេក អេតធេសាន់ ដោយសារតែស-២១ គឺជាឧបករណ៍មួយដែលមានឥទ្ធិពលនៅក្នុងអង្គការរចនាសម្ព័ន្ធផ្សេងៗទៀតនៅក្នុងរដ្ឋនិងរបបនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

តើលោក រូ មានការចង់ឆ្លើយតបដែរឬទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព!

នេះគឺជាឯកសាររបាយការណ៍ ដែលរៀបចំបានយ៉ាងល្អ ហើយវាមានផលប្រយោជន៍សម្រាប់នីតិវិធីរបស់យើង ។ ហើយលោក ក្រេក អេតឆេសាន់ ទាក់ទងទៅនឹងសក្ខីកម្មរបស់គាត់ គឺគាត់សរសេររបាយការណ៍ជើងទំព័រយោងចំនួន៣៥៦ ហើយវាច្រើនណាស់ចំពោះលេខជើងទំព័រនេះ ហើយខ្ញុំសូមកត់សម្គាល់ថា ជាជាងការកម្រិត ការផ្ដល់យោបល់របស់គាត់ទាក់ទងទៅនឹងលេខយោងចំនួន៣៥៦ នោះគឺអ្នក-- ៥៥ គឺអ្នកជំនាញ គឺគាត់បានមកធ្វើការពិភាក្សាទៅលើឯកសារ ដែលឯកសារនេះយើងត្រូវការពិភាក្សាទាក់ទងទៅនឹងអង្គហេតុដែលបានចែងនៅក្នុងដីការបស់អង្គសវនាការ ហើយខ្ញុំគិតថាចំណុចនេះ គឺវាមិនមានភាពយុត្តិធម៌ចំពោះខាងការពារក្ដី ។ ប្រសិនបើខាងលោក ក្រេក អេតឆេសាន់ គឺគាត់រៀបចំក្នុងការលើកឡើងអំពីឯកសារ ពីខាងសហចៅក្រមស៊ើបអង្កេត គឺវាទាក់ទងទៅនឹងរឿងក្ដីដែលមាននៅក្នុងបញ្ជីដូចដែលខ្ញុំទើបតែបានលើកឡើង ។ ខ្ញុំមានការសោកស្ដាយ នេះមិនមែនជាអង្គហេតុដែលមានចែង ហើយយើងមានគោលបំណងចង់ពិភាក្សា តាំងពីដំបូងនៅក្នុងករណីនេះទេ ។ ខ្ញុំឃើញមានភាពផ្ទុយគ្នានៅក្នុងគុណសម្បត្តិការងាររបស់លោក ក្រេក អេតឆេសាន់ ប៉ុន្តែលោក ក្រេក អេតឆេសាន់ មិនមែនមកទីនេះ នៅពេលនេះដើម្បីផ្ដល់យោបល់ទៅលើកិច្ចការរបស់សហចៅក្រមស៊ើបអង្កេតនោះទេ ។ គឺយើងឃើញថា របាយការណ៍របស់សហចៅក្រមស៊ើបអង្កេតមានឯកសារជាច្រើន ហើយវាមិនមានភាពសមស្របក្នុងការផ្ដល់យោបល់ទៅលើកិច្ចការនោះទេ ។ ដូច្នេះ ហើយគឺនៅពេលនេះ គឺយើងធ្វើការពិភាក្សាទៅលើរបាយការណ៍ ហើយដែលយើងមានការចុះលេខ D2/15 ទោះបីជាយើងទទួលឯកសាររបាយការណ៍នេះ ទើបតែទទួលបានក៏ដោយ ។

[១០:០០:០៥]

ហើយខ្ញុំសូមអង្គសវនាការគួរតែផ្ដោតទៅលើរបាយការណ៍មួយនេះ ហើយសហព្រះរាជអាជ្ញាគួរតែជម្រាបអង្គសវនាការថា ខ្លួនចង់សួរសំណួរទៅលើអង្គហេតុផ្សេងៗ ប៉ុន្តែ នៅក្នុងចំណុចបួននៃដីកាគឺអង្គសវនាការបានចែងថា លោក ក្រេក អេតឆេសាន់ នឹងផ្ដល់សក្ខីកម្ម ហើយគឺលោកសហព្រះរាជអាជ្ញាគួរតែ-- នៅពេលដែលគាត់ផ្ដល់យោបល់ដូច្នេះ ថាតើយើងគួរតែធ្វើយ៉ាងម៉េចទៅលើបញ្ហានេះ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចង់ធ្វើការបញ្ជាក់ តំណាងឲ្យជនអ្នកជំនាញ មុននឹងមានការជំទាស់នេះ គាត់បានលើកឡើង អំពីចម្លើយសារភាពរបស់ ចាប ណម ហើយគាត់បានផ្តល់នូវលេខ ERN មួយចំនួន ។ ហើយខ្ញុំចង់ដឹង ថាតើចម្លើយសារភាពហ្នឹង គឺមានដាក់បញ្ចូលនៅក្នុងកំណត់សម្គាល់ជា *ហ្វូតណូត* ឬមួយក៏ត្រូវបាន បញ្ចូលនៅក្នុងរបាយការណ៍របស់គាត់ដែរឬទេ? ហើយខ្ញុំចង់ដឹង ថាតើជាការពិតដែរឬទេ ដែលមានតែ អត្ថបទជាភាសាខ្មែរ និងភាសាអង់គ្លេសទេ ហើយមិនមែនជាអត្ថបទជាភាសាបារាំងសម្រាប់ឯកសារ នេះទេ?

**លោក ក្រេក អេតធេសាន់៖**

លោក លោកស្រីចៅក្រម! ខ្ញុំជឿថាជាការត្រឹមត្រូវ ប្រហែលជាមិនមានការបកប្រែជាភាសា បារាំងនៅឡើយទេ នូវចម្លើយសារភាពរបស់ ចាប ណម នៅស-២១នោះ ។

បាទ, ខ្ញុំនឹងពិនិត្យមើលឯកសារមួយចំនួន ហើយនឹងពិនិត្យមើល-- ។ បាទ, ខ្ញុំជឿថាចម្លើយ សារភាពនៅ ស-២១ របស់ ចាប ណម នោះ មិនត្រូវបានចញ្ចូលនៅក្នុងរបាការណ៍របស់យើងទេ អំពី ស្តីអំពី ការបង្ហាញពីរចនាសម្ព័ន្ធទូទៅ របស់កម្ពុជាប្រជាធិបតេយ្យនោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

[១០:០៣:៣២]

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំនឹងមិនស៊ីពេលយូរទេ ខ្ញុំគ្រាន់តែធ្វើការកែសម្រួលបន្តិចទៅ លើចំណុចចំនួនពីរ ។ ឯកសារទាំងអស់នេះ ដែលយើងបានលើកឡើង ដែលលោក អេតធេសាន់ បាន លើកឡើង គឺជាឯកសារដែលមាននៅក្នុងសំណុំរឿង ហើយគឺថាយើងមិនអាចនិយាយថាជាឯកសារថ្មី នោះទេ ។ ហើយចំណុចទីពីរ ដូចថាយើងទាំងអស់បានដឹងហើយថា នៅក្នុងប្រព័ន្ធស៊ីវិលឡសាក្សី ត្រូវបានកោះឡើង កោះហៅដោយតុលាការ ហើយខាងសហព្រះរាជអាជ្ញាមិនបានធ្វើការរៀបចំលោក អេតធេសាន់ ទេ ហើយគាត់ក៏មិនមែនជាសាក្សីរបស់សហព្រះរាជអាជ្ញាដែរ ។ ហើយយើងជាសហព្រះ រាជអាជ្ញាមិនមានការត្រួតត្រាអ្វីទៅលើសំណួរ ដែលខាងចៅក្រមបានសួរទៅលើលោក អេតធេសាន់ នោះទេ ពីព្រោះនេះ គឺជាតួនាទីរបស់លោក លោកស្រីចៅក្រម ក្នុងការសួរសំណួរ ។ បាទ, នេះជាអ្វី

ដែលខ្ញុំចង់លើកនិយាយនៅពេលនេះ ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១០:៣៨]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោក ហ្វ្រង់ស្វ័រ រូ បើខ្ញុំចង់ធ្វើការបញ្ជាក់ឲ្យច្បាស់ ឯកសារដែលលោកបានធ្វើជំទាស់ហ្នឹង លោកអាចបញ្ជាក់ពីលេខយោងឲ្យបានជាក់លាក់បានទេ? ពីព្រោះលោកបាននិយាយថា គឺជាកិច្ចការរបស់ខាងសហចៅក្រមស៊ើបអង្កេត ហើយនិងឯកសារផ្សេងៗ ។ តើលោកអាចបញ្ជាក់ពីឯកសារច្បាស់លាស់ ដែលលោកធ្វើការជំទាស់នោះដែរឬទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ ។ សាក្សីដែលជាអ្នកជំនាញ បានយោងទៅលើឯកសាររបស់លោក ឌុច នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ទាក់ទងទៅនឹងចំណុចជាក់លាក់មួយចំនួន ដែលមិនបានបញ្ចូលនៅក្នុងរបាយការណ៍របស់គាត់ទេ ។ ហើយនេះគឺជាចំណុច ដែលអ្នកជំនាញបានផ្តល់-- បាននិយាយប្រាប់យើងអំពីឯកសារ ដែលបានបញ្ចូលនៅដំណើរការនីតិវិធី ។ ហើយបើសិនជាខ្ញុំយល់ដឹងត្រឹមត្រូវនោះ គឺបន្ទាប់ពីរបាយការណ៍នោះត្រូវបានបង្កើតរួចទៅហើយ ។

[១០:១២:០២]

ដូច្នេះ នេះអាចគឺជាការទទួលយកបាន ក៏ប៉ុន្តែ ភាពចាំបាច់សម្រាប់ឲ្យខាងសហព្រះរាជអាជ្ញា នៅពេលដែលពួកគេធ្វើសំណើក្នុងការសម្ភាសន៍ជាមួយលោក អេតឆេសាន់ ។ ហើយនៅពេលដែលពួកគេបានបញ្ចូលនៅក្នុងរបស់គាត់ គឺជាការចាំបាច់ណាស់សម្រាប់ឲ្យខាងសហព្រះរាជអាជ្ញាធ្វើការផ្តល់ព័ត៌មានដល់អង្គជំនុំជម្រះ ហើយនិងខាងមេធាវីការពារក្តី ដែលថាគាត់នឹងត្រូវផ្តល់សក្ខីកម្ម មិនត្រឹមតែទៅលើចម្លើយ ចំណុចរបាយការណ៍របស់គាត់ទេ ប៉ុន្តែគឺទៅលើកាលវិភាគរបស់គាត់ផងដែរទៅលើចម្លើយរបស់ ឌុច ជាមួយនឹងសហចៅក្រមស៊ើបអង្កេត ប៉ុន្តែនេះមិនមែនជាអ្វីដែលបានកើតឡើងនោះទេ ។

ដូច្នេះ បញ្ហាដែលលោក អេតឆេសាន់ បានកោះហៅឲ្យមកនិយាយនោះ គឺទាក់ទងទៅនឹងរចនាសម្ព័ន្ធយោធា នៃរបបកម្ពុជាប្រជាធិបតេយ្យ និងរចនាសម្ព័ន្ធនយោបាយរបស់របបខ្មែរក្រហម ហើយនិងអង្គការចាត់តាំង នៃបណ្តាញព័ត៌មានធ្វើការនៅក្នុងរបបនោះ ហើយនិងអំពីនយោបាយ និងមនោគម

វិជ្ជា ។ ហើយនិងនៅក្នុងរបាយការណ៍របស់គាត់គឺថា មានការនិយាយតិចតួចណាស់អំពីស-២១ ដែលជាផ្នែកមួយនៃរបាយការណ៍ទាំងមូលនោះ ។ ក៏ប៉ុន្តែមិនមានការបញ្ជាក់វិភាគច្បាស់លាស់អំពីស-២១ទេ ប៉ុន្តែនៅពេលនេះសាក្សីដែលជាអ្នកជំនាញនេះបានផ្តល់អំពីការវិភាគជាក់លាក់អំពីស-២១ ។ ដូច្នេះគឺថា យើងបាននិយាយហួសពីបរិបទ ដែលគាត់ត្រូវនិយាយនោះរួចទៅហើយ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំបានដឹងអំពីចម្លើយជំទាស់របស់លោកហើយ ប៉ុន្តែ ខ្ញុំចង់ដឹងថា តើឯកសារណាដែលលោកធ្វើការជំទាស់នោះ? មានន័យថា ទៅជា-- គឺជាឯកសារភ្ជាប់នៅក្នុងរបាយការណ៍ នៅក្នុងសំណុំរឿងគឺលេខ D23 នោះឬ? បើសិនត្រឹមខ្ញុំយល់ ពីព្រោះនេះឯកសារនេះ គឺមានការបកប្រែជាភាសាបារាំង ឬមួយក៏ឯកសារផ្សេងទៀត ដែលមិនមានការបកប្រែជាភាសាបារាំងនោះ?

**លោក ហ្រ្វង់ស្វ័រ រូ៖**

បាទ, ជាការត្រឹមត្រូវណាស់ ។ តាមពិតឯកសារ D73 គឺជាឯកសាររបស់ខាងសហចៅក្រមស៊ើបអង្កេតដែលបានដាក់បញ្ចូល ហើយឯកសារនេះមិនទាន់ត្រូវបានបកប្រែជាភាសាបារាំងទេ ហើយក៏នៅមានឯកសារផ្សេងទៀតដែរ ដូចជាឯកសារចុងក្រោយដែលលោក អេតធេសាន់ បាននិយាយគឺទាក់ទងទៅនឹងសមាសភាពរបស់ ចាន់ ម៉ម គឺថាមិនមានការបកប្រែជាភាសាជាភា សាបារាំងទេ ។

[១០:១៥:០៦]

ហើយខ្ញុំក៏សូមឲ្យលោក លោកស្រីចៅក្រមហ្នឹង យកចិត្តទុកដាក់ផងដែរ ទៅលើឯកសារផ្សេងៗដែលមានជាលេខ *អ៊ីនឌិច* គឺ E5 នៅក្នុងចំណោមឯកសារទាំងនោះ ដែលជាចម្លើយសារភាពរបស់អាចារ្យ កង ហើយខ្ញុំចង់រំឭកដល់លោកស្រីផងដែរ ថាឯកសារលេខ E5 នេះ គឺត្រូវបានបញ្ចូលនៅក្នុងចំណោមឯកសារផ្សេងៗទៀតដែលខាងសហចៅក្រមស៊ើបអង្កេតបានបញ្ចូលបន្ទាប់ពីការស៊ើបអង្កេតបានបញ្ចប់រួចហើយនោះ ។ ហើយខ្ញុំបានធ្វើការតវ៉ាចំពោះចំណុចនេះ ពីព្រោះខ្ញុំយល់ថាជាការមួយដែលគួរសោកស្តាយណាស់ គឺថាឯកសារហ្នឹងមិនត្រូវបានបញ្ចូលនៅក្នុងដំណាក់កាលស៊ើបអង្កេត ហើយខ្ញុំបានធ្វើការកត់សម្គាល់ផងដែរ លោក អេតធេសាន់ បានប្រើប្រាស់នៅថ្ងៃនេះនូវឯកសារ ដែលកើតមានឡើងក្រោយបន្ទាប់ពីគាត់បានធ្វើរបាយការណ៍របស់គាត់ផងហើយ ។

ដូច្នេះ ខ្ញុំយល់ថា ជាការចាំបាច់ណាស់ដែលខាងសហព្រះរាជអាជ្ញាគួរតែធ្វើការផ្តល់ព័ត៌មានជាដំណឹងដល់ខាងៗការិយាល័យ ខាងកន្លែងមេធាវីការពារក្តីរបស់យើង ពីព្រោះមិនមែនជាការត្រឹមត្រូវទេ

ដែលថានឹងនិយាយអំពីរបាយការណ៍របស់គាត់ ហើយទាក់ទងទៅនឹងឯកសារនោះ ។ ហើយនៅព្រឹកមិញនេះ គឺថាមានឯកសារដែលថាជាឯកសារថ្មីៗបំផុតនោះ ។ នេះយើងហៅថា មានន័យថា គឺជាការលើកឡើងដែលធ្វើឲ្យ មិនបានឲ្យខាងមេធាវីការពារក្តីបានដឹងឮបន្តិចសោះហើយ ។ ដូច្នេះចំណុចនេះខ្ញុំមិនអាចទទួលយកបានទេ ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ដើម្បីមានសំណួរមួយចំនួនសួរទៅដល់អ្នកជំនាញ និងភាគីដែលពាក់ព័ន្ធដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់អំពីបញ្ហាដែលកើតមានឡើង ដោយមានការជំទាស់ពីមេធាវីការពារក្តីនេះ ។ សូមអញ្ជើញលោកស្រី ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

**ស៖** អរគុណលោកប្រធាន ។អង្គសវនាការចង់ធ្វើការបញ្ជាក់ថា ឯកសារណាដែលខាងការពារក្តីជំទាស់។ ដូច្នេះបណ្ឌិត អេតឆេសាន់ ខ្ញុំនឹងសួរលោក ឲ្យធ្វើការនិយាយសារជាថ្មីចំពោះឯកសារយោងមួយ ចំនួនទាក់ទងទៅនឹងលេខ ERN ដើម្បីឲ្យយើងយល់ច្បាស់ថា ឯកសារណាដែលយើងយោង ។

ឯកសារទី១ គឺឯកសារដែលលោកនិយាយថា វាជាឧបសម្ព័ន្ធចំពោះការសួរចម្លើយរបស់សហចៅក្រមស៊ើបអង្កេតដែលមានលេខD73 ។ នៅក្នុងឧបសម្ព័ន្ធនោះ តាមអ្វីដែលខ្ញុំយល់ យើងឃើញមានការចម្លើយសារភាពរបស់ កែវ មាស ហើយយើងឃើញមានចំណារជាលាយលក្ខណ៍អក្សររបស់ជនជាប់ចោទ តើត្រឹមត្រូវដែរឬទេ?

**លោក ក្រេក អេតឆេសាន់៖**

**ឆ៖** មិនមែនទេ គឺវាមិនត្រឹមត្រូវទេ ។ ឧបសម្ព័ន្ធចំពោះឯកសារលេខ D73 នោះ គឺជាឯកសារដែលរៀបចំដោយជនជាប់ចោទខ្លួនឯង គឺមានចំណងជើងថា “បញ្ជីបុគ្គលិកអ្នកទោសដែលចាប់ខ្លួននៅស-២១” ហើយចម្លើយសារភាពរបស់អាចារ្យ កង ហៅថា កែវ មាស គឺវាមិនពាក់ព័ន្ធទៅនឹងឯកសារមួយនុ៎ងទេ ។

**ស៖** ខ្ញុំនឹងលើកឡើងអំពីឯកសារ D73 ជាមុនដែលជនជាប់ចោទ គាត់បានចារនៅលើឯកសារនោះ គឺមានលេខ ERN00209180 គឺលេខនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** លោកស្រីចៅក្រមកំពុងនិយាយអំពីឯកសារ D73 ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ត្រឹមត្រូវ ។

**លោក ក្រេក អេតធេសាន់៖**

ឯកសារភាគច្រើននៃឯកសារ D73 នេះ លេខ ERN ជាភាសាអង់គ្លេស គឺមានលេខ 00209168 ដល់លេខ00209183 ហើយផ្នែកមួយនៅក្នុងឯកសារនោះ គឺដែលថាជា ឧបសម្ព័ន្ធ ឯកសារនៅក្នុងឧបសម្ព័ន្ធដែលរៀបចំដោយជនជាប់ចោទនោះ គឺមានលេខ00209180 រហូតដល់ 00209182 ។ ហើយប្រសិនបើអង្គសវនាការចង់បាននោះ ខ្ញុំក៏អាចផ្តល់ជូនលេខ ERN ជា ភាសាខ្មែរ និងបារាំងផងដែរ ចំពោះឯកសារនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។

[១០:២៤:១៥]

**លោក ក្រេក អេតធេសាន់៖**

លេខ ERN ជាភាសាបារាំង គឺ 00186308 ដល់លេខ 00186223 ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។

**លោក ក្រេក អេតធេសាន់៖**

លេខ ERN ជាភាសាខ្មែរ គឺ 00186192 ដល់លេខ 00186207 ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។

លោក រូ តើលោកមានការជំទាស់ទៅលើឯកសារមួយនេះដែរឬទេ? ខ្ញុំមិនចាំបាច់ចង់ដឹង លោកមិនបាច់លើកឡើង ហេតុផលរបស់លោកទេ ។ តើលោកមានការជំទាស់ដែរឬទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកស្រីចៅក្រម ។ ចំពោះឯកសារមួយនេះ យើងខ្ញុំគ្មានបញ្ហា និងគ្មានការជំទាស់ទៅលើឯកសារនោះទេ ដោយសារតែវាជាបញ្ជីដែលបង្កើតដោយជនជាប់ចោទខ្លួនឯង ។ ប៉ុន្តែ លោក លោកស្រីចៅក្រម តើលោក លោកស្រីចៅក្រម អាចសួរសំណួរនេះទៅកាន់លោក ក្រេក អេតធេសាន់

បានដែរឬទេ? តើលោក ក្រេក អេតឆេសាន់ បានសរសេររបាយការណ៍លើកដំបូងរបស់លោកនៅពេលណា គឺរបាយការណ៍ដែលយើងកំពុងតែពិភាក្សានៅពេលនេះ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** តើលោក ក្រេក អេឆេសាន់ អាចឆ្លើយបានដែរឬទេ?

**ឆ៖** បាន។ របាយាការណ៍មួយនេះ ដែលមានចំណងជើងថា “ទស្សនៈទានទៃឋានានុក្រម កម្ពុជា ប្រជាធិបតេយ្យ” គឺបានសរសេរ និងបញ្ចប់នៅក្នុងដើមខែកក្កដា ឆ្នាំ២០០៧ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ តើលោកមានយោបល់ទៅលើឯកសារនេះ ឬក៏យ៉ាងម៉េច? ទាក់ទងទៅនឹងឯកសារ D73 ទាក់ទងទៅនឹងការឆ្លើយតបលើឯកសារនេះ តើលោកមានអ្វីចង់លើកឡើង?

[១០:២៧:០២]

**លោក ហ្វ្រង់ស្វ័រ រូ៖**

បាទ, លោកស្រីចៅក្រម! ចំពោះខ្ញុំ វាជាភាពយុត្តិធម៌ ។ ប្រសិនបើលោក អេតឆេសាន់ អាចគួរតែអាចប្រើឯកសារ 73 នោះ ហើយវាជាយុត្តិធម៌ដែលថា វាជារបាយការណ៍ដែលបង្កើតឡើងព្រមគ្នា ដែលគាត់កំពុងតែបង្ហាញជូនអង្គសវនាការ និងភាគី ហើយនៅក្នុងរបាយការណ៍នេះ គាត់គួរតែលើកឡើងអំពី D73 ដែលគាត់យោងផងដែរ ។ ខ្ញុំសូមអភ័យទោស ដោយសារតែបញ្ហានេះវាមិនពាក់ព័ន្ធទៅលើចំណុចនេះទេ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** ឯកសារបន្ទាប់មកទៀត លោក ក្រេក អេឆេសាន់ គឺឯកសារទាក់ទងទៅនឹង កែវ មាស ដែលលោកបានផ្តល់លេខERN ចំនួនបីទាក់ទងទៅនឹងភាសាខ្មែរ, បារាំង និងអង់គ្លេស គឺមានលេខ E5/2.12 ផងដែរ ។ តើត្រឹមត្រូវដែរឬទេ លោក ក្រេក អេឆេសាន់ ?

**ឆ៖** បាទ គឺត្រឹមត្រូវលោកស្រីចៅក្រម ។

**ស៖** ហើយឯកសារនេះវាមានចំណារជាលាយលក្ខណ៍អក្សរ ដែលសរសេរឡើងដោយជនជាប់ចោទ តើមែនដែរឬទេ?

**ឆ៖** ត្រឹមត្រូវ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោក រូ តើលោកចង់ឲ្យខ្ញុំលើកឡើងលេខ ERN ផងដែរឬក៏យ៉ាងម៉េច ? សូមចាំមួយភ្លែត លោកចៅក្រមឡាវ៉ែន៍ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

**ស៖** លោកចង់យោងទៅលើចំណារដែល ឌុច សរសេរនោះតែប៉ុណ្ណោះ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ, លោកចៅក្រម ។ បន្ថែមទៅលើរបាយការណ៍ដែលវាយដោយអង្គុលីលេខរៀបចំដោយជនជាប់ចោទ ហើយបានបញ្ចូលទៅក្នុងចម្លើយសារភាពរបស់ ចាប ណម ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

ឯកសារនេះទំនងហាក់ដូចជា គឺនៅក្នុងបញ្ជីនៃឯកសារដែលសហព្រះរាជអាជ្ញាបានផ្តល់ជូន បីបួនខែមុនបន្ទាប់ពីដំណាក់កាលស៊ើបអង្កេត ។ ហើយនៅក្នុងករណីនេះដែរ ប្រសិនបើលោក អេតឆេសាន់ មានបំណងក្នុងការប្រើឯកសារនោះ វាគួរតែសមស្របសម្រាប់គាត់ ក្នុងការដែលគាត់គួរតែផ្តល់របាយការណ៍បន្ថែម ។ ខ្ញុំសូមអនុញ្ញាតធ្វើការចោទសួរសំណួរមួយ ។ ថាតើបុគ្គលណាគាត់បានបកប្រែឯកសារនេះជាភាសាបារាំង និងអង់គ្លេស? ថាតើបុគ្គលណាជាអ្នកបកប្រែ?

[១០:៣០:៤២]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោក គ្រេក អេតឆេសាន់ តើលោកដឹងទេ?

**លោក គ្រេក អេតឆេសាន់៖**

ខ្ញុំអត់ដឹងទេលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ថាតើលោកការពារក្តីចង់ឲ្យអង្គសវនាការធ្វើការសួរ និងស្រាវជ្រាវជាក់លាក់ទៅលើបញ្ហាចោទដែលលោកលើកឡើងអម្បាញ់មិញនេះ ឬយ៉ាងម៉េច?

**លោក ហ្រ្វង់ស្វ័រ រូ៖**

លោក លោកស្រីចៅក្រមជាទីគោរព! ដោយសារតែយើងមានជួបប្រទះបញ្ហាម្តងទៀតហើយ

ទាក់ទងទៅនឹងការបកប្រែឯកសារបញ្ជីនេះ ក្នុងពេលដែលខ្ញុំសិក្សាទៅលើឯកសារមួយក្នុងចំណោមបញ្ជីនេះ យើងឃើញមានកំហុសមួយធ្ងន់ធ្ងរ ។ អ្នកបកប្រែគឺបានប្រើពាក្យ*ស្មាស* គឺកម្មេច ហើយពាក្យនេះអត់មាននៅក្នុងឯកសារទេ ។ លើកលែងតែខ្ញុំយល់ច្រឡំគឺឯកសារនេះតាមពិតវាដូចតែគ្នាទេ ។ ជាការពិតយើងចង់ដឹងថាតើបុគ្គលមួយណាគាត់ជាអ្នកបកប្រែទៅលើឯកសារដកស្រង់មួយនេះ ដោយសារតែវាជាឯកសារទាក់ទងចម្លើយសារភាព ។ ហើយយើងឃើញមានចម្លើយសារភាព ហើយចម្លើយមួយទៀតនោះគឺមិនមែនបកប្រែជាភាសាបារាំងនិងអង់គ្លេស ។ ហើយ D56 និង D128/25.1 មិនមានការបកប្រែជាភាសាបារាំង គឺឯកសារសារភាពរបស់ ចាប ណម ។

ខ្ញុំគិតថា វាជាភាពសមស្រប គួរតែមានការសរសេរបាយការណ៍បន្ថែមដោយលោក អេត ឆេសាន់ បន្ថែមទៅលើរបាយការណ៍ដែលគាត់ដាក់ជូននេះ ។ គាត់គួរតែសរសេររបាយការណ៍បន្ថែម ។

[១០:៣២:៥៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អាឡិចសាន់ឌឺ បើត៖**

អរគុណលោកប្រធាន ។ ខ្ញុំអាចផ្តល់ជាជំនួយទៅដល់អង្គសវនាការ គឺអត់មានការបកប្រែបារាំងត្រឹមត្រូវ ហើយយើងឃើញមានការបកប្រែជាភាសាអង់គ្លេស ដោយអង្គភាពបកប្រែរបស់ អ.វ.ត.ក ។ ហើយយើងឃើញមានលេខនៅក្រោមជើងទំព័រ ហើយវាមានលេខយោងដើមរបស់អ.វ.ត.ក ។ ខ្ញុំសូមធ្វើការកែតម្រូវចំពោះការពិពណ៌នាទៅលើឯកសារមួយនេះ ។

វាមិនមែនជាចម្លើយសារភាពនោះទេ ។ វាជារបាយការណ៍សង្ខេបពីជនជាប់ចោទ លើករណីចម្លើយសារភាពរបស់ ចាប ណម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៍៖**

យើងបានបំភ្លឺទៅលើករណីជំទាស់របស់ការពារក្តីចំពោះឯកសារយោង ឯកសារនោះហើយ ។ ប៉ុន្តែ បញ្ហាចោទមួយទៀតគឺគួរតែមានការសរសេររបាយការណ៍បន្ថែម ទាក់ទងទៅនឹងរបាយការណ៍ទស្សនទានមុន គឺឯកសារនេះ គឺអ្វីដែលមេធាវីការពារក្តីចង់លើកថា-- លើកទៅលើករណីនេះ ។ ហើយប្រហែលជាលោកប្រធានចង់ធ្វើការផ្អាកសវនាការនេះសិន ដើម្បីធ្វើការពិភាក្សាលើករណីនេះ ឬក៏យ៉ាងម៉េច?

នៅពេលនេះ យើងបានធ្វើការបំភ្លឺលើឯកសារ ហើយនិងការជំទាស់ជាក់លាក់ហើយ ថាតើភាគីផ្សេងៗមានយោបល់បន្ថែមដែរឬទេ? សូមខាងសហព្រះរាជអាជ្ញា ។

**លោក អាឡិចសាន់ឌឺ បេិត៖**

សូមអរគុណ លោក លោកស្រីចៅក្រម ។ ខ្ញុំមិននិយាយសាថ្មីនូវអ្វីដែលខ្ញុំលើកឡើងនោះទេ ។ ហើយឆ្លើយតបទៅនឹងបញ្ហាដែលសាក្សីនេះគួរតែរៀបចំរបាយការណ៍បន្ថែមនោះ ដោយពិចារណាទៅលើរបាយការណ៍របស់គាត់បានសរសេរកាលពីពីរឆ្នាំទៅមិញ ។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់យើង ខ្ញុំគឺវាជាទង្វើករណ៍មិនមានមូលដ្ឋាន ។ ឯកសារទាំងអស់នេះវាមាននៅក្នុងសំណុំរឿង ហើយទទួលយកដោយសវនាការ ។ ហើយឯកសារនៅក្នុងសំណុំរឿង គឺបានបើកឲ្យជនជាប់ចោទ និងមេធាវីការពារក្តីពិនិត្យ ដែលវាមាននៅក្នុងសំណុំរឿងអង្គសវនាការផងដែរ ។

[១០:៣៦:១១]

ដូច្នេះ សេចក្តីសន្និដ្ឋានរបស់ខ្ញុំលើកឡើងមុននេះ លោកបណ្ឌិត អេតធេសាន់ គួរតែអនុញ្ញាតឲ្យឆ្លើយតបទៅនឹងសំណួររបស់អង្គសវនាការ ហើយគាត់គួរតែអនុញ្ញាតឲ្យធ្វើការយោងទៅលើឯកសារដែលគាត់ចង់យោង ។ នេះគឺខ្ញុំគិតថា វាជាគោលការណ៍មួយសម្រាប់អង្គសវនាការ ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ថាតើមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងចង់លោកយោបល់ដែរឬទេ?

**លោក អាឡាំង វ៉ែនណឺ៖**

ខ្ញុំអត់មានយោបល់បន្ថែមទាក់ទងទៅនឹងខ្លឹមសារនោះទេ ។ ហើយខ្ញុំ គឺខ្ញុំមានការយល់ច្រឡំទៅលើចម្លើយសារភាព ចាប ណម ខ្ញុំអត់មានលេខ ERN ជាភាសាអង់គ្លេសនោះទេ ។ ហើយខ្ញុំគួរ ខ្ញុំសូមឲ្យមានការផ្តល់លេខ ERN ជាភាសាអង់គ្លេស ដើម្បីកត់ត្រាក្នុងរបាយការណ៍ឲ្យត្រឹមត្រូវកំណត់ហេតុរបស់សវនាការយើង ។ ថាតើយើងលេខ ERN ដែរឬទេ ជាភាសាអង់គ្លេស?

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន សូមគោរពអង្គជំនុំជម្រះ! ខ្ញុំសូមជូនជាយោបល់បន្តិចទាក់ទងទៅនឹងការបំភ្លឺរបស់អ្នកជំនាញឈ្មោះលោក ក្រេក នេះ ។ ទាក់ទងទៅនឹងការសួរហ្នឹង គឺថាតាមដែលខ្ញុំតាមសង្កេតមើលឃើញថា លោកស្រីចៅក្រមសួរពីបញ្ហានេះ គឺថាវាស្របទៅនឹងអ្វីដែលបានចេញនៅក្នុងដីកាអញ្ជើញហើយ ហើយលោកស្រីបានគ្រាន់តែចង្អុលបង្ហាញឲ្យអ្នកជំនាញហ្នឹងថា បើសិនណាជា

លោកឆ្លើយអ៊ីចឹង តើលោកមានឧទាហរណ៍អីជាក់លាក់ទេ? ដើម្បីបង្ហាញ ដើម្បីយកមកគាំទ្រអ្វីដែលលោកបានបំភ្លឺ ។

អ៊ីចឹង អ្នកជំនាញនេះគាត់បានលើកពីឧទាហរណ៍ជាក់លាក់ ហើយឧទាហរណ៍ជាក់លាក់ហ្នឹងវាមាននៅក្នុងសំណុំរឿង បើសិនណាជាយកចេញពីណារប៉ាត់រប៉ាយមកគឺថា មិនអាចយកជាការបានទេ ។ អ៊ីចឹង អ្វីដែលគាត់បានលើកឡើង ហើយយោងនេះ គឺជាឧទាហរណ៍ជាក់លាក់ ដើម្បីជូនទៅអង្គជំនុំជម្រះពិចារណា ។ សូមអរគុណ អស់ប៉ុណ្ណឹង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទីបី ហុង គីមសួន ។

[១០:៣៨:៣០]

**លោក ហុង គីមសួន៖**

សូមអរគុណលោកស្រី ។ ខ្ញុំបាទមានជាយោបល់ជម្រាបជូន តាមការយល់ឃើញរបស់ខ្ញុំបាទជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំបាទយល់ឃើញថា លោកបណ្ឌិត ក្រេក អេតឆេសាន់ ជាអ្នកជំនាញដែលបានចងក្រងជាឯកសារសម្រាប់ដាក់ជូនមកជជែកវែកញែកនៅក្នុងអង្គសវនាការនេះ គឺលោកប្រធានអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក បានចេញសេចក្ដីប្រកាសជូនដំណឹងរួចហើយ និងបានជម្រាបអង្គសវនាការអំពីពេលវេលាដែលលោកអ្នកជំនាញត្រូវចូលមកបំភ្លឺ ។

អ៊ីចឹងលោកប្រធានពីម្សិលមិញលោកបានជម្រាបហើយ ក្រោយពេលដែលលោក អ្នកជំនាញគាត់បានធ្វើសក្ខីកម្មចប់ នោះភាគីនឹងធ្វើការកត់សម្គាល់ ឬធ្វើការតាំងសំណួរ ។ ហើយនៅពេលនេះតាមខ្ញុំបាទស្ដាប់ រាល់ពេលដែលលោកស្រីចៅក្រមសួរទៅគាត់ លោក អេតឆេសាន់ ច្រើនតែនិយាយថា “បើសិនលោកស្រីចៅក្រមអនុញ្ញាត” ។ អ៊ីចឹងគាត់មិនមែនលើកយកគំនិតគាត់តែរហូតទេ គឺសូមអនុញ្ញាតសិន នេះទីមួយ ។ ទីពីរ ទាក់ទងការជំទាស់របស់លោកមេធាវីការពារ លោកថាឯកសារដែលលោកបណ្ឌិត អេតឆេសាន់ យកមកសំអាងនេះ អម្បាញ់មិញលោកហ្វ្រង់ស្វ័រ រូ លោកថា គាត់ឆ្លើយតបជាមួយនឹងលោកស្រីចៅក្រម គាត់មិនទាន់សម្រេចថា ទទួលយក ឬមិនទទួលយកទេ រង់ចាំមើលការបង្ហាញ ឬបំភ្លឺពីលោក អេតឆេសាន់ សិន ។

អ៊ីចឹងមកដល់នៅពេលនេះ រាល់ឯកសារដែលលោក អេតឆេសាន់ លើកឡើង ខ្ញុំបាទយល់ឃើញថា មិនមែនជាឯកសារថ្មី ដូចលោកព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញនេះ ហើយលោកហ្វ្រង់ស្វ័រ

រូ បានប្រៀបធៀបអំពីឯកសារដែលគាត់លើកឡើងនៅក្នុងឯកសារលោកសហចៅក្រមស៊ើបអង្កេត ។ មានន័យថា ឯកសារនោះចេញក្រោយពេលដែលលោក អេតធេសាន់ ចងក្រងជាឯកសារនេះឡើង ។ ក៏ប៉ុន្តែ អ្វីដែលលោក អេតធេសាន់ លើកឡើងនោះ មានលេខ ERN ដែលយោងនេះ គឺខ្ញុំបាទសង្កេតឃើញថា មាននៅក្នុងលេខសំអាងនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហចៅព្រះរាជអាជ្ញាទៅទៀត ។ អ៊ីចឹងបើប្រៀបធៀបអ៊ីចឹង ឯកសារនេះគឺមានមុន គ្រាន់តែថា ការបង្ហាញនៅពេលនេះ លោក អេតធេសាន់ គាត់ឆ្លើយតបនឹងសំណួរលោកស្រីចៅក្រមតែប៉ុណ្ណោះ ។ អ៊ីចឹងមិនមែនជាឯកសារថ្មី មិនមែនជាឯកសារមិនបានចែងនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរនោះទេ ។

[១០:៤១:២៥]

សរុបមក គឺឯកសារទាំងអស់នេះ គឺមានជាផ្លូវការនៅក្នុងតុលាការរួចហើយ គ្រាន់តែថា ការបង្ហាញជាឯកសារលេខយោងបង្ហាញចែកជូនអម្បាញ់មិញនេះ ពីម្សិលមិញយើងខ្ញុំក៏មិនបានទទួលដែរ ហើយលោកហ្វ្រង់ស្វ័រ រូ ក៏លោកថា គឺអម្បាញ់មិញនេះ គាត់ក៏មិនទាន់បានសិក្សាទាំងអស់ដែរ មានន័យថាយើងរង់ចាំស្តាប់សិន ។ អ៊ីចឹងបើជំទាស់ទៅនឹងការលើកឡើងរបស់លោក អេតធេសាន់ ខ្ញុំបាទយល់ថា គឺមិនជាការត្រឹមត្រូវនោះទេ ព្រោះគាត់ឆ្លើយទៅនឹងសំណួររបស់លោកស្រីចៅក្រមតែប៉ុណ្ណោះ ។

ហេតុដូច្នេះ ខ្ញុំបាទសូមគាំទ្រនូវការឆ្លើយជាសក្ខីកម្មជូនអង្គសវនាការក្នុងតួនាទីដែលលោកស្រីចៅក្រមសាកសួរគាត់ឲ្យបំភ្លឺតែប៉ុណ្ណោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

អង្គជំនុំជម្រះក៏បានពិនិត្យឃើញ កត់សម្គាល់ផងដែរ ទៅលើបញ្ជីដែលអ្នកជំនាញបានផ្តល់ឲ្យកាលពីព្រឹកមិញនេះ គឺឯកសារចំនួនពីរចុងក្រោយនៅក្នុងបញ្ជីហ្នឹង គឺមិនមានការបកប្រែជាភាសាបារាំងទេ ។ ខ្ញុំនិយាយអំពីឯកសារពីរចុងក្រោយសម្រាប់លោកប្រធានពិនិត្យមើល ។

នេះគឺជាបញ្ហាមួយទៀត ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំចង់ធ្វើការបញ្ជាក់ចំណុចមួយចំនួនដល់អង្គជំនុំជម្រះ ខ្ញុំយល់ឃើញថា បញ្ហាហ្នឹង គឺវាកើតចេញមកពីសំណួរដូចខាងក្រោមនេះ ។

នៅពេលដែលលោក ក្រេក អេតធេសាន់ បានផ្តល់របាយការណ៍របស់គាត់កាលពីខែកក្កដា ឆ្នាំ២០០៧ គឺថានៅពេលហ្នឹងមិនទាន់មានជនជាប់ចោទនៅឡើយទេ ។ នោះគឺជារបាយការណ៍ទូទៅមួយ

ហើយតាមពិតនុ៎ងឯង គឺជាគោលបំណងនៃរបាយការណ៍នោះ ។ ដូចដែលអង្គជំនុំជម្រះបានលើកឡើង នៅក្នុងដីការបស់ខ្លួន គោលបំណងរបស់របាយការណ៍នោះ គឺផ្តល់នូវទស្សនទានអំពីស្ថានភាពនៅក្នុង របបកម្ពុជាប្រជាធិបតេយ្យ ។ អ្វីធ្វើឲ្យខ្ញុំមានអារម្មណ៍មិនសុខស្រួលនោះ គឺថានៅថ្ងៃនេះ ប្រហែល ជាពីរឆ្នាំក្រោយ តាំងពីពេលមានរបាយការណ៍នោះមក ហើយបន្ទាប់ពីបានដឹងអំពីការស៊ើបអង្កេតជាក់ លាក់មួយចំនួនទៅលើលោក ឌុច អ្នកជំនាញនេះបានផ្តល់នូវចំណុចលម្អិត ទៅលើរបាយការណ៍របស់ គាត់ ហើយដែលជាការពិតណាស់ របាយការណ៍នុ៎ង គឺអាចនឹងជាការអត្ថប្រយោជន៍ណាស់សម្រាប់ បង្ហាញអំពីការពិត ។

[១០:៤៤:៣៥]

ក៏ប៉ុន្តែ ខ្ញុំនៅតែទទូចថា គឺការលើកឡើងនោះឯង គឺគួរតែជាចំណុចបន្ថែមទៀតទៅលើរបាយ-ការណ៍របស់គាត់ ។ ហើយគ្រប់ៗគ្នានឹងអាចត្រូវទទួលបាននូវការទទួលព័ត៌មានអំពីទស្សនទាន ដែល គាត់បានផ្តល់នោះ ដោយក្នុងនាមគាត់ជាអ្នកជំនាញ លោក អេតឆេសាន់ នឹងអាចផ្តល់នូវការវិភាគអំពី ឯកសារផ្សេងៗដែលបានប្រមូលដោយសហចៅក្រមស៊ើបអង្កេត ។ ហើយបើសិនជាធ្វើដូច្នោះ គឺអ្វីៗ វាច្បាស់លាស់ស្រួលណាស់ ។ ប៉ុន្តែ ដោយនៅពេលដែលយើងកំពុងនិយាយពេលនេះគឺថា អ្វីៗដូចអត់ មានភាពច្បាស់លាស់ទេ ។

ប្រសិនបើ លោកស្រីចៅក្រមពិនិត្យមើលទៅលើរបាយការណ៍ដែលបាន ដីកាដែលបានចុះថ្ងៃទី ២៨ ខែមេសា គឺបានលើកឡើងថា លោក ឆេនល័រ នឹងនិយាយអំពី ស-២១ ។ នេះជាការពិតណាស់ ។ ជាការពិតប្រាកដច្បាស់លាស់ណាស់ គឺថាយើងបានដឹងថាលោក ឆេនល័រ នឹងនិយាយអំពីស-២១ ។ ប៉ុន្តែ មិនមានការសរសេរអ្វីសោះនៅក្នុងចំណុចទីបួននៃដីការបស់លោក ដែលថាលោកក្រេក អេតឆេ សាន់ ហ្នឹងនិយាយពិភាក្សាពីបញ្ហាស-២១ នោះ ។ ហើយនៅក្នុងរបាយការណ៍របស់គាត់គឺថា មានតែ ពីរបីបន្ទាត់ប៉ុណ្ណោះនិយាយអំពី ស-២១ ។ គឺថាខ្ញុំចង់ដឹងថា តើលោក ក្រេក អេតឆេសាន់ នឹងផ្តល់ការ វិភាគយ៉ាងណាខ្លះដែរ បើសិនជាខាងសហព្រះរាជអាជ្ញានឹងធ្វើការបង្ហាញអំពី រចនាសម្ព័ន្ធគ្រប់គ្រង រចនាសម្ព័ន្ធរបស់រដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ ។ ហើយខ្ញុំគិតថា លោក អេតឆេសាន់ គឺថា ត្រូវបានទទួលស្គាល់ថាជាអ្នកជំនាញនៅក្នុងផ្នែកនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ក៏ដល់ម៉ោងត្រូវឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសឈប់សម្រាក ហើយរហូត

ដល់ម៉ោងដប់មួយនិងដប់ប្រាំនាទី សូមអញ្ជើញចូលមកវិញ ។ ហើយមន្ត្រីតុលាការសម្របសម្រួលអ្នកជំនាញដើម្បីឲ្យគាត់ទៅកាន់បន្ទប់សម្រាកឲ្យបានត្រឹមត្រូវ ។

*[សវនាការសម្រាកពីម៉ោង ១០:៤៧នាទី ដល់ម៉ោង ១១:៣៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

ឥឡូវនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគី និងអ្នកចូលរួមសវនាការទាំងអស់បានជ្រាបថា ដំណើរការសវនាការ មិនអាចប្រព្រឹត្តទៅបានទេ ត្រូវផ្អាកសវនាការនៅព្រឹកនេះ ត្រឹមនេះ ។ ហើយលើកទៅបន្តសវនាការនៅរសៀលនេះ ចាប់ពីម៉ោងពីររសៀល ដោយហេតុមតិជំទាស់របស់មេធាវីការពារក្តីដែលបានលើកឡើងនេះ មានបញ្ហាជាច្រើនដែលត្រូវដែកពិភាក្សាគ្នារវាងចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងដែលរិះរកមធ្យោបាយដ៏ត្រឹមត្រូវ ដើម្បីអាចចេញសេចក្តីសម្រេចដ៏សមរម្យសម្រាប់ឆ្លើយតបនឹងការជំទាស់នេះ ។

ហេតុដូច្នេះ គឺអង្គជំនុំជម្រះប្រកាសផ្អាកសវនាការនៅព្រឹកនេះត្រឹមនេះ ហើយលើកទៅរសៀលវេលាម៉ោងពីរ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញឲ្យបានមុនម៉ោងពីររសៀលនៅល្ងាចនេះ ។ ដោយឡែក មន្ត្រីតុលាការសម្របសម្រួលដល់អ្នកជំនាញដើម្បីឲ្យគាត់បានសម្រាកពិសាអាហារ និងសូមអញ្ជើញគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងពីររសៀលនេះ ។

*[សវនាការសម្រាកពីម៉ោង ១១:៣៤នាទី ដល់ម៉ោង ១៤:៣១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងឈានចូលដល់ដំណើរការស្តាប់សក្ខីរបស់អ្នកជំនាញបណ្ឌិត គ្រេក អេតធេសាន់ អង្គជំនុំជម្រះសាលាដំបូងសូម

ប្រកាសនូវសេចក្តីសម្រេចលើការជំទាស់ ដែលបានលើកឡើងដោយមេធាវីការពារជនជាប់ចោទពីព្រឹកមិញដូចខាងក្រោម៖

អង្គជំនុំជម្រះសាលាដំបូងមិនជាប់កាតព្វកិច្ចទៅនឹងសេចក្តីណែនាំ ឬការចង្អុលបង្ហាញដែលបានប្រគល់ទៅឲ្យភាគីចំពោះវិសាលភាពនៃការផ្តល់សក្ខីកម្ម ឬរបាយការណ៍របស់អ្នកជំនាញនោះទេ ។

ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូង និងភាគីមានសិទ្ធិក្នុងការសួរសំណួរដល់អ្នកជំនាញ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សំណួរទាំងនោះមានភាពពាក់ព័ន្ធ ។ នៅពេលឆ្លើយទៅនឹងសំណួរទាំងនោះអ្នកជំនាញមិនត្រូវបានចងភ្ជាប់ទៅនឹងរបាយការណ៍ ឬសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរដែលបានដាក់ពីមុននោះទេ ។ អ្នកជំនាញមិនមាននូវកាតព្វកិច្ចក្នុងការដាក់នូវរបាយការណ៍ជាលាយលក្ខណ៍អក្សរបន្ថែមនោះទេ ។

[១៤:៣៣:៣៥]

ជាទូទៅ ដើម្បីដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ រាល់ឯកសារទាំងអស់ត្រូវតែមានជាបីភាសារបស់តុលាការ ។ ប៉ុន្តែ អង្គជំនុំជម្រះនឹងទទួលយកនូវការយោងទៅលើឯកសារទាំងឡាយណាដែលមានជាភាសាខ្មែរ និងភាសាផ្លូវការមួយទៀតរបស់តុលាការ ។ ដោយហេតុថា៖

ក) អ្នកនិយាយភាសាខ្មែរមាននៅក្នុងគ្រប់ភាគីទាំងអស់ និងនៅក្នុងអង្គជំនុំជម្រះសាលាដំបូងផងដែរ ។

ខ) ធនធាននៃការបកប្រែនៅមានកម្រិត ហើយមានឯកសារជាច្រើនក្នុងសំណុំរឿងដែលត្រូវបកប្រែ ។

គ) យោងតាមវិធាន២១ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចក្នុងការរៀបចំដំណើរការសវនាការប្រកបដោយភាពយុត្តិធម៌ និងបញ្ចប់ក្នុងរយៈពេលមួយដែលសមស្រប ។ មានករណីលើកលែងចំពោះវិធាននេះ ដែលករណីមួយនៃការលើកលែងនេះ គឺក្នុងករណីដែលឯកសារត្រូវលើកឡើង ហើយមិនបានជូនដំណឹងជាមុននោះ ភាគីអាចជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារនោះ ឬអាចស្នើសុំពន្យារ សុំពេលវេលាបន្ថែមដើម្បីធ្វើការពិនិត្យពិចារណាលើឯកសារនោះបាន ។

រាល់ការបកប្រែទាំងអស់នឹងត្រូវបានទទួលយកដោយតុលាការ លើកលែងតែមានការជំទាស់ទាក់ទងនឹងភាពត្រឹមត្រូវ និងភាពស៊ីសង្វាក់គ្នារវាងឯកសារទាំងនោះ ។ ការលើកឡើងនូវការជំទាស់នោះត្រូវមានមូលហេតុច្បាស់លាស់ ។ តុលាការសូមរំឭកដល់ភាគីថា ឯកសារ ដោយរួមបញ្ចូលទាំង

ឯកសារដែលលើកឡើងដោយអ្នកជំនាញត្រូវតែបានអាន ឬសង្ខេបដើម្បីយកមកពិចារណានៅចំពោះមុខអង្គជំនុំជម្រះ ។ សេចក្តីសម្រេចៈ

ការជំទាស់ដែលបានលើកឡើងដោយមេធាវីការពារជនជាប់ចោទ ទាក់ទងនឹងវិសាលភាពនៃការធ្វើសក្ខីកម្មរបស់អ្នកជំនាញ ក្រេក អេតឆេសាន់ ដែលថាគាត់គួរតែដាក់នូវរបាយការណ៍បន្ថែម ហើយដែលថា ការបកប្រែមិនបានធ្វើឡើងដោយអង្គភាពបកប្រែរបស់អង្គជំនុំជម្រះក្នុងតុលាការកម្ពុជានោះ ត្រូវបដិសេធចោល ។ ឯកសារ D56 ដែលគេស្គាល់ថា ជាចម្លើយសារភាពរបស់ ចាប ណម មិនមានការបកប្រែជាភាសាបារាំង ហើយការលើកឡើងនៅឯកសារនោះ ធ្វើឡើងដោយមិនបានដឹងជាមុន ។ មេធាវីការពារជនជាប់ចោទ អាចជ្រើសរើសក្នុងការស្នើសុំពេលវេលាបន្ថែម ដើម្បីពិនិត្យលើឯកសារនោះ ឬអាចស្នើសុំបដិសេធមិនឲ្យទទួលយកនូវឯកសារនោះ ក្នុងដំណាក់កាលនេះបាន ។

[១៤:៣៧:០៧]

អង្គជំនុំជម្រះសាលាដំបូង នឹងស្នើសុំដល់មេធាវីការពារជនជាប់ចោទ ឲ្យធ្វើការចង្អុលបង្ហាញដោយផ្អែកតាមសេចក្តីសម្រេចនេះថា តើក្រុមរបស់ខ្លួនរក្សានៅជំហរក្នុងការបដិសេធទៅនឹងឯកសារយោងលេខ D2-15 ឧបសម្ព័ន្ធ “គ” នៃសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ៣៩ និង៣០ដែរ ឬទេ?

ដោយធ្វើការបញ្ជាក់លើឯកសារយោងទាំងនេះ និងប្រសិនបើក្រុមរបស់ខ្លួនរក្សានូវជំហរក្នុងការបដិសេធលើឯកសារទាំងនេះ សូមបញ្ជាក់នូវមូលហេតុនៃការជំទាស់នេះឲ្យបានច្បាស់លាស់ត្រឹមម៉ោងប្រាំបួនព្រឹកថ្ងៃស្អែក ។

នេះជាសេចក្តីសម្រេចលើការជំទាស់របស់មេធាវីការពារជនជាប់ចោទ ដែលបានលើកឡើងពីព្រឹកមិញ ។

សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រ៉ូ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូៈ**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមធ្វើការបញ្ជាក់នូវចំណុចមួយ អ្វីដែលខ្ញុំចង់បានពីលោកជំនាញ គឺទាក់ទងទៅនឹងឯកសារដែលគាត់មានដាក់បញ្ចូលនៅក្នុងបញ្ជីរបស់គាត់ គឺឯកសារលេខ៣៩ តើឯកសារលេខ ៣៩ហ្នឹង និយាយយោងទៅលើឯកសារកំណត់សម្គាល់នៅចុងទំព័រ មានន័យថា នៅក្នុងឯកសារកំណត់ចុងទំព័រនៃរបាយការណ៍របស់អ្នកជំនាញឬ? អ៊ីចឹង តើលេខ៣៩ ហ្នឹង គឺជាលេខ

យោងទៅលើឯកសារអ្វីដែរ? ខ្ញុំចង់ឲ្យលោកអ្នកជំនាញហ្នឹងធ្វើការបញ្ជាក់ ប្រសិនបើលោក លោកស្រីចៅក្រមបានយល់ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្សង់ម៉ាក ។

[១៤:៣៩:៤០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំយល់ថា លេខ៣៩ ហ្នឹង គឺជាឧបសម្ព័ន្ធ “គ” ជាឧបសម្ព័ន្ធរបស់ដីកាបញ្ជូនរឿងឲ្យស៊ើបសួរ គឺវាយោងទៅនឹងលេខដែលមាននៅក្នុងឧបសម្ព័ន្ធរបស់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ ដូច្នេះហើយបានជាឯកសារហ្នឹងត្រូវដាក់បញ្ចូលជាឯកសារ D2-15 ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

ខ្ញុំយល់ថា អ៊ីចឹងដែរ ប៉ុន្តែខ្ញុំតែមានបញ្ហាទាក់ទងទៅនឹងលេខនេះ ពីព្រោះចម្លើយសារភាពនេះគឺពី ចាន់ សំ ហ្នឹងគឺបានយកនៅក្នុងរបាយការណ៍របស់លោក អេតធេសាន់ នៅក្នុងកំណត់សម្គាល់ចុងទំព័រលេខ៥៩ ក៏ប៉ុន្តែថ្ងៃនោះ គឺនិយាយអំពីថ្ងៃ១០ ខែ៩-៧៨ ។ ប៉ុន្តែក្នុងឧបសម្ព័ន្ធហ្នឹង ចម្លើយសារភាពនោះចុះនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ៧៨ វិញ ។ អ៊ីចឹង ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ពីចំណុចនេះ ។

ខ្ញុំចង់និយាយថា តើចម្លើយសារហ្នឹង ជាចម្លើយសារភាពតែមួយទេ ពីព្រោះអី យើងអាចមើលទៅវាដូចជាឯកសារដែលជាចម្លើយសារភាពពីរ ហើយនៅក្នុងឯកសារដែលត្រូវបានដាក់បញ្ចូលដោយខាងសហព្រះរាជអាជ្ញា គឺលេខ E55.1 នៅទំព័រ003 ជាភាសាអង់គ្លេស 21680 ហើយនៅក្រោមលេខ៣១ ។ ៤.១ គឺមានជាលេខដែលមានការបង្ហាញថា ចម្លើយហ្នឹងគឺថ្ងៃទី២៥ ខែតុលា ១៨ របស់ចាន់ សំ ហៅ ស៊ី នេះគឺជាអ្វីដែលមានបង្ហាញ ប៉ុន្តែនៅក្នុងឯកសារដែលបានបង្ហាញនៅថ្ងៃនេះ ។

ខ្ញុំមិនមាននៅថ្ងៃខែពិតប្រាកដនៃសេចក្តីចម្លើយសារភាពនោះទេ អ៊ីចឹងហើយខ្ញុំចង់និយាបញ្ជាក់ឲ្យបានច្បាស់ថា តើយើងនិយាយអំពីចម្លើយតែមួយ ឬក៏ពីរផ្សេងគ្នា?

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

សហចៅក្រម សហព្រះរាជអាជ្ញា ។ សូមអរគុណលោកប្រធាន ខ្ញុំចង់ធ្វើការកែសម្រួលបន្តិច

ទៅលើអ្វីដែលលោកចៅក្រម ឡាវ៉ែន៍ បានលើកឡើងនេះ ។ គឺលេខ៣៩ ហ្នឹង មិនមែនជាលេខឧបសម្ព័ន្ធទេ ប៉ុន្តែគឺជាលេខនៃឯកសារដែលភ្ជាប់ទៅនឹងចម្លើយសារភាពរបស់បុគ្គលនោះផ្ទាល់ ។ ហើយតាមពិតលេខឧបសម្ព័ន្ធ “គ” របស់ឯកសារនោះ គឺលេខ ៤.១ វិញទេ ។ សូមទោស ៤០.២ ។

[១៤:៤៣:៤៩]

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំចង់ស្នើឲ្យយើងបន្តចំពោះដំណើរការនីតិវិធីបន្តទៀត ហើយខ្ញុំសូមចង់ស្នើឲ្យខាងការិយាល័យសហព្រះរាជអាជ្ញាធ្វើការបង្ហាញ ឬក៏ធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ទាក់ទងទៅនឹងឯកសារនេះ។ ហើយនៅក្នុងពេលនេះដែរ គឺថាសូមឲ្យយើងកុំនិយាយយោងទៅលើឯកសារនេះសិន ដើម្បីរង់ចាំឲ្យមានការបញ្ជាក់ឲ្យបានច្បាស់ជាមុនសិន ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងតំណាងសហព្រះរាអាជ្ញាអាចធ្វើបានទេ តាមសំណើរបស់មេធាវីការពារដែលបានលើកឡើងអម្បាញ់មិញនេះ? ប៉ុន្តែបញ្ជាក់ថា មិនលើកឡើងនៅពេលនេះទេ គ្រាន់តែថាអាចធ្វើបាន ហើយនៅហើយនៅពេលវេលាណាមួយដែលសមស្រប ហើយយើងនឹងធ្វើការពិភាក្សានូវឯកសារផ្សេងទៀតដែលឯកសារនេះគ្រាន់តែថា អាចធ្វើបាន ហើយនឹងបង្ហាញនៅពេលណាដែលយើងអាចរកឃើញ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណលោកប្រធាន គឺថា យើងអាចធ្វើដូច្នេះបាន ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងយើងអាចធ្វើដំណើរការនៃកិច្ចពិភាក្សាដេញដោលបន្តទៅទៀតបានហើយ លើកលែងតែឯកសារអម្បាញ់មិញនេះរង់ចាំការរកដែលត្រូវបង្ហាញដោយតំណាងសហព្រះរាជអាជ្ញានៅពេលបន្ទាប់។

ជាបន្តនេះសូមជូនវេទិកានេះទៅលោកស្រីចៅក្រម ខាត់រ៉ាយន៍ ដើម្បីបន្តការតាំងសំណួរទៅដល់អ្នកជំនាញបន្ត ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតរ៉ាយច៍៖**

សូមអរគុណលោកប្រធាន លោកបណ្ឌិត អេតឆេសាន់ ប្រហែលជាលោកភ្លេចថា យើងដល់ចំណុចណាហើយនៅក្នុងសក្ខីកម្មរបស់លោក ប៉ុន្តែយើងអាចបន្តដំណើរទៅមុខទៀត ហើយសូមលោកដែលចាំថាយើងធ្វើការកត់សម្គាល់នូវឯកសារយោងបន្ថែមទៀត ហើយសូមលោក-- ចំណែកឯកសារ

ទាំងបីដែលយើងពិចារណានោះ យើងនឹងគិតនៅពេលក្រោយទៀត ។ ពីព្រោះអីខាងមេធាវីការពារក្តី គាត់មិនទាន់បានធ្វើអត្ថាធិប្បាយទៅលើឯកសារនោះទេ ហើយនិងឯងលេខ៣៩នេះផងដែរ ដែលមាននៅក្នុងឧបសម្ព័ន្ធនៅក្នុងរបាយករណ៍របស់លោក ។

**ស៖** នៅពេលដែលយើងបានឈប់កាលពីព្រឹកមិញនេះ ខ្ញុំបានសួរលោក ថាតើមានប្រភពណាផ្សេងទៀតទេ ដែលស-២១ បានទទួលជនជាប់ឃុំនោះ ហើយឥឡូវខ្ញុំក៏ចង់ដឹងថា តើមានដំណាក់កាលជាក់លាក់ណាមួយទេដែលមានចំនួនច្រើននៃកម្មាភិបាលតាមស្រុកដែលត្រូវបានគេចាប់ ហើយបញ្ជូនមក ស-២១ ដើម្បីធ្វើការសួរចម្លើយនោះ?

[១៤:៤៧:០៣]

**ផ៖** ពិតជាបានលោកស្រីចៅក្រម ។ ប្រសិនបើ សិនជាខ្ញុំអាច ខ្ញុំចង់ធ្វើការបង្ហាញចម្លើយរបស់ខ្ញុំទៅនឹងសំណួរនេះ គឺទាក់ទងទៅនឹងការបង្ហាញតារាងពីរទៀត ។ កាលពីព្រឹកមិញនេះ ខ្ញុំបានពិភាក្សាអំពីបញ្ជីអ្នកទោសរួមចូលគ្នានៅស-២១ របស់ខាងការិយាល័យសហព្រះរាជអាជ្ញា ហើយនិងការចងក្រងបញ្ជីនៃការចាប់ខ្លួននោះ ។ ហើយយើងក៏បានបង្ហាញអំពីតារាង និង*ក្រាហ្វ* ពីព័ត៌មានដែលយើងបានទទួលយកដកស្រង់ចេញពីបញ្ជីអ្នកទោសសរុបនោះ ។ តារាងពីរបន្ថែមទៀតដែលខ្ញុំចង់ធ្វើការបង្ហាញនៅចំពោះមុខអង្គចៅក្រមនៅពេលនេះ គឺបានដកស្រង់ចេញមកពីការវិភាគទៅលើបញ្ជីអ្នកទោសនោះផងដែរ បើសិនជាខ្ញុំអាចបង្ហាញបាននៅពេលនេះ ។

**ស៖** តើមានជំទាស់អ្វីទេ ទាក់ទងទៅនឹងវិធីសាស្ត្រដែលគាត់នឹងធ្វើការបង្ហាញ? តើមានការជំទាស់ពីភាគីពាក់ព័ន្ធណាមួយទេ? អត់មានចំណុចអ្វីពីខាងសហព្រះរាជអាជ្ញាទេ ពីខាងដើមបណ្តឹងរដ្ឋប្បវេណីអត់មានទេ? សូមអរគុណ ។ ចុះខាងមេធាវីការពារក្តីវិញ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ដូចជាការកត់សម្គាល់ពីមុនរបស់ខ្ញុំដែរ គឺថា ជាការសោកស្តាយណាស់ដែលឯកសារត្រូវបានបង្ហាញនៅពេលនេះ ពីព្រោះអីរបាយការណ៍នោះគឺមានរយៈពេលពីរឆ្នាំមកហើយ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

មេធាវីការពារក្តីនឹងមានឱកាសដើម្បីធ្វើការពិចារណាទៅលើតារាងទាំងនេះ ហើយនិងធ្វើការកត់សម្គាល់ ឬក៏សង្កេតនៅពេលក្រោយ ឬក៏ការជំទាស់នៅពេលក្រោយទៀត ។ ប៉ុន្តែ នៅពេលនេះលោក អេតធេសាន់ អាចធ្វើការបង្ហាញពីតារាងទាំងពីរនោះបាន ។

**ស៖** អ៊ីចឹងតើយើងត្រូវលើកឡើងពីលេខ ERN *ណាំប៊ឺ* ទេ ដែលថាឯកសារតារាងនេះត្រូវបានដកស្រង់ចេញមកនោះ?

[១៤:៤៩:២៥]

**ឆ៖** ជាការប្រសើរណាស់ លោកស្រីចៅក្រម ។ ការិយាល័យសហព្រះរាជអាជ្ញាបានបញ្ចូលបញ្ជីឈ្មោះអ្នកទោសហ្នឹង គឺលេខ D៥៥ ហើយ ERN ជាភាសាអង់គ្លេស គឺ00172353 រហូតដល់លេខ 00172255 ។

**ស៖** ខ្ញុំសូមធ្វើការកាត់បន្តិច លោក អេតធេសាន់ ។ ខ្ញុំមើលទៅដូចជាមានកំហុសនៅក្នុងលេខ ERN *ណាំប៊ឺ* អ៊ីចឹងលេខហ្នឹងចាប់ផ្តើមគឺ00172353 ប៉ុន្តែបញ្ចប់នៅលេខ 00172255 វិញ ។ មានន័យថា លេខនេះវាថយចុះមកវិញ វាអត់កើនឡើងទៅមុខទេ ។

**ឆ៖** លោកស្រីចៅក្រម ពិតជាត្រឹមត្រូវហើយ។ ខ្ញុំធ្វើមានកំហុសតូចមួយនៅក្នុងការសរសេរនូវលេខនេះ ពីព្រោះខ្ញុំបានដកយកលេខ ERN នេះពីការិយាល័យសហព្រះរាជអាជ្ញា ។ អ៊ីចឹងប្រហែលជាយើងអាចមានចំណុចមួយមិនល្អទាក់ទងទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្ន័យនេះ ។ អ៊ីចឹងគឺខ្ញុំប្រហែលជាអត់មានលទ្ធភាពក្នុងការផ្តល់នូវលេខ ERN ឲ្យបានត្រឹមត្រូវទេ ។

**ស៖** អ៊ីចឹង ខ្ញុំចង់សួរខាងការិយាល័យសហព្រះរាជអាជ្ញា តើអាចផ្តល់លេខ ERN ឲ្យបានត្រឹមត្រូវទេ?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

គឺយើងឃើញថា មានវៃលេខខុសមួយខ្ទង់ គឺលេខ 00172353 រហូតដល់លេខ 00172355 ។ ឯកសារនេះ គឺជាកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីសាក្សី និងចម្លើយភស្តុតាង ហើយនិងរបាយ-ការណ៍ជាលាយលក្ខណ៍អក្សរដែលវាមានបីទំព័រ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** សូមអរគុណ តើលោក គ្រេក អេតធេសាន់ អាចបន្តទៀតបានទេ ។

**ឆ៖** ខ្ញុំអាចបន្តបាន តែសុំទោសចំពោះការអានខុសលេខនេះ ។ ដោយមានការជំនួយពីខាងសោតស្សន៍ សូមឲ្យខាងសោតស្សន៍ធ្វើការបញ្ចាំង *ឡេបថប* របស់ខ្ញុំ ។

ជាថ្មីម្តងទៀត តារាងនេះ គឺផ្អែកទៅលើការវិភាគរបស់ការិយាល័យសហព្រះរាជអាជ្ញា ដោយផ្អែកទៅលើបញ្ជីរួមលើអ្នកទោស ហើយមាននៅក្នុងសំណុំរឿងដូចដែលខ្ញុំបានលើកឡើងពីមុន ។ តារាង

មួយនេះ គឺបានបង្ហាញអំពីការកម្ទេចកម្មាភិបាលគណៈបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងតាមភូមិនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ហើយនៅក្នុងភូមិភាគមួយចំនួន ការកម្ទេចវាមានលក្ខណៈធ្ងន់ធ្ងរជាងភូមិភាគដទៃទៀត ។ ជាពិសេសការកម្ទេចធ្ងន់ធ្ងរនោះ គឺត្រូវបាន ធ្វើឡើងនៅខាងផ្នែកពាយ័ព្យ ហើយនៅក្នុងផ្នែកភូមិភាគបូព៌ា ហើយនិងភូមិភាគពាយព្យ និងភូមភាគបូព៌ា ។

អង្គជំនុំជម្រះអាចពិនិត្យមើលទៅលើតារាងនេះ និងយើងនិងធ្វើការពិភាក្សាពិស្តារទៅលើចំណុចនេះ ។

**ស៖** លោកអាចបន្តបានទៀតលោក បណ្ឌិត ក្រេក អេតឆេសាន់ ។

**ឆ៖** តារាងបន្ទាប់នេះ គឺធ្វើការប្រៀបធៀបនូវតំបន់ ភូមិភាគកណ្តាល ភូមិភាគពាយព្យ និងភូមិភាគបូព៌ា ។ ដោយធ្វើការប្រៀបធៀបនូវការចាប់ខ្លួននៅស-២១ ។ តារាងនេះ គឺក៏ផ្អែកទៅលើទិន្ន័យរបស់ខាងសហព្រះរាជអាជ្ញា ដោយផ្អែកទៅលើបញ្ជីរមរបស់លើអ្នកទោស ។ តារាងមួយនេះ គឺបានបង្ហាញ គឺបានកម្ទេចទៅលើភូមិភាគកណ្តាល គឺកើនឡើងដល់ចំណុចកំពូលនៅក្នុងឆ្នាំ១៩៧៧ ។ ហើយខាងផ្នែកកម្ទេច ខាងផ្នែកពាយ័ព្យ គឺធ្វើឡើងដល់-- ក្នុងការកម្ទេចដល់ចំណុចខ្ពស់បំផុតនៅក្នុងឆ្នាំ៧៧ដល់ទៅដល់៧៨ ។ ហើយការកម្ទេចនៅក្នុងភូមិភាគបូព៌ា គឺមានការកើនឡើងដល់ចំណុចខ្ពស់បំផុតនៅក្នុងឆមាសទីពីរនៃឆ្នាំ៧៨ ។ ហើយកម្មាភិបាលមកពីភូមិភាគគឺមានចំនួនជាងមួយពាន់នាក់ ត្រូវបានបញ្ជូនទៅស-២១ ទាក់ទងទៅនឹងការបោសសម្អាតទាំងអស់នោះ ។ ហើយកម្មាភិបាលភាគច្រើនគឺមកពីខាងស្រុក ។ ហើយនៅពេលដែលយើងពិនិត្យមើលទៅលើតារាងនេះ គឺយើងឃើញមានការផ្តោតសំខាន់ទៅលើកម្មាភិបាលថ្នាក់ស្រុកដែលត្រូវបានបញ្ជូនទៅស-២១ ។

**ស៖** សូមអរគុណ ។ នេះគឺជាតារាងចំនួនពីរដែលលោកចង់បង្ហាញនោះ ឬយ៉ាងម៉េច?

**ឆ៖** គឺត្រឹមត្រូវ ។

**ចៅក្រម ស៊ីលវ៉ា ខាតវ៉ាយថ៍៖**

ដូច្នេះ ខាងសោតទស្សន៍អាចធ្វើការបង្វែររូបភាពទៅជារូបភាពដើមវិញ ។

[១៤:៥៦:៤៨]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកស្រីចៅក្រម, ថាតើយើងខ្ញុំអាចមានឯកសារថតចម្លងនៃតារាងនេះឲ្យបានលឿន បានដែរឬទេ? ហើយខ្ញុំសូមធ្វើការសង្កេតនៅក្នុងត្រង់ចំណុចនេះផងដែរ ។

យើងនិយាយជាច្រើនអាទិត្យហើយ ច្រើនខែហើយ ជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ដើម្បីបង្កើតអំពីបញ្ជីនៃអង្គហេតុដែលទទួលស្គាល់ដោយជនជាប់ចោទ ។ ហើយតើលោក លោកស្រីចៅក្រមគិតថា វាមានប្រយោជន៍ដែរឬទេ ក្នុងការឱ្យមេធាវីការពារក្តីដឹងអំពីឯកសារទាំងអស់នោះ ដោយសារឯកសារវាមានផលប្រយោជន៍ ។ ហេតុអ្វីយើងចាំបាច់រង់ចាំដល់ពេលរហូតដល់អ្នកជំនាញធ្វើការផ្តល់សក្ខីកម្មទៅវិញ នៅក្នុងនីតិវិធីតទល់ដែលធ្វើឡើងនៅពេលនេះ? ហើយម្យ៉ាងវិញទៀត ខ្ញុំសូមធ្វើការកែប្រែទៅលើចំណុចមួយ ខុសតូចមួយដែលលោក អាឡិច ប៊េត បានលើកឡើង ។

ឧបសម្ព័ន្ធ D55 នោះ គឺជាមិនមែនជាកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសម្ភាសន៍លោក ក្រេក អេតធេសាន់ នោះទេ ។ D55 គឺជាសំណើរបស់សហព្រះរាជអាជ្ញា ដែលបានផ្ញើជូនទៅសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៨ គឺជាងមួយឆ្នាំមកហើយ ដែលនៅក្នុងលិខិតនោះ គឺស្នើសុំក្នុងការទទួលបញ្ជីអ្នកទោសមកពី ស-២១ ដែលមានចំណងជើងថា-- ហើយយើងឃើញថា សំណើនេះគឺមានបីទំព័រ ។ ហើយឧបសម្ព័ន្ធ "ក" គឺមានរហូតទៅដល់៣៧០ទំព័រ ហើយខ្ញុំយល់ឃើញថា ដោយផ្អែកទៅលើ៣៧០ទំព័រ ដែលមាននៅក្នុងឯកសារនោះ គឺវាជាបញ្ជីរបស់អ្នកទោស ហើយលោក ក្រេក អេតធេសាន់ គឺអាចធ្វើការបង្កើតតារាងទាំងពីរដែលគាត់បង្ហាញយើងអម្បាញ់មិញនេះ ។ ដូច្នេះហើយ គឺខ្ញុំចង់មានឯកសារទាក់ទងនឹងតារាងទាំងពីរនេះឱ្យបានលឿនបំផុត ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំឃើញសញ្ញាពីសហព្រះរាជអាជ្ញាថានឹងធ្វើឱ្យបានលឿន ។ តើលោកសហព្រះរាជអាជ្ញាអាចធ្វើការបញ្ជាក់ និងផ្តល់សញ្ញាទៅលើការស្នើសុំនេះបានដែរឬទេ?

**លោក អាឡិចសាន់ឌឺ ប៊េត៖**

សូមអរគុណ ។ ប្រសិនបើមេការពារទាមទារឯកសារថតចម្លងនោះជាលាយលក្ខណ៍អក្សរនោះ គឺខ្ញុំនឹងធ្វើការផ្តល់ជូននូវស្អែកព្រឹក ហើយប្រសិនបើទាមទារឱ្យមានការបកប្រែទាំងពីរភាសានោះ គឺវាអាចចំណាយពេលមួយអាទិត្យ ។ ដូច្នេះ ខ្ញុំសូមឱ្យមានការបញ្ជាក់ ឬក៏ធ្វើការតម្រូវទៅលើចំណុចនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោក រ៉ូ យ៉ាងហោចណាស់លោកចង់បានតារាងដែលបង្ហាញទាំង-- ដែលតារាងទាំងពីរនេះដែលបង្ហាញទាំងពីរនេះនៅពេលនេះ នៅពេលព្រឹកស្អែក ឬក៏ហើយរង់ចាំការបកប្រែរហូតទៅដល់អាទិត្យក្រោយ ។ តើលោកយល់យ៉ាងម៉េច?

[១៥:០០:៤៩]

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំគិតថា យើងគួរតែអាចប្រើប្រាស់ទាញ ឬក៏ទាញផលប្រយោជន៍ពីតារាងទាំងពីរនេះ ។ មិនចាំបាច់សុំឱ្យខាងសេវាបកប្រែធ្វើការងារនេះជាបន្ទុករបស់គេទៀតទេ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៏៖**

**ស៖** វាជាចំណុចល្អណាស់ទាក់ទងចំណុចនេះ ។ ហើយលោក គ្រេក អេតធេសាន់ ខ្ញុំចង់ធ្វើការប្រៀបធៀបស្ថានភាពនៅក្នុងស-២១ ទាក់ទងទៅនឹងគុកពិសេស គឺគុកខាងគុកពិសេស ដែលគាត់ទទួលអ្នកជាប់ឃុំយ៉ាងច្រើន ។

**ឆ៖** ខ្ញុំមិនយល់ដូច្នេះទេ ។ កម្ពុជាប្រជាធិបតេយ្យទាក់ទងទៅនឹងមន្ទីរសន្តិសុខ គឺមានអំណាចក្នុងការចាប់បុគ្គលនៅក្នុងតំបន់នៃការគ្រប់គ្រងរបស់ខ្លួន ។ ឧទាហរណ៍ នៅក្នុងតំបន់១០៣ មន្ទីរសន្តិសុខនេះ គឺអនុញ្ញាតក្នុងការចាប់ខ្លួនបុគ្គលនៅក្នុងតំបន់១០៣ ។ ហើយចំពោះខាងភូមិភាគនិរតីគឺអនុញ្ញាតឲ្យចាប់ខ្លួនបុគ្គលិកនៅក្នុងភាគនិរតី ។ល។ និង ។ល។ ប៉ុន្តែ ស-២១ តួនាទីជាច្រើន គឺវាផ្តោតទៅលើទូទាំងប្រទេស ។ ស-២១ គឺជាមន្ទីរសន្តិសុខដែលមានអំណាចក្នុងការចាប់ខ្លួន ហើយនិងយកមនុស្សមកពីគ្រប់ផ្នែកទាំងអស់នៅក្នុងប្រទេស ។

**ស៖** នៅក្នុងចម្លើយរបស់ជនជាប់ចោទ ជនជាប់ចោទបានលើកឡើងថាស-២១ គឺជាឧបករណ៍របស់គណៈអចិន្ត្រៃយ៍ ។ ហើយគាត់បានលើកឡើងថា ហើយស-២១ នេះវាជាឧបករណ៍របស់គណៈអចិន្ត្រៃយ៍ដោយសារវាមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ។ តើលោកយល់ដូច្នេះដែរឬទេ?

**ឆ៖** ជាការពិត គឺដូច្នេះមែន ។ គណៈមជ្ឈិម គឺយើងហៅថា គណៈមជ្ឈិម ដែលថាអំណាចជាគឺវាស្ថិតនៅក្នុងថានានុក្រម ហើយវាផ្តោតទៅលើចំណុចនេះ ។ មន្ទីរសន្តិសុខដែលជាប់ពាក់ព័ន្ធជាមួយអង្គការជាន់ខ្ពស់មួយនេះ គឺវាមានដែនកំណត់នៃអំណាចនៅក្នុងរដ្ឋកម្ពុជាប្រជាធិបតេយ្យ ហើយវាបានឆ្លុះបញ្ចាំងអំពីអំណាចដែលជនជាប់ចោទមានផងដែរនោះ ។

**ស៖** ហើយនៅក្នុងចម្លើយនៃអង្គហេតុ ដែលបានព្រមព្រៀងគ្នានៅក្នុងកថាខណ្ឌទី២១ ការិយាល័យសហព្រះរាជអាជ្ញាបានលើកឡើងដូច្នេះថា ស-២១ គឺជាផ្នែកសំខាន់នៃរចនាសម្ព័ន្ធនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយដែលយើងហៅថា “អង្គការ” ឬក៏ “អង្គការចាត់តាំង” ឬក៏ “គណៈមជ្ឈិម” ។ គណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍ ដែលមានយោងនៅក្នុងកថាខណ្ឌ៣២ នៃដីកាដំណោះស្រាយ ។

ហើយគាត់បានយល់ស្របមួយផ្នែកទៅលើចម្លើយនេះ ។

[១៥:០៤:៥៩]

ជនជាប់ចោទក៏បានផ្តល់យោបល់បន្ថែមផងដែរ នៅក្នុងការយល់ឃើញរបស់ ឌុច វាជា-- ត្រឹមត្រូវក្នុងការនិយាយថា ស-២១ គឺគ្រប់គ្រងចាត់ចែងដោយគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិម ជាជាងនៅក្នុងមជ្ឈិម ។ ស-២១ គឺវាជាមិនមែនជាចំណុចមជ្ឈិម ហើយ ឌុច គាត់ជាផ្នែក-- គាត់មិនមែនជាផ្នែកមួយនៃគណៈអចិន្ត្រៃយ៍នោះទេ ។ ថាតើលោកអាចបញ្ជាក់ទៅលើចំណុចនេះ ចំពោះការឆ្លើយតបរបស់ជនជាប់ចោទឆ្លើយតបទៅកថាខណ្ឌ-- អង្គហេតុដែលបានយល់ព្រមព្រៀងគ្នានៅក្នុងកថាខណ្ឌ៦៦ នោះដែរឬទេ?

**ឆ៖** ចំពោះខ្ញុំចំណុចនេះ គឺជាចំណុចមួយដែលបានបង្ហាញជាក់លាក់ ។ ចំពោះការយល់ឃើញរបស់ខ្ញុំ ខ្ញុំគិតថា អង្គហេតុដែលបានព្រមព្រៀងគ្នាចំណុច៦៦ គឺវាត្រឹមត្រូវ ដូចដែលបានលើកឡើងទោះបីជាជនជាប់ចោទមិនមែនជាសមាជិកនៃគណៈអចិន្ត្រៃយ៍ក៏ដោយ ។

**ស៖** សូមអរគុណ ។ ហើយចំពោះស-២១ វាមានខុសគ្នាទាក់ទងទៅនឹងការឃុំខ្លួនទៅតាមថ្នាក់ និងក្រុមដែរឬទេ? គឺខ្ញុំចង់មានន័យទៅលើបញ្ហានៃថ្នាក់ ។

**ឆ៖** គឺវាជាភាពត្រឹមត្រូវក្នុងការនិយាយដូច្នេះ ។ ឧទាហរណ៍ នៅក្នុងចម្លើយរបស់គាត់ចំពោះសហចៅក្រមស៊ើបអង្កេត ជនជាប់ចោទបាននិយាយថា ស-២១ គឺមានអំណាចក្នុងការសួរចម្លើយសមាជិកនៃគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ។ ខ្ញុំមិនមានលេខ ERN ជាក់លាក់ចំពោះការលើកឡើងដូច្នោះនោះទេ ប៉ុន្តែចំណុចនេះ គឺវាមាននៅក្នុងសំណុំរឿងដែលជនជាប់បានលើកឡើងនៅក្នុងដំណាក់កាលស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ។

បន្ថែមទៅលើចំណុចនេះ ប្រសិនបើយើងពិនិត្យឲ្យបានដិតដល់ទៅលើបញ្ជីអ្នកទោសដែលរៀបចំឡើងសហព្រះរាជអាជ្ញានោះ គឺយើងឃើញមានលក្ខណៈជាទូទៅ ។ កម្មាភិបាលដឹកនាំពីភូមិភាគពីតំបន់ និងពីស្រុកផ្សេងៗរួមជាមួយនឹងមេដឹកនាំជួរយោធា និងអ្នកក្នុងជួររដ្ឋាភិបាល គឺមកជាប់ឃុំនៅស-២១ ហើយត្រូវបានគេកម្ទេច ។ ខ្ញុំមិនឃើញភស្តុតាង ដែលបង្ហាញវាលក្ខណៈដូចគ្នានេះដែរនៅតាមមន្ទីរសន្តិសុខផ្សេងៗទៀតទេ ។

អ្នកទោសសំខាន់ៗទាំងអស់ បានន័យថាអ្នកទោសដែលមានតំណែងខ្ពស់ៗនៅក្នុងជួរយោធា និងនយោបាយត្រូវបានគេបញ្ជូនទៅ ស-២១ ។

[១៥:០៨:៣៨]

**ស៖** សូមអរគុណ ។ ថាតើប្រធាននៃគុកពិសេសហ្នឹងបានរាយការណ៍ទៅ សុន សេន ឬក៏រដ្ឋមន្ត្រីផ្សេងទៀតដែរ ឬទេ? (សូមកែប្រែ គឺមន្ទីរសន្តិសុខ គឺប្រធានមន្ទីរសន្តិសុខ)

**ឆ៖** វាជាសំណួរមួយដ៏ពិបាក ។ ខ្ញុំដឹងអំពីភស្តុតាងមួយចំនួនដែលពាក់ព័ន្ធទៅនឹងសំណួរមួយនេះ ប៉ុន្តែភស្តុតាងទាំងនោះនៅក្នុងសំណុំរឿងលេខ២ តែនៅពេលនេះស្ថិតនៅក្នុងការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ។ ដូចដែលលោក លោកស្រីចៅក្រមបានជ្រាបហើយ គឺដំណើរការស៊ើបអង្កេតគឺមានលក្ខណៈសម្ងាត់ ។ ដូច្នេះ ខ្ញុំមិនមានសេរីភាពក្នុងការផ្តល់ជូននៅព័ត៌ពិស្តារទៅលើចំណុចនេះទេ ។ ប៉ុន្តែ ខ្ញុំជឿថា ខ្ញុំអាចនិយាយបានថាមិនមានភស្តុតាងទាំងនោះលើកឡើងជាភស្តុតាងផ្ទាល់អំពីការរាយការណ៍ដោយផ្ទាល់ និងប្រចាំថ្ងៃទៅកាន់ សុន សេន និង នួន ជា នោះទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទាក់ទងមន្ទីរសន្តិសុខផ្សេងៗ ។

**ស៖** សូមអរគុណលោក ក្រេក អេតឆេសាន់ ។ ខ្ញុំសូមចូលទៅដល់រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជា-ធិបតេយ្យ ។ លេខយោងទៅលើឯកសារមួយនេះ គឺនៅក្នុងលេខ ERN ភាសាអង់គ្លេសគឺ 00184833 រហូតដល់ 00184839 ។ នៅក្នុងភាសាខ្មែរ គឺលេខ ERN0089841 រហូតដល់ 0089852 ។ ខ្ញុំអត់មានលេខយោងចំពោះឯកសារបារាំងនៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យមួយនេះទេ ។

តើលោកមានលេខយោងដែរឬទេ? សូមឲ្យលោកផ្តល់ជូនខ្ញុំ ។

**ឆ៖** បាទ, មានលោកស្រីប្រធាន ។ លេខ ERN សម្រាប់ភាសាបារាំងនោះនៃ គឺមានលេខ 00012644 រហូតដល់លេខ 00012659 ។

**ស៖** សូមអរគុណ ។ នៅក្នុងមាត្រា៥ នៃជំពូក៥ហ្នឹង បាននិយាយថា សភាតំណាងនេះត្រូវបានបង្កើតឡើង អ៊ីចឹងនៅក្នុងការស៊ើបអង្កេត នៅក្នុងការស្រាវជ្រាវរបស់លោកថា តើសភាហ្នឹងត្រូវដែលធ្លាប់បានប្រជុំគ្នាដែរឬទេ?

[១៥:១២:៣០]

**ឆ៖** បាទ, លោកស្រីចៅក្រម! ទៅតាមការយល់របស់ខ្ញុំ សភាតំណាងប្រជាជនហ្នឹង គឺថាបានជួបប្រជុំគ្នាម្តងកាលពីថ្ងៃទី១១ ខែ៤ ៧៦ ដែលស៊ីចង្វាក់គ្នានៅពេលដែលអ្នកតំណាងសភានុំង បានបង្កើតនូវច្បាប់នេះ ។

**ស៖** អ៊ីចឹង តើលោកអាចនិយាយថា សមាជិកចំនួន២៦០ហ្នឹងឯង-- ២៥០ហ្នឹងឯង ត្រូវបានគេតែងតាំង ឬក៏ត្រូវបានគេបោះឆ្នោតជ្រើសរើស?

**ឆ៖** ជាការមើលឃើញច្បាស់ណាស់ដែលថា សមាជិកទាំងអស់ត្រូវបានគេតែងតាំងឡើងពីថ្នាក់លើនៃបក្សកុម្មុយនីស្តកម្ពុជា ។

**ស៖** សូមអរគុណ ។ នៅក្នុងជំពូក៦ គឺនិយាយអំពីអង្គការអនុវត្តច្បាប់ ដែលត្រូវជ្រើសតាំងឡើងដោយអ្នកតំណាងប្រជាជននៅក្នុងសភា ។ តើអ្នកតំណាងសភាប្រជាជនកម្ពុជាហ្នឹងត្រូវបានបង្កើតឡើងដែរឬទេ?

**ឆ៖** អង្គការអនុវត្តច្បាប់នៃអង្គការនីតិបញ្ញត្តិរបស់កម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើង ប៉ុន្តែ បើសិនជាលោកពិនិត្យមើលកំណត់ហេតុនៃអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ពី ខែមីនា ឆ្នាំ៧៦ ។ លោកស្រីចៅក្រមអាចពិនិត្យមើលឃើញដំណើរការ ដែលគណៈអចិន្ត្រៃយ៍បានធ្វើឡើងក្នុងការបង្កើតនូវស្ថាប័នរដ្ឋមួយនេះ ។ ប៉ុន្តែមិនដែលមានការបោះឆ្នោតច្បាស់លាស់ពីអ្នកតំណាងប្រជាជននៅកម្ពុជានោះទេ ។ ប៉ុន្តែ គឺថាជាការបោះឆ្នោតដោយអនុម័តសម្រាប់ធ្វើការជ្រើសតាំងតំណាង ដោយសភាតំណាងប្រជាជនកម្ពុជានោះ ។

ហើយនៅក្នុងជំពូក៧ របស់ច្បាប់នេះ គឺថាតុលាការរបស់ប្រជាជនត្រូវបានបង្កើតឡើង ហើយចៅក្រមត្រូវបានតែងតាំងឡើងដោយសភាតំណាងប្រជាជនជាអ្នកជ្រើសរើស និងតែងតាំង ។

**ស៖** តើតុលាការរបស់ប្រជាជននោះត្រូវបានបង្កើតឡើងហើយ ចៅក្រមត្រូវបានគេតែងតាំងដែរ ឬទេ?

[១៥:១៥:00]

**ឆ៖** នៅក្នុងសំណុំរឿងលោកស្រីចៅក្រម មានឯកសារមួយដែលមានចំណងជើងថា "ឯកសារស្តីអំពីការប្រជុំលើកទីមួយនៃសមាជទីមួយរបស់សភាតំណាងប្រជាជនកម្ពុជា ពីថ្ងៃទី១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ៧៦ ។ ឯកសារហ្នឹងគឺចុះនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ៧៦ ។ ហើយឯកសារហ្នឹង គឺថាមានលេខERN គឺលេខ00184048 រហូតដល់លេខ00184078 ហើយនិងមានលេខ ERN00184746 នៅក្នុងឯកសារនោះគឺបាននិយាយថា តំណាងឲ្យប្រជាជនកម្ពុជាបានសម្រេចអំពីការជ្រើសតាំង និងតែងតាំងនូវស្ថាប័នតុលាការ ហើយនិងមានលោក កង ចាប ជាប្រធាន" ។ បិទនូវការដកស្រង់ពាក្យសម្តីមកនេះ ។

ក៏ប៉ុន្តែ នៅក្នុងកំណត់ហេតុអង្គប្រជុំរបស់គណៈអចិន្ត្រៃយ៍ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ៧៦ ដែលមានលេខ ERN00182628 រហូតដល់លេខ 00182634 ហើយនៅទំព័រដែលមានលេខ ERN 00182629 នោះ គណៈអចិន្ត្រៃយ៍បានធ្វើការកត់សម្គាល់ដូចខាងក្រោមនេះ ។ យើងមិនបង្កើតការបោះឆ្នោតនៅក្នុងរាជធានីភ្នំពេញទេ គឺយើងប្រើតាមវិធីនៃការអនុវត្តច្បាប់អនុម័តខ្លួនយើង ។ ហើយអ្នកតំណាងត្រូវបានជ្រើសតាំងពីស្ថាប័នជាន់ខ្ពស់ពីថ្នាក់លើ ។ ដូច្នេះ គណៈអចិន្ត្រៃយ៍បានធ្វើការតែងតាំង កម្មាភិបាលជាន់ខ្ពស់ កង ចាប ជាប្រធាននៃគណៈកម្មាការតុលាការ ។ ប៉ុន្តែ មិនមានភស្តុតាងណាមួយដែលខ្ញុំបានឃើញនៅគ្រប់ទីកន្លែងទាំងអស់ហ្នឹង គឺថាតើគណៈកម្មាការតុលាការហ្នឹងត្រូវបានជួបប្រជុំគ្នាដែរ ឬក៏អត់នោះទេ? ឬក៏មានសកម្មភាពប្រតិបត្តិការអ្វីក្នុងការបង្កើតនូវតុលាការ គឺតុលាការតំណាងប្រជាជន ឬក៏តុលាការផ្សេងនោះទេ ។

អង្គជំនុំជម្រះបានប្រាប់មកបុគ្គលិកទាំងអស់គឺថា មិនឲ្យយើងធ្វើការពិភាក្សាអំពីសេចក្តីចម្លើយសារភាពរបស់ ចាន់ សំ, កង ចាប នោះទេនៅពេលនេះ ។ ដូច្នេះ ខ្ញុំនឹងកត់សម្គាល់អំពីចំណុចនេះ ។ គឺថាអាចមានព័ត៌មានពាក់ព័ន្ធទៀតដែរទាក់ទងទៅនឹងចម្លើយសារភាពនោះ សម្រាប់លោក លោកស្រីចៅក្រមពិចារណា ។

**ស៖** សូមអរគុណ ។ នៅក្នុងជំពូក៨ នៃច្បាប់នេះ និយាយអំពីគណៈប្រធានរដ្ឋដែលត្រូវបានជ្រើសតាំងនិងតែងតាំងដោយសភាតំណាងឲ្យប្រជាជនកម្ពុជានោះ ថាតើមានការបង្កើតឡើងបែបនេះដែរឬទេ?

[១៥:១៩:៣៦]

**ឆ៖** បាទ, មានលោកស្រីចៅក្រម ។ គណៈប្រធានរដ្ឋត្រូវបានបង្កើតឡើង ក៏ប៉ុន្តែដូចគ្នានឹងអង្គភាពផ្សេងៗគ្នាទៀតដែលយើងបានពិភាក្សានោះ គឺជាការពិត ។ គណៈប្រធានរដ្ឋត្រូវបានតែងតាំងដោយគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ។ ហើយការជ្រើសតាំងប្រធានគណៈប្រធានរដ្ឋនោះ គឺក្នុងច្បាប់នេះបានលើកឡើងអំពី គឺថា សភាតំណាងប្រជាជនកម្ពុជានឹងធ្វើការជ្រើសតាំងប្រធានគណៈប្រធានរដ្ឋ ហើយការជ្រើសតាំងនុ៎ងឯង គឺគ្រាន់តែជាការបង្ហាញអំពីសមាជិករបស់គណៈប្រធានរដ្ឋដែលត្រូវបានជ្រើសតាំងដោយគណៈមជ្ឈិមតែប៉ុណ្ណោះ ។

**ស៖** សូមអរគុណ ។ បើអ៊ីចឹង ខ្ញុំចង់សួរឲ្យលោកបញ្ចេញយោបល់បន្តិចទាក់ទងទៅនឹងចំណុចមួយចំនួន ដែលយើង ដែលបានលើកឡើងដោយជនជាប់ចោទនៅក្នុងចម្លើយរបស់គាត់ ។ គាត់បាន

និយាយថា នយោបាយបក្សកុម្មុយនីស្តកម្ពុជាគឺដាច់ខាត ផ្តាច់ការ តើលោកឯកភាពនឹងចំណុចនេះទេ?

**ឆ៖** ពាក្យពេចន៍ដែលប្រើគឺ ពាក្យពេចន៍ផ្តាច់ការ គឺជាពាក្យមនោគមវិជ្ជាដែលត្រូវបានប្រើនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ហើយពាក្យដាច់ខាតនេះ គឺនិយាយអំពីកម្រិតនៃការប្តេជ្ញាចិត្តរបស់កម្មាភិបាលណាម្នាក់ ដើម្បីអនុវត្តនូវមាគ៌ានយោបាយរបស់បក្ស ឬមួយក៏កម្រិតនៃការលះបង់របស់កម្មាភិបាលណាម្នាក់ ដែលគាត់ព្យាយាមធ្វើដើម្បីដំណើរការបដិវត្តន៍ ឬមួយក៏បើនិយាយអំពីកម្រិតនៃការណែនាំនយោបាយដែលបានចេញមកពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់បក្ស ។ នៅតាមមនោគមវិជ្ជាដ៏តឹងតែងបែបនេះ គឺថាអ្វីៗភាគច្រើនសុទ្ធតែជាដាច់ខាតនៅក្នុងបដិវត្តន៍របស់ខ្មែរក្រហម ។

**ស៖** ជនជាប់ចោទក៏បាននិយាយថា គឺនៅស-២១ ប្រជាជនត្រូវបានចាប់ ហើយប្រហែលជាត្រូវបានឃុំខ្លួននៅទីនោះ ហើយប្រហែលជានឹងមិនត្រូវបានគេដោះលែងឲ្យចេញក្រៅបានទេ ។ អ៊ីចឹងនៅក្នុងការស្រាវជ្រាវរបស់លោក តើលោកមានបានបញ្ជាក់ អាចបញ្ជាក់បានអំពីអ្វីដែលជនជាប់ចោទបានលើកឡើងនេះទេ?

**ឆ៖** បាទ,ខ្ញុំមើលទៅដូចជាឃើញថា នេះគឺតាមអាស្រ័យតាមការស្រាវជ្រាវរបស់ខ្ញុំទាក់ទងទៅនឹងស-២១ មុនពេលដែលជនជាប់ចោទបានក្លាយទៅជាប្រធានស-២១ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់លេខាស-២១ ពីមុននោះគឺលោក ណាត គឺថាវាមិនសាមញ្ញធម្មតាទេដែលបុគ្គលណាម្នាក់ត្រូវគេដោះលែងនោះ ។ ប៉ុន្តែ បន្ទាប់ពីជនជាប់ចោទបានក្លាយទៅជាលេខាស-២១ មក ការដោះលែងអ្នកទោស គឺកាន់តែមានចំនួនតិចទៅ ហើយជាការពិតណាស់គឺថា កម្រនឹងមានណាស់បើយើងមើលទៅតាមតួលេខស្ថិតិ ។ ក៏ប៉ុន្តែ មិនមែនជាការពិតទេដែលថា មិនដែលមាននរណាម្នាក់ត្រូវបានគេដោះលែងនោះ ។

[១៥:២៣:៥៥]

**ស៖** ជនជាប់ចោទក៏បាននិយាយដែរថា គាត់មិនមានសិទ្ធិក្នុងការដោះលែងជនណាម្នាក់ចេញពីមន្ទីរស-២១ ទេ តើលោកមានមតិយោបល់អ្វីទេ ទៅលើចំណុចនេះ?

**ឆ៖** ខ្ញុំសង្ស័យថា នេះប្រហែលនេះអាចជាការពិត ។

**ស៖** ហើយបន្ទាប់មកទៀតគាត់ក៏បាននិយាយដែរថា ប៉ុល ពត ខ្លួនឯងផ្ទាល់ហ្នឹង គឺថាមិនមានសិទ្ធិក្នុងការដោះលែងជនណាម្នាក់នោះទេ ។ តើលោកអាចមានមតិអីទៅលើចំណុចនេះទេ?

**ឆៈ** ខ្ញុំមិនដឹងថាតើចំណុចនេះអាចជាការពិត ឬក៏អត់ទេលោកស្រីចៅក្រម? ទៅតាមការយល់ដឹងភាគច្រើនរបស់យើងនោះអំពីដំណើរការគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ប្រតិបត្តិការការងាររបស់ខ្លួននោះគឺអាចមានការស្នើឡើងថា ពួកគេប្រតិបត្តិការតាមរយៈគោលការណ៍នៃការសមូហភាពនិយម ហើយនិងគឺតាមចំណុចប្រមូលផ្តុំហើយសេចក្តីសម្រេចទៅលើនយោបាយនោះ គឺថាត្រូវបានពិភាក្សាគ្នាហើយត្រូវបានសម្រេច ហើយមានន័យថា គ្រប់ៗគ្នាគឺត្រូវអនុវត្តតាមសេចក្តីសម្រេចនោះ ។ ក៏ប៉ុន្តែយើងហាក់បីដូចបង្ហាញដែរថា ប៉ុល ពត ក្នុងនាមគាត់ជាលេខាបក្ស ហើយក្នុងនាមគាត់ជាអ្នកនយោបាយផងដែរនោះ គឺជាមនុស្សដែលពូកែទាក់ទាញទឹកចិត្តមនុស្សណាស់ ។ អ៊ីចឹងជាការពិបាកសម្រាប់ខ្ញុំធ្វើការស្រមើស្រមៃថា ប្រសិនបើគាត់មានបំណងប្រាថ្នាឲ្យនរណាម្នាក់ត្រូវបានដោះលែងពី ស-២១ នោះ ហើយគាត់បើសិនជាគាត់មិនអាចរៀបចំឲ្យដោះលែងបាននោះដូចជាមិនស្តែងទេ ។

**សៈ** សូមអរគុណ ។ ជាថ្មីម្តងទៀត នៅក្នុងចម្លើយរបស់គាត់ ជនជាប់ចោទបាននិយាយថា មន្ទីរមជ្ឈិមគឺរក្សាទុកឯកសារសម្ងាត់ ហើយដែលឯកសារមួយចំនួននោះទៅតាមការកត់សម្គាល់របស់ជនជាប់ចោទគឺថា គាត់មិនបានពិនិត្យមើលឯកសារនោះទេ ទើបតែនៅពេលក្រោយៗនៅដំណាក់កាលស៊ើបអង្កេតទេទើបគាត់បានឃើញ ។ ហើយគឺវាធ្វើការបែងចែកទៅតាមប្រភេទ តាមបីប្រភេទ គឺឯកសារសម្ងាត់បំផុត ។ ទីពីរ គឺឯកសារផ្ទៃក្នុងរបស់បក្សដូចជាលក្ខន្តិកៈជាដើម ហើយបើសិនជាយើងមិនមែនជាសមាជិកពេញលេញ សមាជិកពេញសិទ្ធិរបស់បក្សនោះទេគឺថា យើងមិនអាចអាន ឬក៏ពិភាក្សាឯកសារទាំងនោះបានទេ ។ ហើយចំណុចចុងក្រោយ គឺជាឯកសារចំហ ដូចជាទស្សនាវដ្តីទង់យុវជន ទង់បដិវត្តន៍ រដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ ហើយនិងការផ្សព្វផ្សាយតាមវិទ្យុ ។ ហើយគាត់ក៏បានបន្តនិយាយទៀតថា អ្វីដែលគាត់ហើយនិងអ្នកដទៃគឺស្ថានភាពរបស់គាត់ដែលបានធ្វើនោះ គឺអាស្រ័យ គឺធ្វើតាមបញ្ហា ហើយមិនមែនទៅតាមឯកសារដែលមានជាលាយលក្ខណ៍អក្សរនោះទេ ។ អ៊ីចឹង តើលោកមានមតិយោបល់អ្វីទៅលើការលើកឡើងរបស់ជនជាប់ចោទនេះទេ?

[១៥:២៧:២៨]

**ឆៈ** បាទ, គ្រប់រដ្ឋទាំងអស់ជាពិសេសគឺតាមអង្គការធំៗជាច្រើន គឺមានគោលនយោបាយពិតប្រាកដរបស់គេសម្រាប់ការបែងចែកប្រភេទឯកសាររសើប ឬក៏ឯកសារសម្ងាត់នោះ ។ លក្ខណៈពិសេសមួយដែលយើងបានកត់សម្គាល់ឃើញអំពីបក្សកុម្មុយនីស្តកម្ពុជា ហើយនិងការទាក់ទងនៅក្នុងបក្សកុម្មុយនីស្តកម្ពុជានោះគឺថា ពួកគេមាននយោបាយដ៏តឹងរ៉ឹងបំផុតមួយទាក់ទងទៅនឹងភាពសម្ងាត់

សម្រាប់ទៅលើប្រធានបទជាច្រើន ហើយជាការពិតណាស់ដូចជាសម្រាប់រយៈពេលពីរឆ្នាំកន្លះ ដែលថា រដ្ឋនេះបានឡើងកាន់អំណាចនោះគឺថា ពួកគេបានបដិសេធមិនព្រមទទួលស្គាល់ថា បក្សកុម្មុយនីស្តកម្ពុជាហ្នឹងគឺថាមានអាទិភាពទេ ។ នេះជាការធ្វើដើម្បីរក្សានូវភាពសម្ងាត់របស់ខ្លួនឯងដែលមិនដែលមានទេនៅក្នុងប្រវត្តិសាស្ត្រពីមុនមកទាក់ទងទៅនឹងបក្សកុម្មុយនីស្ត ។ ហើយដូច្នេះជាការមួយធ្វើឲ្យភ្ញាក់ផ្អើលបំផុតនៅពេលដែលយើងពិនិត្យមើល បើប្រៀបធៀបទៅនឹងបក្សកុម្មុយនីស្តដទៃទៀតនៅលើពិភពលោក។

ដូច្នេះយើងអាចមើលឃើញថា ជាភាពប្រាកដប្រជាណាស់ដែលថា បក្សកុម្មុយនីស្តកម្ពុជាប្រាកដជាមានប្រព័ន្ធមួយក្នុងការធ្វើការបែងចែកព័ត៌មានរសើប ឬក៏ព័ត៌មានសង្ខេប ។ ហើយអ្វីដែលជនជាប់ចោទបានលើកឡើងទៀតនោះគឺថា ខ្ញុំមិនបានដឹងពីគោលនយោបាយទាំងអស់នោះទេ ។

**ស៖** សូមអរគុណ ។ ជនជាប់ចោទក៏បាននិយាយដែរថានៅក្នុងចម្លើយរបស់គាត់គឺថា ទាក់ទងទៅនឹងនយោបាយនៃការកម្ទេចគឺថា មិនបានធ្វើតាមរយៈតុលាការទេ ។ តើលោកឯកភាពទៅនឹងការលើកឡើងនេះទេ?

[១៥:២៩:៣៧]

**ឆ៖** បាទ, ដូចដែលខ្ញុំបានស្នើឡើងថាអ៊ីចឹង នៅពេលដែលលោកបាននិយាយអំពីទាក់ទងទៅនឹងតុលាការ ទាក់ទងទៅនឹងរដ្ឋធម្មនុញ្ញនោះគឺថាមិនមានភស្តុតាងអ្វីថា ស្ថាប័នឬក៏តុលាការហ្នឹង កើតមានឬក៏មានអាទិភាពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ លោក អេតឆេសាន់ ។ លោកប្រធាន ខ្ញុំអត់មានសំណួរអ្វីផ្សេងទៀតទេសម្រាប់សួរដល់លោកបណ្ឌិត អេតឆេសាន់ នោះ ។

**ប្រធានអង្គជំនុំ៖**

លោកចៅក្រមផ្សេងទៀត តើមានសំណួរអីត្រូវសួរដល់អ្នកជំនាញរូបនេះទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំចង់ឲ្យមានការបំភ្លឺពីអ្នកជំនាញពាក់ព័ន្ធទៅនឹងសំណួររបស់លោកស្រីចៅក្រម ខាតវ៉ាយថ៍មួយ ទាក់ទងទៅនឹងគោលនយោបាយដែលបានអនុវត្តនៅស-២១ ហើយនិងអង្គហេតុដែលថា គេមិនអាចដោះលែងអ្នកជាប់ឃុំនៅស-២១ បានទេ ។ លោកបាននិយាយអំពីការផ្លាស់ប្តូរ ដែលបានកើតឡើង

នៅក្នុងពេលដែល ណាត ជាប្រធាន ស-២១ ហើយនឹងពេលដែលជនជាប់ចោទក្លាយទៅជាប្រធាននៃមន្ទីរនោះ ហើយនៅពេលដែលលោកនិយាយអំពីស-២១ លោកនិយាយអំពីមន្ទីរសន្តិសុខ ដូចដែលបានលើកឡើង ហើយលោកមិនបាននិយាយឡើងអំពីតំបន់នៅក្រោមមន្ទីរនេះ ដូចជាព្រៃសជាដើម ។

**ស៖** សំណួរទី២របស់ខ្ញុំសុំសួរថា លោកបាននិយាយថាមានការផ្លាស់ប្តូរ ប៉ុន្តែ តាមអ្វីដែលលោកបានដឹងនោះ ក្នុងពេលដែលជនជាប់ចោទកាន់កាប់មន្ទីរនោះ ថាតើមាននរណាគេត្រូវបានគេដោះលែងដែរឬទេ នៅមន្ទីរសន្តិសុខមួយនុ៎ង?

**ឆ៖** សូមអរគុណលោកចៅក្រម ។

នេះគឺជាការបែងចែករវាងស-២១ និងស-២៤ តាមការយល់ដឹងរបស់ខ្ញុំ ស-២៤ គឺស្ថិតនៅក្រោមការអំណាច និងការគ្រប់គ្រងរបស់ជនជាប់ចោទ ហើយវាស្ថិតនៅក្រោមស-២១ ។ ប៉ុន្តែ ដោយសារគណៈពេលដែលស-២១ គឺជាមន្ទីរធ្វើទារុណកម្មនិងសួរចម្លើយ ដែលមានចំនួនមនុស្សតិចណាស់ រស់រានមានជីវិត ។ ស-២៤ វិញ គឺជាមន្ទីរអប់រំ ដែលមានមនុស្សជាច្រើនបានរស់រានមានជីវិតពីមន្ទីរស-២៤ ។ តាមការយល់ដឹងរបស់ខ្ញុំនោះ យើងឃើញមានអ្នកទោស៣ប្រភេទ នៅស-២៤ ។ យើងហៅថាអ្នកទោសស្រាលៗ អ្នកទោសមានកំហុសធ្ងន់ ហើយនិងអ្នកដែលស្ថិតនៅក្នុងជាលក្ខណៈអន្តរការី ហើយដែលអ្នកនៅចន្លោះកណ្តាល បានន័យថា គេអាចក្លាយទៅជាអ្នកដែលមានទោសធ្ងន់ និងទោសស្រាល ។

[១៥:៣៣:៥១]

ស្ថានភាពរស់នៅនៅស-២៤ គឺមានលក្ខណៈអមនុស្សធម៌ មនុស្សទាំងឡាយស្ថិតនៅក្រោមរបបការងារ មិនមានការថែទាំសេវាសុខភាព មិនមានការហូបគ្រប់គ្រាន់ ការវាយតប់ និងការរំលោភបំពានផ្សេងៗ ។ ដើម្បីឲ្យអ្នកប្រភេទទាំងបីនោះស្ថិតនៅក្រោមរបបដ៏មានភាពយ៉ាប់យឺននេះ ។ ប៉ុន្តែ មានមនុស្សជាច្រើនដែលជាអ្នកទោសស្រាលនោះ ត្រូវបានគេដោះលែងចេញពីស-២៤ នៅពេលចុងក្រោយ ហើយបញ្ជូនទៅតាមមន្ទីររបស់គេ ហើយឲ្យធ្វើការទៅតាមការងាររបស់គេ ហើយមនុស្សភាគច្រើននៅក្នុងប្រភេទជាអ្នកទោសធ្ងន់ គឺមិនមានការរស់រានមានជីវិតនោះទេ ។ ដូច្នេះ ប្រសិនបើយើងពិចារណាថា ស-២៤ គឺជាផ្នែកមួយនៃស-២១នោះ យើងអាចយល់ឃើញថា មនុស្សជាច្រើន ដែលយើងតែងតែនិយាយនៅក្នុងស-២១នោះ ទាក់ទងទៅនឹងបុគ្គលទាំងអស់នោះ មនុស្សជាច្រើន គឺបានរស់រានមានជីវិតពីមន្ទីរស-២៤នេះ ។ ថាតើខ្ញុំឆ្លើយតបទៅនឹងសំណួរទី១ របស់លោកចៅក្រមបានគ្រប់

គ្រាន់ដែរឬទេ?

សំណួរទីពីរនោះ គឺវាពាក់ព័ន្ធទៅនឹងការដោះលែងបុគ្គលចេញពីមន្ទីរចម្បង គឺស-២១ បន្ទាប់ពីជនជាប់ចោទក្លាយជាប្រធានស-២១ ។ ថ្មីៗនេះយើងទទួលបានឯកសារថ្មីៗពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំជឿថា វាមិនស្ថិតនៅក្នុងសំណុំរឿងនោះទេនៅពេលនេះ ដែលឯកសារនេះវាធ្វើឲ្យយើងជឿថា ហើយធ្វើឲ្យខ្ញុំជឿថា វាមានករណីមួយចំនួន គឺទាក់ទងទៅនឹងការដោះលែងនៅមន្ទីរស-២១ បន្ទាប់ពីជនជាប់ចោទបានក្លាយទៅជាប្រធានស-២១ ។ យើងឃើញមានករណីមួយ ដែលក្រុមទាហានធំមួយមកពីកងពលត្រូវបានបញ្ជូនទៅស-២១ ។ បីថ្ងៃក្រោយមក ក្រុមដែលបានបញ្ជូនទៅស-២១ ដែលមានជាង១០០ជាងនាក់នោះ គឺមាននៅក្នុងបញ្ជី ប៉ុន្តែត្រូវបានដោះលែង ប៉ុន្តែខ្ញុំអត់មានបញ្ជីនៅទីនេះ ដើម្បីបញ្ជាក់អំពីERNនោះទេ ឬក៏ខ្ញុំមិនមានឯកសារយោងទាក់ទងទៅនឹងចំណុចនេះទេ ប៉ុន្តែចំណុចនេះ វាអាចជាចំណុចដោះបន្ទុកទៅដល់ខាងការពារក្តី ។ អ៊ីចឹងគឺវាទាក់ទងទៅនឹងឯកសារដែលបានបង្ហាញទៅលើចំណុចនេះ នៅពេលនោះ ។

**ស៖** ខ្ញុំមានសំណួរមួយទៀត លោកនិយាយអំពីលទ្ធភាពសម្រាប់មន្ទីរសន្តិសុខក្នុងការចាប់ខ្លួន ខ្ញុំជឿថាចំណុចនេះ គឺជាការតវ៉ាពីជនជាប់ចោទពាក់ព័ន្ធទៅនឹងអង្គហេតុស-២១ ហើយនៅទីនេះ គឺយើងនិយាយអំពីការបែងចែកយ៉ាងច្បាស់អំពីអំណាចក្នុងការឃុំបុគ្គល ហើយនិងអំណាចក្នុងការចាប់ខ្លួនអ្នកទាំងអស់នោះ ។ ថាតើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ? ថាតើវាមានធាតុផ្សំមួយចំនួនជាក់លាក់យ៉ាងម៉េចដែលអាចឲ្យយើងជឿថា ជនជាប់ចោទគឺមានលទ្ធភាពក្នុងការធ្វើការចាប់ខ្លួន? ឬក៏ខ្ញុំសូមប្រើពាក្យថា លោកគិតថាតើវាមានលក្ខណៈដែលថាជនជាប់ចោទមានសិទ្ធិក្នុងការឃុំខ្លួនដែរឬទេ?

[១៥:៣៨:៤៤]

**ឆ៖** វាទាំងពីរតែម្តងលោកចៅក្រម ។ ខ្ញុំសូមលើកឡើង វាប្រហែលជាមិនមានលក្ខណៈច្បាស់លាស់ក្នុងការប្រើពាក្យដូច្នេះ ។ ចំពោះខ្ញុំ ដោយសារតែស-២១ ក្លាយទៅជាមន្ទីរមួយ ហើយវាមានតួនាទី ហើយគេយល់តាមប្រព័ន្ធអង្គការផ្សេងៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ នីតិវិធីសាមញ្ញៗចំពោះបុគ្គលដែលត្រូវយកមកឃុំខ្លួននៅស-២១ គឺអ្នកទាំងអស់នោះ ជាបឋមត្រូវតែរងការឃុំនៅក្នុងអង្គភាពរបស់ពួកគេ ហើយបន្ទាប់មកអង្គភាព ឬក៏អង្គការរបស់អ្នកទាំងអស់នោះនឹងបញ្ជូនអ្នកដែលជាប់ឃុំនៅមន្ទីររបស់គេមក ស-២១ ដែលនៅស-២១នោះ គឺខ្ញុំគួរនិយាយថា មានការបញ្ជូនពីអង្គភាពផ្សេងចូលមកស-២១ ។ នេះគឺជាស្ថានភាពសាមញ្ញធម្មតានៅពេលនោះ ប៉ុន្តែវាមិនមែនតែសេណារីយ៉ូ

ឬក៏ស្ថានភាពតែមួយនោះទេ ។ ឧទាហរណ៍ ជនជាប់ចោទបានរៀបរាប់ ឧទាហរណ៍ និងករណីមួយចំនួនដែលមេដឹកនាំជាន់ខ្ពស់ត្រូវបានចាកចេញ ហើយបានចាកចេញពីទីបរិវេណរបស់ស-២១ ហើយត្រូវបានចាប់ខ្លួន ។ ក្រោយមកអ្នកទាំងអស់នោះត្រូវបានឃុំខ្លួននៅស-២១ ។ ជនជាប់ចោទក៏បានលើកឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា មានករណីមួយយ៉ាងហោចដែលកងកម្លាំងនៅក្រោមការបញ្ជារបស់គាត់ចាកចេញពីទីតាំងស-២១ ដើម្បីធ្វើការចាប់ខ្លួនអ្នកទោសនៅក្នុងអង្គភាពផ្សេងៗ ។ ខ្ញុំជឿថាវាមានករណីជាច្រើនចំពោះការកើតឡើងដូច្នេះ ដែលថា ជនជាប់ចោទបានបង្ហាញនិងរៀបរាប់ទៅលើចំណុចនោះ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ សូមជូនវេទិកានេះដល់តំណាងសហព្រះរាជអាជ្ញា ដើម្បីមានលទ្ធភាពក្នុងការអាចសួរសំណួរដល់លោកបណ្ឌិត អេតធេសាន់ ដែលជាអ្នកជំនាញ ប្រសិនបើមាន ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

[១៥:៤២:៣៩]

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

អរគុណលោកប្រធាន ។ មុនពេលយើងខ្ញុំចាប់ផ្តើមការតាំងសំណួរ ខ្ញុំចង់លើកនូវចំណុចមួយដែលវាមានផលប៉ះពាល់ដោយផ្ទាល់ទៅនឹងការតាំងសំណួររបស់យើងចំពោះសាក្សីអ្នកជំនាញមួយនេះ ហើយវាជាពេលមួយមិនសមស្របក្នុងការលើកឡើងបញ្ហានេះ ។

បណ្ឌិត អេតធេសាន់ ឯកសារ១៤៨នៅក្នុងរបាយការណ៍របស់គាត់ ហើយមានការយោងនៅក្នុងបញ្ជីលេខ៤ ដូចដែលអង្គសវនាការបានជ្រាប ហើយរំឭកយើងខ្ញុំជាច្រើនដង ច្រើនសាហើយនោះ ។ តាមវិធាន៨៧(២)-- (ខ្ញុំហាក់ដូចជាឮសំឡេងរំខានតាមរយៈកាសរបស់ខ្ញុំ វាហាក់ដូចជាបញ្ឈប់ហើយនៅពេលនេះ) ។

តាមវិធាន៨៧(២) មានតែភស្តុតាងដែលដាក់ចំពោះមុខអង្គសវនាការ ហើយស្ថិតនៅក្រោមការដេញដោលតែប៉ុណ្ណោះ ដែលអាចប្រើប្រាស់ក្នុងការគាំទ្រទៅលើសាលក្រមស្ថាពរ ។ ហើយបន្ថែមទៅលើចំណុចនេះ វិធាន៨៧(៣) ក្នុងករណីដែលអង្គសវនាការបញ្ជាក់ក្នុងពេលសវនាការ ឧទាហរណ៍តម្រូវឲ្យយើងធ្វើការសង្ខេបនិងអានក្នុងតុលាការ ទើបឯកសារភស្តុតាងទាំងអស់នោះ បានដាក់ត្រឹមត្រូវ ។ វិធានផ្ទៃក្នុងមិនមានសេចក្តីណែនាំទាក់ទងទៅនឹងលក្ខណៈនៃការអនុវត្តមួយចំនួន ទាក់ទងទៅ

នឹងភស្តុតាង ថាតើភស្តុតាងនោះ គួរតែអាន និងធ្វើការសង្ខេបតាមរបៀបណា?

សហព្រះរាជអាជ្ញា ដូច្នេះស្នើសុំឲ្យមានការណែនាំពីអង្គសវនាការទៅលើករណីនេះ ដោយសារតែបញ្ហានេះ វាមានផលប៉ះពាល់ដោយផ្ទាល់ទៅលើវិធីសាស្ត្រ និងរបៀបនៃការសួរសំណួររបស់យើងខ្ញុំទៅកាន់អ្នកជំនាញមួយនេះ ហើយចំពោះសាក្សីផ្សេងៗទៀត យើងខ្ញុំក៏គិតថាមានការផ្តល់នូវឯកសារជាច្រើនផងដែរ ។ យើងខ្ញុំមានសេចក្តីសន្និដ្ឋានមួយ ឬក៏ពីរទៀត និងការស្នើសុំការស្នើឡើងទៅលើបញ្ហានេះផងដែរ ។

[១៥:៤៥:២០]

ប្រសិនបើខ្ញុំជាបឋមអាចលើកឡើងនៅក្នុងអង្គសវនាការរៀបចំកាលពីឡើងមុននៅថ្ងៃទី១៥ ខែមករា លោកចៅក្រម ឡាវ៉ែន៍ គឺបានលើកឡើងអំពីការអនុវត្តដែលបានបញ្ជាក់ថាភាគីធ្វើការណែនាំភស្តុតាង និងបង្ហាញភស្តុតាងតាមរយៈវិធាន៨៧ ហើយតាមលោកចៅក្រមបានបញ្ជាក់ថា ភាគីត្រូវតែបង្ហាញគោលបំណងរបស់ខ្លួនទាក់ទងទៅនឹងការប្រើប្រាស់សេវាតុលាការ ដើម្បីបំពេញទៅតាមបញ្ហាបច្ចេកទេស ។ ហើយនៅក្នុងការប្រជុំរៀបចំសវនការនៅថ្ងៃទី១៥ ខែមករា ទំព័រទី៦៥ ជួរ១១ ដល់ ១៨ លោកចៅក្រមបានបន្តនិយាយថា ការរៀបចំនូវឯកសាររឹង ហើយការបង្ហាញអំពីផ្នែកមួយណានៃឯកសារដែលចង់យោងនោះ ។ល។ និង ។ល។ ដោយមើលទៅលើគោលបំណងនោះ ចំពោះសហព្រះរាជអាជ្ញា គឺវាជាការស្នើសុំទៅដល់ភាគីឲ្យផ្តល់ឯកសារថតចម្លងចំពោះគ្រប់ឯកសារទាំងអស់ ដែលភាគីមានបំណងក្នុងការយកមកធ្វើការដេញដោល និងធ្វើការយកមកធ្វើការជាសំអាងនៅក្នុងតុលាការ។ នៅពេលនេះ យើងនៅចំពោះមុខអង្គសវនាការ ស្នើសុំធ្វើការតាំងសំណួរទៅកាន់បណ្ឌិត ក្រេក អេតធេសាន់ ។

សហព្រះរាជអាជ្ញា សូមស្នើសុំសេចក្តីណែនាំពីអង្គសវនការ ថាតើយើងអាចដាក់ឯកសារនៅចំពោះមុខសវនាការដោយរបៀបណា? ជាការពិត គឺការអានឯកសារ១៤៨នោះ ដែលមាននៅក្នុងរបាយការណ៍ គឺយើងនឹងចំណាយពេលរហូតទៅដល់មួយអាទិត្យ ហើយប្រសិនបើយើងស្នើសុំឲ្យមានការអានទៅលើសេចក្តីសង្ខេបនៃឯកសារនីមួយៗ ដែលលោក ក្រេក អេតធេសាន់ យកមកធ្វើជាសំអាងទាំងអស់នោះ យើងនឹងនៅក្នុងពេលនេះ ចំណាយពេលជាច្រើនម៉ោងទោះបីវាមិនចំណាយពេលច្រើនថ្ងៃក៏ដោយ ហើយវាជាការពន្លឿន និងភាពជាផលប្រយោជាចំពោះការជំនុំជម្រះ ។ សហព្រះរាជអាជ្ញាសូមស្នើឡើងថា ខ្ញុំសូមស្នើសុំឲ្យអង្គសវនាការធ្វើការពិចារណានៅក្នុងដំណាក់កាលនេះដោយយើង

ពិចារណាថា វាមានភាពសំខាន់ក្នុងការពិចារណាទៅលើករណីនេះ មុនពេលភាគីធ្វើការតាំងសំណួរទៅកាន់សាក្សីអ្នកជំនាញ ដែលសាក្សីនេះមានឯកសារជាច្រើនដែលគាត់ត្រូវយោង ។

សហព្រះរាជអាជ្ញា សូមស្នើសុំចំណុចក្នុងការអនុវត្តនៅទីនេះ ដូចតទៅៈ

ជាបឋម ភាគីណាក៏ដោយ នៅពេលដែលខ្លួនមានបំណងចង់ផ្អែកទៅលើឯកសារ ដោយយើងអនុលោមទៅតាមវិធាន៨៧(២) និង(៣) គួរតែដាក់ជូនឧបសម្ព័ន្ធនៃឯកសារទាំងអស់នោះ ដែលឧបសម្ព័ន្ធនោះ វាមានសេចក្តីសង្ខេបជាលាយលក្ខណ៍អក្សរនៃឯកសារទាំងអស់នោះ ។

[១៥:៤៩:១០]

ហើយសហព្រះរាជអាជ្ញាសូមស្នើសុំ សូមស្នើឡើងថាសេចក្តីសង្ខេបដោយផ្ទាល់មាត់ត្រូវតែធ្វើឡើងនៅក្នុងតុលាការ ទៅតាមប្រភេទឯកសារ ជាជាងការសង្ខេប ឬក៏ការអានសេចក្តីសង្ខេបទៅលើគ្រប់ឯកសារទាំងអស់ ។ តើខ្ញុំអាចបង្ហាញទៅលើរបាយការណ៍របស់លោក ក្រេក អេតឆេសាន់ បានលើកឡើងដែរឬទេ? ថាតើយើងមានន័យយ៉ាងម៉េច? យើងមានឯកសារ១៤៨ឯកសារ ។

ឯកសារពីរដំបូង គឺវាជាឯកសាររបាយការណ៍វិភាគ ហើយឯកសារប្រាំបន្ទាប់ទៀត គឺទាក់ទងទៅនឹងប្រវត្តិរូប ហើយឯកសារបួនទៀត គឺសៀវភៅ ដែលមានចម្លើយសារភាពម្ភៃបួន មានសេចក្តីបង្គាប់ចំនួនពីរ ឯកសារច្បាប់ពីរ ។ល។ និង ។ល។

សហព្រះរាជអាជ្ញាសូមស្នើសុំថា ដោយសារតែឧបសម្ព័ន្ធទាំងអស់នេះ បានដាក់ជូនអង្គសវនាការសាលាដំបូងរួចហើយនោះ ហើយបានចែកជូនទៅគ្រប់ភាគីទាំងអស់រួចហើយ យើងគួរតែស្នើសុំឲ្យមានការសង្ខេបទៅលើប្រភេទនៃឯកសារ ដែលនឹងយកមកធ្វើការអានដូចសហព្រះរាជអាជ្ញា ដើម្បីយើងអនុលោមទៅតាមវិធាន៨៧.២ និង(.៣) ។ ខ្ញុំសូមលើកឡើងនៅក្នុងការសង្កេតមួយ ឯកសារគឺដកស្រង់និងដេញដោយមួយៗ ដោយអ្នកជំនាញមួយនេះនៅក្នុងសវនាការ ហើយវាមានសារសំខាន់ក្នុងការធ្វើដូច្នេះ គឺថាភាគីគាត់ត្រូវតែដឹងថា ឯកសារមួយណាដែលអាច ហើយវាផ្អែកនៃឯកសារដែលត្រូវយកមកធ្វើជាសំអាងនៃសាលក្រមស្ថាពរ ។ ហើយប្រសិនបើយើងត្រូវពិនិត្យលើឯកសារគ្រប់ទាំងអស់របស់អ្នកជំនាញនោះ យើងនឹងចំណាយពេលយ៉ាងច្រើនឥតគណនាក្នុងការពិនិត្យលើឯកសារទាំងអស់នោះ។

សំណើរបស់ខាងយើងខ្ញុំ ដែលចង់ដាក់ជូននេះគឺថា នៅក្នុងករណីទីមួយ អង្គសវនាការសាលាដំបូងបានទទួលយកឧបសម្ព័ន្ធរួចហើយ ចំពោះឯកសារគាំទ្រទាំងឡាយ ហើយប្រសិនបើភាគីទាំងឡាយមានការជំទាស់ទៅលើឯកសារទាំងអស់នោះ ដែលគេយកមកប្រើសម្រាប់ផ្អែកទៅលើសាលក្រមស្ថាពរ

នោះ ដូច្នេះ ភាគីគួរតែធ្វើការលើកឡើងអំពីការជំទាស់នោះ ហើយការជំទាស់នោះអាចយកមកធ្វើការដេញដោលនៅចំពោះមុខភាគី ។

ហើយប្រសិនបើខ្ញុំអាចផ្តល់ឧទាហរណ៍ដោយសង្ខេបមួយនៅក្នុងការពិភាក្សាដេញដោលផ្លូវការមួយដែលបានធ្វើឡើងរវាងសហព្រះរាជអាជ្ញា និងខាងការពារក្តី ពាក់ព័ន្ធទៅនឹងក្រុមនៃឯកសារមួយក្រុម គឺទាក់ទងទៅនឹងរបាយការណ៍សារព័ត៌មាននោះ ។ ឯកសារទាំងអស់នេះ គឺវាមានចំនួន រាប់រយ ហើយយើងឃើញមានសេចក្តីសង្ខេប ទៅលើរបាយការណ៍សារព័ត៌មាននីមួយៗបន្ថែមទៀត ។ វាបង្ហាញថា ខាងការពារក្តីហាក់ដូចជាមិនមានជំទាស់ជាគោលការណ៍ចំពោះចំនួនសរុបនៃរបាយការណ៍សារ-ព័ត៌មានទាំងអស់នោះ ដែលត្រូវតែធ្វើសង្ខេបជាងមួយទំព័រ ។

[១៥:៥៣:៣២]

ជាគោលការណ៍ នេះគឺវាជាគោលការណ៍ដែលសហព្រះរាជអាជ្ញាចង់យក ចង់ធ្វើការឲ្យមានការអនុវត្តដូច្នេះចំពោះឯកសារផ្សេងៗ ដើម្បីយើងពិនិត្យនិងពិចារណាទៅលើឯកសារនៅចំពោះអង្គសវនាការ ដូចដែលខ្ញុំបានលើកឡើងប៉ុន្មាននាទីមុននេះ ប្រសិនបើអង្គសវនាការសាលាដំបូងពិចារណាភាពចំបាច់ក្នុងការមានប្រសិទ្ធភាព និងពន្លឿនទៅលើឯកសារទាំងអស់នៅក្នុងសំណុំបែបនេះ ។ ហើយដោយយើងពិចារណាទៅលើករណីដែលថា ភាគីគាត់មានសិទ្ធិក្នុងការជំទាស់ទៅលើឯកសារជាក់លាក់ណាមួយផងនោះ សិទ្ធិនៃការជំនុំជម្រះដោយយុត្តិធម៌ត្រូវតែរក្សាឲ្យបាន ហើយភាគីគាត់មានសិទ្ធិក្នុងការពិនិត្យសំណុំរឿងនៅក្នុងនីតិវិធីផងដែរ ។

ខ្ញុំសូមអភ័យទោស ក្នុងការចំណាយពេលវេលាក្នុងការពន្យល់ដូច្នេះ ប៉ុន្តែវាជាភាពចាំបាច់ក្នុងការដាក់សេចក្តីសន្និដ្ឋាននេះ ជាលាយលក្ខណ៍អក្សរផងដែរ ។ ហើយសេចក្តីសន្និដ្ឋានចំពោះការឆ្លើយតបនេះ ខ្ញុំយល់ឃើញថា សេចក្តីសន្និដ្ឋានតបនោះគួរតែដាក់នៅចុងថ្ងៃនេះ ឬក៏ថ្ងៃស្អែក ។ ប៉ុន្តែ ខ្ញុំសូមលើកឡើងថា នៅពេលប្រសិនបើអង្គសវនាការសម្រេចថា មានតែឯកសារដែលយកមកដេញដោលនៅចំពោះអង្គសវនាការ អាចជាមូលដ្ឋាននៃសាលក្រមនោះ ។ បើសិនដូច្នេះមែន គឺសហព្រះរាជអាជ្ញាត្រូវតែធ្វើការពិនិត្យគ្រប់ឯកសារទាំងអស់របស់លោក ក្រេក អេតធេសាន់ ហើយធ្វើដូច្នេះវាហាក់ដូចជាមានលទ្ធភាពនិងទម្ងន់តិចតួច ហើយវាអាចឲ្យយើងធ្វើការពិចារណាទៅលើគុណសម្បត្តិការងារ និងជំនាញរបស់គាត់នៅទីនេះ ។

ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំលើកឡើងគឺមានលក្ខណៈច្បាស់លាស់ ហើយប្រសិនបើអង្គសវនាការមាន

ចម្ងល់ផ្សេងៗនោះ ខ្ញុំអាចផ្តល់ជូនបាន ។ អ៊ីចឹងខ្ញុំសូមលើកដូច្នេះ មុនពេលដែលយើងបន្តនីតិវិធីក្នុងការតាំងសំណួរ ។

**ប្រធានអង្គជំនុំ៖**

មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី តើមានមតិយោបល់អ្វីទេ ដែលពាក់ព័ន្ធជាមួយនឹងមតិយោបល់ដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ? បើមានសូមអញ្ជើញ ។

[១៥:៥៦:៤០]

**លោក អាឡាំង វ៉ែនណឺ៖**

លោកប្រធាន សម្រាប់ក្រុមខ្ញុំ ខ្ញុំយល់ថា ជាការត្រឹមត្រូវណាស់ ប្រសិនបើសិនជាលោកប្រធានចង់ឲ្យយើងបង្ហាញពីគោលជំហររបស់យើងជាលម្អិត ថាតើដំណើរការនីតិវិធីហ្នឹង គឺថាយើងត្រូវធ្វើយ៉ាងម៉េចនោះ គឺថាខ្ញុំនឹងអាចធ្វើបាន ។ ប៉ុន្តែ វានឹងអាចស៊ីពេល ប្រហែលជាព្រឹកស្អែកហ្នឹង អាចយើងជាពេលដែលថាយើងលើកឡើងបានលឿនអំពីចំណុចនេះ ។ នេះជាចំណុចដែលខ្ញុំអាចលើកឡើងនិយាយជម្រាបប្រាប់លោកចៅក្រមនៅពេលនេះ ។

**លោកស្រី ស៊ីលយ៉ីស្នូត ហ្សីនស្គី៖**

អរគុណលោកប្រធាន។ ខ្ញុំក៏ចង់និយាយផងដែរទាក់ទងទៅនឹងការសេចក្តីសន្និដ្ឋាន ការដាក់ជូនជាលាយលក្ខណ៍អក្សរ ទាក់ទងទៅនឹងគោលជំហររបស់យើងឲ្យបានលម្អិត ។ ហើយគឺថា យើងអាចធ្វើបានដោយផ្ទាល់មាត់ ក៏ប៉ុន្តែយើងខ្ញុំនឹងមានគោលជំហរដើម្បីគាំទ្រដល់ខាងសហព្រះរាជអាជ្ញាទាក់ទងទៅនឹងថាតើយើងធ្វើការបង្ហាញភស្តុតាង ឬក៏ឯកសារយ៉ាងម៉េចនៅចំពោះមុខអង្គសវនាការ? តើយើងត្រូវតែដោះស្រាយបញ្ហានេះឲ្យបានច្បាស់ មុននឹងយើងចាប់ផ្តើមធ្វើការសាកសួរដល់សាក្សីដែលជាអ្នកជំនាញនោះ? សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីក្រុមបី បន្ទាប់ទៀតណ៎ា ។

**លោកស្រី អេលីហ្សាប៉ែត រ៉ាបេសាន់ជ្រាតាណា៖**

ខ្ញុំបានឯកភាពទៅនឹងការកត់សម្គាល់មើល របស់មេធាវីនៅក្នុងក្រុមទីមួយ ទីពីរ ទាក់ទងទៅនឹងអ្វីដែលបានលើកឡើងដោយខាងសហព្រះរាជអាជ្ញា ។ ហើយខ្ញុំយល់ថា មានហេតុផលសមរម្យ ក៏ប៉ុន្តែខ្ញុំមានការកត់សម្គាល់មួយដែលខ្ញុំចង់ធ្វើឡើង ដែលខ្ញុំយល់ថាជាចំណុចសំខាន់មួយទាក់ទងទៅនឹងការ

ការពារសិទ្ធិរបស់ជនរងគ្រោះ ។ នៅក្នុងចម្លើយរបស់សាក្សីដែលជាអ្នកជំនាញ នៅពេលដែលគាត់បានឆ្លើយទៅនឹងសំណួររបស់លោកចៅក្រម ឡាវែន៍ គឺថាទាក់ទងទៅនឹងការដោះលែងទោសនៅ ស-២១ នោះ គាត់បានឆ្លើយដោយយោងទៅលើឯកសារដែលទទួលបានមកពីមជ្ឈមណ្ឌលឯកសារម្ពុជា (Dc-Cam) ជាឯកសារដែលមិនបានបញ្ចូលនៅក្នុងសំណុំរឿង ក៏ប៉ុន្តែ អ្នកជំនាញបាននិយាយថា គាត់បាននិយាយជាមួយខាងមេធាវីការពារក្តី ថានេះមិនមែនជាបញ្ហាទេ ពីព្រោះនេះគឺជាភស្តុតាងដោះបន្ទុក ប៉ុន្តែខ្ញុំចង់និយាយថា នេះគឺជាបញ្ហាសម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនេះ ។ ហើយនេះគឺជាការបង្ហាញនូវកង្វះខាតនៃការគោរពសិទ្ធិនៅក្នុងការបង្ហាញឯកសារដែលមិននៅក្នុងសំណុំរឿង ។

[១៦:៥៩:៥០]

ដូច្នេះ គឺថាមានន័យថាយើងគ្មានសិទ្ធិក្នុងការធ្វើការជំទាស់ទេ ព្រោះឯកសារនោះអត់មានអត្ថិភាពនៅក្នុងសំណុំរឿងនៅឡើយទេ។ ក៏ប៉ុន្តែ នេះអាចជាប្រយោជន៍មួយសម្រាប់ខាងមេធាវីការពារក្តី ។ ប៉ុន្តែ យើងនៅទីនេះ គឺយើងនៅទីនេះ គឺជាសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ជនរងគ្រោះ ។ ហើយខ្ញុំជឿថា យើងគួរតែមានការគោរពនូវអញ្ញាក្រឹត្យទៅវិញទៅមក ហើយយើងត្រូវអនុវត្តទៅតាមវិធានដូចគ្នា ។ ដូច្នេះ ថាតើយើងត្រូវធ្វើយ៉ាងម៉េចទាក់ទងទៅនឹងឯកសារដែលចង់ធ្វើការបង្ហាញនោះ? ហើយនិងទៅចំណុចផងដែរ ថាតើយើងគួរតែធ្វើការបដិសេធទៅលើឯកសារដែលមិនបានបង្ហាញយ៉ាងម៉េចផងដែរ? ពីព្រោះគឺថាការពិភាក្សាដេញដោលនេះ គឺមានឥទ្ធិពលទៅលើចំណុចទាំងអស់ ។

ដូច្នេះហើយខ្ញុំមិនអាចនិយាយអំពីចំណុចនេះទេ ពីព្រោះអី មានន័យថា ឯកសារហ្នឹងមិនមាននៅក្នុងសំណុំរឿងនោះទេ ។ អ៊ីចឹងខ្ញុំសង្ឃឹមថា លោក លោកស្រីចៅក្រម បានយល់ដឹងអំពីបញ្ហាដែលខ្ញុំមានហើយ ។ អ៊ីចឹងខ្ញុំជឿថា នេះគឺមានន័យថា សិទ្ធិរបស់យើងហ្នឹង ត្រូវបានគេមិនអើពើ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ។ បើសិនជាមានមតិយោបល់កត់សម្គាល់ពាក់ព័ន្ធបញ្ហានេះ សូមអញ្ជើញ ។

**លោក ហុង គឹមសួន៖**

ខ្ញុំបាទសូមអរគុណ លោកប្រធានជាទីគោរព!

ក្នុងនាមខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រចាំក្រុមទីបួន ។ ខ្ញុំបាទ មិនមានជាបញ្ហាធំដុំសម្រាប់លើកឡើងទេ តែខ្ញុំបាទសុំគាំទ្រទៅដល់ខាងការលើកឡើងរបស់សហព្រះរាជអាជ្ញា ដែលលោកលើក

ឡើងអំពីបំណាង និងបង្ហាញ ឬការអានឯកសារទាំង១៤៨ នោះ ។ ដូច្នេះ ជាកង្វល់ទៅវិញទេ ដែលខាងខ្ញុំបាទគិតហើយថា បើសិនជាអានឯកសារទាំងអស់ ។ ទីមួយគឺប្រើពេលយូរ ។ ទីពីរ ខាងមេធាវីការពារ គាត់បានមានប្រសាសន៍មកហើយថា ឯកសារខ្លះដែលលោកមិនទាន់បានដឹងមុន គឺមានការពិចារណា ឬជំទាស់ ។ ហេតុនេះ ជាមតិរបស់ខ្ញុំបាទ គឺសុំឱ្យលោកប្រធានសម្រេចថាតើ សម្រេចយកឯកសារណាខ្លះ? ឬឱ្យអានតែចំណុចមាន ERN ដូច្នេះច្បាស់លាស់ ដើម្បីខាងយើងខ្ញុំក៏នឹងមានការកត់សម្គាល់ និងមានសំណួរខ្លះៗ ទៅក្នុងនោះទៅលោកជំនាញផងដែរ ។ ដូច្នេះ សុំលោកប្រធានមេត្តាសម្រេចឱ្យបានច្បាស់ ។ សូមអរគុណ ។

[១៦:០៣:០០]

**ប្រធានអង្គជំនុំ៖**

មេធាវីការពារ តើមានអ្វីត្រូវកត់សម្គាល់ ឬឆ្លើយតបនឹងការលើកឡើងរបស់ភាគីតំណាងសហព្រះរាជអាជ្ញា និងមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ?

បើមានសូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកប្រធាន ។

លោកប្រធាន លោក លោកស្រីចៅក្រម ។ កាលពីសប្តាហ៍មុនសហសេវិករបស់ខ្ញុំ គឺកញ្ញា ស្វូត ហ្សីនស្តី ហើយនិងលោក ខារីម ខាន ហើយនិងខ្លួនខ្ញុំផ្ទាល់ បានចូលរួមនៅក្នុងអង្គសិក្ខាសាលាមួយទាក់ទងទៅនឹងអង្គតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយមានវត្តមានចៅក្រមផ្សេងៗគ្នា ហើយនិងបុគ្គលិកផ្នែកច្បាប់មួយចំនួនទៀត រួមបញ្ចូលទាំងលោក ហ្គោល ស្ទូន ផង ។ ហើយខ្ញុំបាននិយាយ ហើយបាននិយាយថា ខ្ញុំមានសុបិនមួយ ។ ខ្ញុំសុបិនថានៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ សហព្រះរាជអាជ្ញាព្រះរាជអាជ្ញា គឺជាអ្នកដែលមានឋានៈនៅខ្ពស់លើយើង ដោយមានឯកសារបើជាច្រើនដែលជាឯកសារមិនចាំបាច់ ។

កាលពីដប់ឆ្នាំមុន គឺពេលនោះ មានន័យថាខ្ញុំធ្វើការនៅក្នុងព្រហ្មទណ្ឌអន្តរជាតិនេះ វាជាងដប់ឆ្នាំមកហើយ គឺថារឿងហេតុនោះវាដូចៗតែគ្នា ។ គឺមានន័យថា ឯកសាររាប់រយដែលមិនមានអត្ថ-ប្រយោជន៍អ្វីបន្តិចសោះ ដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការនីតិវិធីរបស់តុលាការ ដែលជាធ្វើឱ្យដាក់សម្ពាធទម្ងន់មកលើខាងផ្នែកសេវាបកប្រែ ពីព្រោះគឺថាមិនមានចំណុចសំខាន់អ្វីទេដែលខាងសហព្រះ

រាជអាជ្ញាបានកំណត់ទៅលើឯកសារទាំងនោះ។ ថាតើអ្វីទៅដែលវាសំខាន់បំផុត អ្វីដែលមិនសំខាន់នោះ? ហើយឥឡូវនេះ គឺថាយើងប្រឈមមុខនឹងបញ្ហាដូចគ្នាដដែល ។

[១៦:០៥:៣៩]

នៅពេលដែលយើងធ្វើការពិចារណាថា ឯកសារដែលខាងសហព្រះរាជអាជ្ញាចង់យកមកបង្ហាញនៅក្នុងមុខអង្គសវនាការ ទាក់ទងទៅនឹងរបាយការណ៍របស់លោក ក្រេក អេតធេសាន់ នោះ គឺធ្វើឲ្យយើងមានការវិលមុខណាស់ ។ តើយើងពិតប្រាកដជាត្រូវការឯកសារអស់ហ្នឹងមែន ឬក៏យ៉ាងម៉េច? គឺថាយើងមានអ្នកជំនាញហើយឥឡូវនេះ ហើយគាត់គឺថាត្រូវធ្វើកិច្ចការមួយចំនួន ហើយដែលត្រូវផ្តល់នូវមតិយោបល់ជំនាញរបស់គាត់ ។ តើអ៊ីចឹងយើងត្រូវការឯកសារយោងអស់ទាំងហ្នឹងឬ? នេះគឺជាអត្តចរិតមួយដ៏មិនល្អសោះ ដែលបានរាលដាលនៅក្នុងតុលាការអន្តរជាតិនានា ហើយអត្តចរិតបែបហ្នឹងគឺជាការទទួលខុសត្រូវចំពោះការពន្យារពេលនៅក្នុងដំណាក់កាលនីតិវិធីនៃតុលាការព្រហ្មទណ្ឌនានា ។ នៅក្នុងប្រព័ន្ធច្បាប់របស់ខ្ញុំនេះ ខ្ញុំត្រូវបានបង្រៀននូវគោលការណ៍សំខាន់ចំនួនបី គឺការបង្ហាញប្រកាសឲ្យបានច្បាស់លាស់ ឲ្យបានប្រាកដប្រជា ហើយនិងធ្វើអ្វីបានជាក់លាក់ ។

ដូច្នេះ បើខ្ញុំនៅតែទទូចថា បើសិនជាមានការទទូចថាឲ្យធ្វើការបង្ហាញឯកសារ ដោយមិនមានធ្វើការបែកចែកប្រភេទឯកសារទាំងអស់ទេនោះ គឺយើងមិនមានអ្វីច្បាស់លាស់ ឬក៏មិនប្រាកដប្រជា ឬក៏ច្បាស់លាស់នោះទេ ។ ហើយដោយសារខ្ញុំឥឡូវនេះ លើកឡើងអំពីចំណុចនេះ ជម្រាបប្រាប់ទៅដល់លោក លោកស្រីចៅក្រម ដែលមានជំនាញផ្នែកតុលាការនោះ គឺថាខ្ញុំយោងទៅលើវិធាន៨៥ នៃវិធានផ្ទៃក្នុងបន្ទាប់ពីបានពិភាក្សាគ្នាជាមួយនឹងចៅក្រមផ្សេងៗគ្នាទៀត ។ ខ្ញុំនឹងចាប់ផ្តើមពីវគ្គដំបូង គឺទាក់ទងទៅនឹងការដឹកនាំសវនាការ ។ ប្រធានអង្គជំនុំជម្រះសាលាដំបូង ត្រូវដឹកនាំកិច្ចដំណើរការនីតិវិធី និងជួយសម្រួលដល់ការធ្វើអន្តរាគមន៍របស់ចៅក្រមផ្សេងទៀត ។ ប្រធានអង្គជំនុំជម្រះសាលាដំបូង ត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឲ្យប្រព្រឹត្តទៅបានដោយសេរី ។ ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត ប្រធានសវនាការអាចបដិសេធនូវរាល់នីតិវិធីដែលនាំឲ្យមានការពន្យឺតពេលដល់ការជំនុំជម្រះ និងដែលមិនអាចនាំទៅដល់ការស្វែងរកការពិត ។

ខ្ញុំគិតថា ដំណោះស្រាយគឺថា ងាយស្រួលនឹងពិនិត្យនៅក្នុងកថាខណ្ឌនេះ ។ ប្រសើរជាងនៅក្នុងសំណើដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះ គឺពួកគាត់បានប្រាប់យើងថា ឯកសារហ្នឹងមានចំនួន១៤៧ ប៉ុន្តែគឺគេនិយាយតែពីចំនួនឯកសារទេ គឺគេមិនទាន់និយាយពីចំនួនទំព័រនៃឯកសារអស់ទាំង

នុ៎ងទេ ។ មានន័យថា គឺមានចំនួនច្រើនណាស់ គឺហ្នឹងមានចំនួនជាច្រើនរយទំព័រ ហើយថាបើសិនជាខាងសហព្រះរាជអាជ្ញាមិនត្រូវបានទទួលការណែនាំធ្វើការបែងចែកប្រភេទឯកសារហ្នឹង តើឯកសារណាសំខាន់ ឬក៏ឯកសារណាយើងអាចទាត់ចោទបាននោះ?

[១៦:១០:១៧]

ដូចខាងសហព្រះរាជអាជ្ញាបានលើកឡើងអ៊ីចឹង គឺថាយើងបានឯកភាពគ្នាថា ទាក់ទងទៅនឹងអត្ថបទសារព័ត៌មាន ដែលខាងសហព្រះរាជអាជ្ញា ចង់ធ្វើការបង្ហាញនៅចំពោះមុខអង្គសវនាការនោះ ទាក់ទងទៅនឹងជម្លោះប្រដាប់អាវុធ គឺមានន័យថា មិនគួរឱ្យត្រូវបកប្រែពេញលេញចំពោះអត្ថបទសារ-ព័ត៌មានជាងពីររយនោះទេ ។ ពីព្រោះគឺថាវាអត់មានសារប្រយោជន៍អ្វីបន្តិចសោះ ។ ហើយខ្ញុំបាននិយាយប្រាប់ទៅខាងការិយាល័យសហព្រះរាជអាជ្ញាថា ផ្ដល់សេចក្ដីសង្ខេបទៅតែមួយទំព័រមកឱ្យខ្ញុំបាន ហើយក្នុង-- ដកស្រង់តែមួយទំព័របានហើយ ពីអត្ថបទសារព័ត៌មានទាំងពីររយជាងនោះ ។ ប៉ុន្តែ អ្វីដែលខ្ញុំចង់បាននោះ គ្រាន់តែសុបិនតែប៉ុណ្ណោះ ពីព្រោះសេចក្ដីសុបិនរបស់ខ្ញុំគឺថាខាងសហព្រះរាជអាជ្ញា បើសិនជាបើមិនចាំបាច់ធ្វើការបង្ហាញអត្ថបទជាងពីររយនោះ គឺថាជ្រើសរើសតែអត្ថបទសារព័ត៌មានណាដែលសំខាន់បំផុត ហើយចៀសវាងដាក់បញ្ចូលឯកសារដ៏ច្រើនដែលជាឯកសារមិនសំខាន់បំផុត ហើយដែលមិនចាំបាច់នោះ គឺជាឯកសារដដែលៗនោះ ។ ហើយនិយាយឱ្យត្រង់ទៅ ថាតើយើងត្រូវការអត្ថបទសារព័ត៌មានពីររយឬ? ដើម្បីឱ្យដឹងថាមានជម្លោះប្រដាប់អាវុធ រវាងកម្ពុជានិងវៀតណាមនោះ? ពិតមែនឬ? ថាតើអង្គសវនាការនេះត្រូវការអត្ថបទសារព័ត៌មានចំនួនពីររយឬ?

អ៊ីចឹងខ្ញុំសូមវិលត្រឡប់ទៅសំណើរបស់ខ្ញុំវិញ ។ លោកប្រធាន លោក លោកស្រីចៅក្រម ខ្ញុំសូមឱ្យលោក លោកស្រីចៅក្រម នីមួយៗហ្នឹង គឺអនុវត្តវិធានដែលមាននៅក្នុងវិធានផ្ទៃក្នុង គឺវិធានលេខ៨៥ ហើយត្រូវធ្វើការបង្ហាញដល់ខាងសហព្រះរាជអាជ្ញាថា ពួកគេត្រូវអនុវត្តនូវការជ្រើសរើសឯកសារ ហើយពួកគេមិនអាចឱ្យលើកឡើងការពិភាក្សាគ្នាទៅលើឯកសាររាប់សិបតោននោះទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ លោកប្រធាន ។

ខ្ញុំសូមធ្វើការផ្អាកបន្តិច ដើម្បីឱ្យយើងទាំងអស់គ្នាមានអារម្មណ៍សម្រួលបួលឡើងវិញ ។ អ្វី

ដែលយើងព្យាយាមធ្វើនិងស្នើឡើងនៅទីនេះ គឺដើម្បីធ្វើការឲ្យមានលក្ខណៈងាយស្រួលដើម្បីចៀសវាងការតវ៉ាពីខាងមេធាវីការពារក្តី ។ ហើយយើងព្យាយាមដើម្បីចំណាយពេលតិច ហើយយើងធ្វើការពង្រីកដើម្បីធ្វើសេចក្តីសង្ខេបទៅលើឯកសារ ។ ជាគោលការណ៍ ដូចខ្ញុំបានបង្ហាញហើយនៅក្នុងការពិភាក្សាខាងមេធាវីការពារក្តី ហាក់ដូចជាបានយោបល់ស្របហើយ នៅពេលដែលពិភាក្សានោះ ។ ឯកសារដែលពាក់ព័ន្ធទៅនឹងរបាយការណ៍វិភាគរបស់លោកបណ្ឌិត ក្រេក អេតធេសាន់ គឺបានប្រមូលមកពីឯកសាររាប់ពាន់នៅក្នុងសំណុំរឿង ដែលលោកអ្នកជំនាញ ក្រេក អេតធេសាន់ ហើយដែលបានកំណត់ថាឯកសារខ្លះដែលសំខាន់ ហើយវាពាក់ព័ន្ធ ។

[១៦:១៤:២១]

ជាពិត យើងឃើញទំព័រនោះដល់ទៅរាប់ពាន់ទំព័រដែលមាននៅក្នុងឯកសារ១៤៨ ហើយប៉ុន្តែអ្វីដែលស្នើសុំដោយសហព្រះរាជអាជ្ញានោះ វាមិនជាការដាក់បន្ទុកទៅលើការងារពិនិត្យឯកសារ ចំពោះឯកសារទាំងអស់ទេ ។ វាជាការស្នើសុំពីយើងខ្ញុំ ពីអង្គសវនាការឲ្យផ្តល់សេចក្តីណែនាំ ថាតើយើង ថាយើងគួរតែធ្វើសេចក្តីសង្ខេបដែលល្អបំផុតតាមរបៀបណា? ដោយអនុលោមតាមវិធាន៨៧.២ និងទីបីដើម្បីឲ្យមានភាពងាយស្រួល ។ យើងនៅទីនេះដើម្បីធ្វើការរកយុត្តធម៌ឲ្យបានល្អបំផុត ហើយឲ្យបានលឿនបំផុត ។ សហព្រះរាជអាជ្ញា គឺមិនទទួលយកការចោទប្រកាន់ដែលធ្វើឡើងដោយជនជាប់ចោទឬក៏មេធាវីការពារក្តីនោះទេ ។ យើងទទួលបន្ទុកក្នុងការបង្ហាញភស្តុតាង ប្រសិនបើយើងដាក់ឯកសារនៅមុខអង្គសវនាការ បើសិនជាជនជាប់ចោទអាចធ្វើការតវ៉ាបាន គឺគាត់អាចដាក់ឯកសារដោះបន្ទុករបស់គាត់ ហើយគាត់អាចស្នើសុំអង្គសវនាការ ឬអង្គសាលាដំបូងឲ្យធ្វើការច្រានចោលឯកសារទាំងអស់នោះ ។ សហព្រះរាជអាជ្ញាបានដាក់ជូនឯកសារទាំងអស់នោះ ហើយចង់បង្ហាញភស្តុតាងទាំងឡាយដែលមាននៅក្នុងសំណុំរឿង ហើយយើងចង់ធ្វើឡើងក្នុងការបង្ហាញភស្តុតាងនេះឲ្យមានភាពលឿនដើម្បីជៀសវាងទៅលើបញ្ហាផ្សេងៗ ដែលលោក រូ បានតវ៉ានៅទីនេះ ។

ខ្ញុំមិនធ្វើការសុំទោសក្នុងការលើកបញ្ហានេះទេ ។ ខ្ញុំសុំស្នើសុំជាថ្មីម្តងទៀត ដើម្បីចំណាយពេលវេលាតិចនៅក្នុងតុលាការនេះ ហើយក្នុងគោលបំណងសុំសេចក្តីណែនាំពីអង្គសវនាការនោះគឺយើងខ្ញុំចង់ដឹងថា តើយើងគួរតែអនុវត្តនីតិវិធីយើងតាមផ្លូវណា ដើម្បីឲ្យវាមានភាពរលូន និងងាយស្រួល? នេះជាអ្វីដែលខ្ញុំសុំស្នើឡើង និងដាក់ជូនអង្គសវនាការ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានដាក់ជូននូវពាក្យសុំនិងសំណើរបស់ខ្លួនមុនពេលសហព្រះរាជអាជ្ញាចោទសំណួរទៅកាន់អ្នកជំនាញ ។

ខ្ញុំចង់ដឹងថា តើសហព្រះរាជអាជ្ញាមានបំណងក្នុងការប្រើប្រាស់ឯកសារ រាល់ឯកសារក្នុងចំណោមឯកសារ១៤៨ ទាំងអស់នោះដែលបានលើកឡើងដែរឬទេ? ដើម្បីតាំងសំណួរទៅកាន់អ្នកជំនាញ ឬក៏សហព្រះរាជអាជ្ញាគ្រាន់តែចង់យោងទៅលើសេចក្តីសង្ខេបនៅក្នុងករណីដែលថា ខ្លួនចង់ឲ្យមានការ ឲ្យខ្លួនចង់បង្ហាញសេចក្តីសង្ខេបជាជាងបង្ហាញឯកសារទាំងមូល ។

ហើយបន្ទាប់មកឯកសារដែលបង្ហាញនោះ នឹងយកមកធ្វើការវាយតម្លៃដើម្បីសំអាងជាសាលក្រមនោះ ឬក៏យ៉ាងម៉េច?

**លោក អាឡិចសាន់ឌឺ ប៊ែត៖**

សូមអរគុណ លោកចៅក្រម ។ នេះជាអ្វីដែលសហព្រះរាជអាជ្ញាចង់បាន យើងមិនចង់ធ្វើការលើកឡើងឯកសារនីមួយៗនៅក្នុងចំណោមឯកសារ១៤៨ ទាំងអស់នោះទេ ។ ការធ្វើដូច្នោះ គឺនឹងចំណាយពេលយូរណាស់ យើងខ្ញុំនឹងជ្រើសរើសឯកសារជាក់លាក់មួយចំនួន ហើយយកដេញដោលជាមួយនឹងអ្នកជំនាញ ។ ហើយយើងក៏មានបំណងក្នុងការរក្សាតុល្យភាពរវាងឯកសារនៅក្នុងឯកសារ ១៤៨ ទាំងអស់នោះដែរ ដើម្បីយកមកប្រើប្រាស់ក្នុងសាលក្រមរបស់តុលាការ ។ ហើយដើម្បីធ្វើដូច្នោះបាននោះ ការយល់របស់យើងខ្ញុំចំពោះវិធាន៨៧.២ និង៣ គឺឯកសារទាំងអស់នោះទោះបីជាឯកសារមិនដាក់ពិភាក្សាដេញដោលនៅក្នុងសវនាការក៏ដោយ ក៏ត្រូវធ្វើការសង្ខេបផងដែរ ។ ហើយការស្នើរបស់យើងខ្ញុំនោះ គឺថាការសង្ខេបនៅលើឯកសារនោះវាមានលក្ខណៈចំណាយពេលតិច ហើយយើងខ្ញុំមិនមានបំណងក្នុងការពិភាក្សាដេញដោលគ្រប់ឯកសារទាំងអស់នៃឯកសារ១៤៨ នោះទេ ។

**ប្រធានអង្គជំនុំ៖**

លោក ហ្វ្រង់ស្វ័រ រូ ត្រូវការប្រើពេលច្រើនទេ ព្រោះខាងផ្នែកបច្ចេកទេសបានអស់ *ឌីស* ហើយឌីសហ្នឹងគឺមានអំឡុងពេលតែពីរ-បីមីនុតទៀត ឌីសថតសំឡេងហ្នឹងវាអស់ ។ ត្រូវការផ្អាក ដើម្បីប្តូរចំណាយពេលយូរទេ អ្នកបច្ចេកទេស? *អូខេ* សូមអញ្ជើញ ។

[១៦:២០:០០]

**លោក ហ្វេង់ស្វ័រ រូ៖**

ខ្ញុំគ្រាន់ធ្វើការសង្កេតទៅលើចំណុចនេះ នៅពេលនេះ អ្វីដែលសំខាន់ជាងនេះសម្រាប់យើងទាំងអស់គ្នានៅពេលនេះ គឺវាជាការលើកឡើងអំពីយោបល់ទៅលើឯកសាររាប់គោន ឬក៏លទ្ធភាព និងឱកាសក្នុងការផ្តល់សម្តែងទៅដល់ខាងជនរងគ្រោះ យើងត្រូវតែកំណត់ទៅលើជម្រើសនេះ ។

ចំពោះខ្ញុំសាក្សី និងជនរងគ្រោះអាចចូលរួមនៅក្នុងដំណើរការនេះ គឺគាត់រង់ចាំដំណើរការទាំងអស់នេះ ហើយការយល់ឃើញរបស់ខ្ញុំ គឺវាសារសំខាន់ដែលថា នៅពេលនេះ នោះមានការចង់ដាក់ឯកសារជាច្រើននៅចំពោះមុខអង្គសវនាការ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវឈប់សម្រាកពីរសៀល ពេលល្ងាចនេះហើយ ហើយអង្គជំនុំជម្រះមិនអាចបន្តទៀតបានទេ ។ ប៉ុន្តែ ដោយមានហេតុនៃការលើកឡើងនូវបញ្ហាពាក់ព័ន្ធជាមួយនឹងឯកសារដែលដាក់ដោយអ្នកជំនាញ ហើយធៀបជាមួយនឹងវិធានជាធរមាននៅក្នុង ៨៧.២ និង ៨៧.៣ ដែលលើកឡើងដោយតំណាងសហព្រះរាជអាជ្ញា ហើយមានការកត់សម្គាល់ពីភាគីផ្សេងៗទៀត ហើយបញ្ហានេះជាបញ្ហាចម្បង ហើយជាបញ្ហាសំខាន់បំផុតនៅក្នុងដំណើរការប្រព្រឹត្តទៅនៃសវនាការ ចាប់ពីពេលនេះទៅ ហើយទៅមុខទៀត ។ ហេតុដូច្នេះ គឺអង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅថ្ងៃស្អែក ដោយស្តាប់សក្ខីកម្មរបស់អ្នកជំនាញ ក្រេក អេតឆេសាន់ដដែលនៅវេលាម៉ោងដប់និងសាមសិបនាទីព្រឹក ។ ដោយទុកពេលវេលាមួយសមស្របដើម្បីប្រជុំពិភាក្សា និងចេញសេចក្តីសម្រេចមុន មុននឹងស្តាប់សក្ខីកម្មរបស់អ្នកជំនាញរូបនេះ ទើបអាចដំណើរការសវនា-ការទៅមុខបាន ។ អ៊ីចឹងហើយ គឺទាមទារពេលវេលាមួយ ដើម្បីចេញសេចក្តីសម្រេចនោះ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់ទីនេះនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងដប់និងសាមសិបនាទី ។ ចំណែកឯ ភាគីដែលពាក់ព័ន្ធក៏ដូច្នោះគ្នាដែរ គឺសូមអញ្ជើញឲ្យបាននៅមុនម៉ោងដប់និងសាមសិបនាទីព្រឹកស្អែក ។ ដោយឡែកលោកបណ្ឌិត ក្រេក អេតឆេសាន់ គឺសូមអញ្ជើញមកកាន់សវនាការនៅព្រឹកថ្ងៃស្អែកតាមម៉ោងដែលបានកំណត់អម្បាញ់មិញនេះ ៕

*[សវនាការផ្អាកនៅម៉ោង ១៦:២៥:០០]*